ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ
National Institute of Education

**កែម សុកែវ**
KEM SOKEO

# ទស្សនៈយល់ឃើញរបស់សិក្ខាកាម ដែលចូលរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន TUP នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Perceptions of Teacher Learning Teacher Upgrading Program
at Royal University of Phnom Penh

**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ**
**ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

**ភ្នំពេញ ២០១៩**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education (NIE)


កែម សុកែវ

KEM SOKEO


# ទស្សនៈយល់ឃើញរបស់សិក្ខាកាម ដែលចូលរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Perceptions of Teacher Learning Teacher Upgrading Program
at Royal University of Phnom Penh

**និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ**

**ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

១. បណ្ឌិតសៀង សុវណ្ណា　　　　សាស្ត្រាចារ្យណែនាំ

ជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩

**ក្រសួងអប់រំ យុវជន និងកីឡា**
**Ministry of Education Youth and Sport**

**វិទ្យាស្ថានជាតិអប់រំ**
**National Institute of Education**

**កែម សុកែវ**

KEM SOKEO

# ទស្សនៈយល់ឃើញរបស់សិក្ខាកាម ដែលចូលរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

Perceptions of Teacher Learning Teacher Upgrading Program
at Royal University of Phnom Penh

គណៈកម្មការវាយតម្លៃនៃការការពារថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងអប់រំ

ឯកទេស៖ វគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ

ថ្ងៃទី ខែ ឆ្នាំ២០១៩

និក្ខេបបទនេះត្រូវបានវាយតម្លៃដោយ៖

______________________ ______________________

ប្រធានគណៈកម្មការ គ្រូវាយតម្លៃទី១

______________________ ______________________

គ្រូវាយតម្លៃទី២ គ្រូវាយតម្លៃទី៣

______________________ ______________________

សមាជិក សមាជិក

______________________ ______________________

លេខាកត់ត្រា

ឯកភាពដោយ៖

**តំណាងក្រសួងអប់រំ យុវជន និងកីឡា** **នាយកវិទ្យាស្ថានជាតិអប់រំ**

**ឯកឧត្តមបណ្ឌិត ជ័យ សារិន** **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា**

# សេចក្តីប្រកាសរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទដែលមានចំណងជើង **«ទស្សនៈរបស់សិក្ខាកាមរៀនវគ្គ កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ** TUP» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេស វិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិជំនាន់ទី២នៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។

ស្នាដៃនេះពុំទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថាន ឬសាកលវិទ្យាល័យណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានយកមកប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬការចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវ និងចងក្រងខាងលើនេះ ពិតជាការស្រាវជ្រាវរបស់ខ្ញុំបាទប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

ហត្ថលេខា

**កែម សុខែវ**

# ការបញ្ជាក់ពីសាស្ត្រាចារ្យដឹកនាំ

ក្នុងនាមជាសាស្ត្រាចារ្យដឹកនាំ នៃការសរសេរនិក្ខេបបទស្រាវជ្រាវនេះ សូមបញ្ជាក់ថា បេក្ខជនឈ្មោះ **កែម សុកែច** ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវខាងលើប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៩

សាស្ត្រាចារ្យណែនាំ

**សៀង សុវណ្ណា**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកទាំងអស់គ្នាដែលបានចូលរួមចំណែកជួយជ្រោមជ្រែង និងលះបង់ពេលវេលាដ៏មានតម្លៃក្នុងការចងក្រងនិក្ខេបបទនេះឡើង។

ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅបំផុតដល់លោកឪពុក **យស់ ភប** និងអ្នកម្តាយ **ខី លិ** ដែលអ្នកមានគុណទាំងពីរបានផ្តល់កំណើត ចិញ្ចឹមបីបាច់ ផ្តល់នូវដំបូន្មានល្អៗ និងបានបញ្ជូនកូនឱ្យចូលរៀនតាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សាដោយមិនគិតពីការនឿយហត់និងលំបាកព្រមទាំងតស៊ូគ្រប់បែបយ៉ាង ដើម្បីកូនទទួលបានចំណេះដឹងដល់សព្វថ្ងៃនេះ។

លោកស្រី **យ៉ុខ ចន្ធ្រា** ជាភរិយា និងក្រុមកគ្រួសារខ្ញុំ ដែលបានជួយជ្រោមជ្រែងផ្នែកថវិកា ស្មារតី និងលើកទឹកចិត្តឱ្យខ្ញុំបាទបានបន្តការសិក្សាវគ្គឯកទេសវិជ្ជាជីវៈនាយកសាលាធម្យមសិក្សាទុតិយភូមិជំនាន់ទី២ ឆ្នាំសិក្សា២០១៨-២០១៩។

សូមថ្លែងអំណរគុណឯកឧត្តម **បណ្ឌិត សៀង សុវណ្ណា** នាយកវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលវគ្គនាយកសាលា ឱ្យក្លាយជាអ្នកគ្រប់គ្រងអប់រំនៅក្នុងសាលារៀន។

សូមថ្លែងអំណរគុណដ៏ជ្រាវជ្រៅឯកឧត្តម **បណ្ឌិត សៀង សុវណ្ណា** ជាថ្មីម្តងទៀត ដែលឯកឧត្តមក៏ជាសាស្ត្រាចារ្យដឹកនាំ ហើយបានផ្តល់នូវមតិយោបល់ល្អៗពីរបៀបរៀបចំកម្រងសំណួរ ការជ្រើសរើសសំណាកដើម្បីធ្វើការសម្ភាសន៍ ជាពិសេសជំរុញឱ្យយើងខ្ញុំខិតខំប្រឹងប្រែងជម្នះឧបសគ្គដើម្បីសម្រេចបាននូវការសរសេរនិក្ខេបបទរហូតទទួលបានជោគជ័យប្រកបដោយមោទនភាព។

សូមថ្លែងអំណរគុណចំពោះឯកឧត្តម **បណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលបានបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលនាយកសាលានេះឡើង។

សូមថ្លែងងអំណរគុណផងដែរចំពោះ ឯកឧត្តមសកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាធិការរង លោកគ្រូ អ្នកគ្រូ សិក្ខាកាមដែលរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលបានអនុញ្ញាត ព្រមទាំងសម្រួលក្នុងការស្រាវជ្រាវ និងសហការក្នុងការចូលរួមបំពេញកម្រងសំណួរធ្វើឱ្យការប្រមូលទិន្នន័យសម្រាប់ការសរសេរនិក្ខេប បទនេះ ទទួលបានជោគជ័យ។

សូមអរគុណមិត្តភក្តិរួមជំនាន់ទី២ នៃវគ្គវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិទាំងអស់ ដែលបានជួយផ្តល់យោបល់ និងមតិក្នុងការកែលម្អ ហើយជួយរកឯកសារពាក់ព័ន្ធនៃនិក្ខេបបទនេះ។

សូមថ្លែងអំណរគុណដល់គ្រូឧទ្ទេសគ្រប់មុខវិជ្ជានៅវិទ្យាស្ថានជាតិអប់រំ ដែលបានជួយជ្រោមជ្រែងកិច្ចការស្រាវជ្រាវនេះ។

ជាទីបញ្ចប់ សូមគោរពជូនពរលោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោក លោកស្រីទាំងអស់ជួបតែសេចក្តីសុខ កម្លាំងមាំមួន សុខភាពល្អ និងសម្រេចគ្រប់ភារកិច្ច និងកិច្ចការទាំងអស់។

ថ្ងៃ ខែ ឆ្នាំ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៩

និស្សិតវគ្គនាយកសាលា

**កែម សុកែវ**

# មូលន័យសង្ខេប


ការសិក្សាស្រាវជ្រាវនេះមានគោលបំណងដើម្បីៈ(១) រកឱ្យឃើញទស្សនៈនានាដែលកើតមានឡើងចំពោះវគ្គ និងកម្មវិធីសិក្សានៃវគ្គបណ្តុះបណ្តាលនេះ និង(២)សិក្សាប្រៀបធៀបពីគុណសម្បត្តិ និងគុណវិបត្តិទាំងឡាយតាមរយៈផលឆ្លើយតបក្នុងអំឡុងពេលបណ្តុះបណ្តាល និងក្រោយបណ្តុះបណ្តាលដោយផ្អែកលើពេលវេលាសិក្សា កម្រិតនៃកម្មវិធីសិក្សា បញ្ហាប្រឈម ដំណោះស្រាយ ការអនុវត្តផ្ទាល់នូវអ្វីដែលសិក្ខាកាមទទួលបានពីវគ្គ។ គម្រូសំណាកក្នុងការសិក្សានេះគឺ គ្រូជាសិក្ខាកាមជំនាន់ទី២ចំនួន ១០៥នាក់ ដែលកំពុងរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញលើ៦មុខវិជ្ជាគឺ គណិតវិទ្យា ភាសាខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា។ ចំណែកឧបករណ៍ដែលប្រើប្រាស់សម្រាប់ការស្រាវជ្រាវនេះគឺ កម្រងសំណួរ ហើយត្រូវបានរៀបចំឡើងដោយអ្នកស្រាវជ្រាវដែលបានបែងចែកជាពីរផ្នែក គឺៈ (១) ព័ត៌មានទូទៅ របស់លោក គ្រូអ្នកគ្រូ និង (២) ទស្សនៈផ្ទាល់ខ្លួនរបស់សិក្ខាកាមជុំវិញការបណ្តុះបណ្តាល TUP។ រីឯទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគស្ថិតិតាមប្រព័ន្ធ EXCEL ដូចជា តម្លៃភាគរយ (%) និងប្រមូលផ្តុំគំនិតនានាដើម្បីបកស្រាយទិន្នន័យ។

លទ្ធផលសំខាន់ៗនៃការសិក្សាស្រាវជ្រាវនេះ អាចសរុបបានដូចខាងក្រោមៈ

១. លោកគ្រូអ្នកគ្រូជាសិក្ខាកាមយល់ឃើញថា ជារួមទាំងដំណើរការវគ្គ និងការរៀបចំកម្មវិធីសិក្សាទាំងមូលពោលគឺ អាចទទួលយកបានក្នុងកម្រិតល្អ ព្រោះបានផ្តល់មេរៀនល្អ គំនិតល្អ បទពិសោធ បច្ចេកទេស និងវិធីសាស្ត្រ ទោះបីមានមេរៀនខ្លះត្រូវការកម្រិតយល់ដឹងខ្ពស់ក៏ដោយ ហើយអ្វីដែលសំខាន់ពួកគាត់យល់ថាគឺ ជាហេតុផលផ្ទាល់ខ្លួនរបស់គាត់ទាក់ទងទៅនឹងសមត្ថភាពទទួលយកទៅវិញទេ។

២. ក្នុងកំឡុងពេលសិក្សា លោកគ្រូអ្នកគ្រូក៏បានជួបនូវបញ្ហាប្រឈមមួយចំនួនដូច ការធ្វើដំណើរ ថវិកា និងភាសាបរទេស ដែលបញ្ហាទាំងបីនេះមានអត្រាខ្ពស់ជាងគេក្នុងចំណោមបញ្ហាដែលបានលើកឡើង។ ក្រៅពីនោះនៅមានបញ្ហាបន្ទាប់បន្សំផ្សេងទៀតដូចជា វិធីសាស្ត្របង្រៀន ខ្លឹមសារមេរៀន បច្ចេកទេសICT មុខវិជ្ជាឯកទេស និងសម្ភារឧបទេស ដែលបញ្ហាទាំងនេះខ្លះក៏បានដោយស្រាយ និងខ្លះទៀតមិនទាន់បានដោះស្រាយនៅឡើយទេ។

៣. ក្រោយការសិក្សា សិក្ខាកាមទាំងអស់បានទទួលចំណេះដឹងជាច្រើន ហើយបានយកទៅអនុវត្តនៅសាលារៀនផ្ទាល់បានក្នុងកម្រិតមធ្យមនៅឡើយ ដោយផ្អែកលើលក្ខខណ្ឌផ្ទាល់ខ្លួន ស្ថានភាពរបស់សាលា និងស្ថានភាពសិស្សមិនទាន់មានលក្ខណៈសមស្របដែលអាចឱ្យពួកគេអនុវត្តបានល្អប្រសើរ។

# មាតិកា


សេចក្តីប្រកាសរបស់បេក្ខជន ....................................................................I
សេចក្តីបញ្ជាក់របស់សាស្ត្រាចារ្យដឹកនាំ ....................................................II
សេចក្តីថ្លែងអំណរគុណ .......................................................................III
មូលន័យសង្ខេប ................................................................................V
មាតិកា...........................................................................................VI


## ជំពូកទី១

## សេចក្តីផ្តើម


១.១- សាវតា ...................................................................................១
១.២- បញ្ហានៃការស្រាវជ្រាវ ...................................................................៥
១.៣- គោលបំណងនៃការស្រាវជ្រាវ ............................................................៦
១.៤- សំណួរស្រាវជ្រាវ .........................................................................៦
១.៥- សារៈសំខាន់នៃការស្រាវជ្រាវ ...........................................................៦
១.៦- វិសាលភាពនៃការស្រាវជ្រាវ.............................................................៧
១.៧- រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............................................................៧


## ជំពូកទី២

## រំលឹកទ្រឹស្តី


២.១- សេចក្តីផ្តើម .................................................................................៩
២.២- និយមន័យពាក្យគន្លឹះ.......................................................................៩
២.៣- ទិដ្ឋភាពទូទៅនៃការបណ្តុះបណ្តាលគ្រូ...................................................១០
២.៣.១- គោលនយោបាយកំណែទម្រង់វិស័យអប់រំ .......................................១០
២.៣.២- គោលនយោបាយគ្រូបង្រៀន .......................................................១៥
២.៣.៣- ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ........................................................១៧
ក. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា ................................................១៧
ខ. ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀននៅអាស៊ីអាគ្នេយ៍.........................................២០
២.៣.៤- ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ...................................................២៣
ក. ករណីកិច្ចគ្រូបង្រៀន .................................................................២៣
ខ.ករណីកិច្ចគ្រូបង្រៀនចំពោះអាណាព្យាបាលសិស្ស ...................................២៤
គ. ករណីកិច្ចគ្រូបង្រៀនត្រូវជៀសវាង....................................................២៥
ឃ. តួនាទី និងគុណសម្បត្តិគ្រូបង្រៀនសម័យឌីជីថល.................................២៥
២.៣.៥- កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅ RUPP ..................................២៦
ក. លក្ខណៈទូទៅនៃវគ្គបណ្តុះបណ្តាល TUP.............................................២៧

ខ. ចក្ខុវិស័យ វត្ថុបំណង និងគោលបំណងនៃវគ្គបណ្តុះបណ្តាល TUP.... ២៧
គ. យុទ្ធសាស្ត្រនៃការបណ្តុះបណ្តាល TUP.......................................... ២៨

# ជំពូកទី ៣
# វិធីសាស្ត្រស្រាវជ្រាវ

៣.១- ការរៀបចំស្រាវជ្រាវ ...................................................................................៣០
៣.២- វិធីសាស្ត្រប្រមូលទិន្នន័យ ..........................................................................៣០
៣.៣- ការជ្រើសរើសសំណាក ..............................................................................៣១
៣.៤- ឧបករណ៍ស្រាវជ្រាវ ................................................................................. ៣២
៣.៥- កម្រងសំណួរ និងគោលបំណងស្រាវជ្រាវ ........................................................ ៣២
៣.៦- ការវិភាគទិន្នន័យ .................................................................................... ៣២
៣.៧- ក្រមសីលធម៌នៃការស្រាវជ្រាវ.....................................................................៣៣

# ជំពូកទី ៤
# វិធីសាស្ត្រវិភាគទិន្នន័យ

៤.១- ព័ត៌មាន និងលក្ខណៈនៃវគ្គសិក្សា ...............................................................៣៤
៤.១.១- ព័ត៌មានមុនការបណ្តុះបណ្តាល ...........................................................៣៤
៤.១.២- ប្រភពព័ត៌មាន...............................................................................៣៥
៤.២- លខ្ខខណ្ឌ និងមូលហេតុនៃការស្រាវជ្រាវ ........................................................៣៦
៤.២.១- លក្ខខណ្ឌនៃការចូលរៀន ..................................................................៣៦
៤.២.២- មូលហេតុនៃការចូលរៀន ..................................................................៣៨
៤.៣- ទស្សនៈអំពីពេលវេលានៃការសិក្សា ...............................................................៣៩
៤.៤- ទស្សនៈចំពោះសមត្ថភាព និងកម្មវិធីសិក្សា ...................................................... ៤១
៤.៤.១- ទស្សនៈសិក្ខាកាមធៀបនឹងកម្មវិធីសិក្សា............................................... ៤១
៤.៤.២- កម្មវិធីសិក្សា ................................................................................. ៤២
៤.៥- វិធីបង្រៀន និងការប្រតិបត្តិ.............................................................................៤៣
៤.៦- បញ្ហាប្រឈម និងដំណោះស្រាយ.................................................................... ៤៥
៤.៦.១- បញ្ហាប្រឈម ................................................................................. ៤៥
៤.៦.២- ដំណោះស្រាយ...............................................................................៤៧
៤.៧- ប្រសិទ្ធភាព និងនិរន្តភាពនៃវគ្គសិក្សា ............................................................ ៤៨

៤.៧.១- ការអនុវត្តជាក់ស្តែង ......................................................................... ៤៨
៤.៦.២- ទស្សនៈអំពីវគ្គសិក្សា TUP.............................................................. ៤៩
៤.៦.៣- និរន្តរភាពនៃវគ្គ.............................................................................. ៥១

# ជំពូកទី ៥
# សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍

៥.១- សេចក្តីសន្និដ្ឋាន ....................................................................................................៥៣
៥.១.១- ការកំណត់ពេលវេលា និងការអនុវត្តកម្មវិធីសិក្សានៃវគ្គ..........................៥៣
៥.១.២- ការអនុវត្តចំណេះដឹង និងវិធីសាស្រ្តបង្រៀន ........................................៥៣
៥.១.៣- បញ្ហាប្រឈមនៃវគ្គសិក្សា.................................................................... ៥៤
៥.១.៤- ទស្សនៈអំពីវគ្គ................................................................................... ៥៤
៥.២- សំណូមពរ ........................................................................................................ ៥៤
៥.២.១- ក្រសួងអប់រំ យុវជន និងកីឡា ........................................................... ៥៥
៥.២.២- ម្ចាស់ជំនួយ ........................................................................................ ៥៥
៥.២.៣- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ.......................................................... ៥៥
៥.២.៤- មន្ទីរអប់រំ យុវជន និងកីឡា ................................................................ ៥៥
៥.២.៥- គណៈគ្រប់គ្រងសាលារៀន................................................................... ៥៦
៥.២.៦- គ្រូបង្រៀន ឬសិក្ខាកាម ...................................................................... ៥៦
៥.២.៧- អាណាព្យាបាលសិស្ស.........................................................................៥៧
៥.៣- អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ..................................................... ៥៨
គន្ថនិទ្ទេស

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១-សារតារ

ការវិវត្ត និងរីកចម្រើនពីសម័យកាលមួយទៅសម័យកាលមួយគឺកើតឡើងដោយសារការខិតខំប្រឹងប្រែងរបស់មនុស្សពីជំនាន់មួយទៅជំនាន់មួយ។ ដោយសារតែការខិតខំប្រឹងប្រែងនេះហើយ ដែលអាចឱ្យមនុស្សបំពេញនូវតម្រូវការទាំងឡាយបានគ្រប់បែបយ៉ាង។ ការប្រែប្រួលនេះ ត្រូវបានកំណត់ និងបែងចែកទៅតាមដំណាក់កាលផ្សេងៗគ្នា ដែលក្នុងឯកសារបកប្រែរបស់លោក តាន់ មន្នីវិសាល ទំព័រទី២ (ឧស្សាហកម្ម៤.០) ក្នុងឆ្នាំ២០១៩ បានចែកបដិវត្តន៍ឧស្សាកម្មជា ៤ ដំណាក់កាល គឺ ១) ការបង្កើតម៉ាស៊ីនដើរដោយចំហាយទឹកគួបផ្សំជាមួយការប្រើប្រាស់នូវផ្លូវរថភ្លើង ២) របកគំហើញថាមពលអគ្គីសនី និងការបង្កើតខ្សែសង្វាក់ផលិតកម្មនៅក្នុងរោងចក្រ ៣) ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា ប្រព័ន្ធអ៊ិនធើណែត ព័ត៌មានវិទ្យា សីមីកុងឌុចទ័រ (Semi-conductor) និងកុំព្យូទ័រភាវូបនីយកម្ម និង ៤) ការពឹងផ្អែកលើមូលដ្ឋានគ្រឹះរបស់បច្ចេកវិទ្យា ៣យ៉ាងមានពិភពរូប ពិភពឌីជីថល និងពិភពជីវសាស្ត្រ។ បច្ចុប្បន្នការគ្រប់គ្រង និងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឌីជីថលកំពុងត្រូវបានប្រទេសទាំងអស់នៅលើពិភពលោកកំពុងខិតខំពង្រឹងបញ្ចេញអស់សមត្ថភាពដើម្បីដើរឱ្យទាន់សម័យកាលមួយនេះ។

ការរីកចម្រើនឥតឈប់ឈរយ៉ាងឆាប់រហ័ស និងការប្រកួតប្រជែងស្វែងរកឧត្តមភាពនៅលើពិភពលោកក្នុងបរិបទសកលភាវូបនីកម្មនេះហើយ ទាមទារឱ្យប្រទេសនីមួយៗខិតខំបង្កើនគុណភាពផលិតផល និងសេវាកម្មរបស់ខ្លួនឱ្យបានជាអតិបរមា។ ការប្រើប្រាស់ធនធានមនុស្សឱ្យអស់ពីលទ្ធភាពមានសារៈសំខាន់ណាស់ ដែលជាកម្លាំងចលករមិនអាចខ្វះបានក្នុងការធ្វើឱ្យសម្រេចបំណងប្រាថ្នាខាងលើ និងធ្វើឱ្យអាជីពជីវិតបុគ្គល អង្គភាព សង្គម និងប្រទេសជាតិមានការផ្លាស់ប្តូរ និងការរីកចម្រើនប្រកបដោយចីរភាព។ សមាហរណកម្មក្នុងតំបន់ តម្រូវឱ្យប្រទេសនីមួយៗក្នុងអាស៊ានចូលរួមក្នុងកិច្ចសហការ និងការប្រកួតប្រជែងជាមួយប្រទេសជិតខាងលើគ្រប់វិស័យ ដើម្បីសម្រេចបាននូវចក្ខុវិស័យរួមមួយរបស់អាស៊ានទាំងមូល។ ដើម្បីសម្របខ្លួនទៅនឹងការវិវត្តរបស់ពិភពលោក និងតំបន់ ក្នុងន័យបង្កើនភាពឆ្លើយតបទៅនឹងការប្រកួតប្រជែងប្រទេសជាសមាជិកអាស៊ានទាំងអស់ ត្រូវមានធនធានមនុស្សដែលមានសមត្ថភាព និងវិជ្ជាជីវៈខ្ពស់[1] ។

[1] ក្រសួងអប់រំ យុវជន និងកីឡា-គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ ២០១២ ទំព័រ២

ការសិក្សាអប់រំគឺ ជាផ្នែកមួយដ៏សំខាន់ក្នុងការកសាងធនធានមនុស្ស និងដឹកនាំមនុស្សឱ្យចេះពីរបៀប ឬបែបបទផ្សេងៗនៃដំណើរជីវិតរស់នៅប្រចាំថ្ងៃ។ ការសិក្សាអប់រំធ្វើឱ្យមនុស្សគ្រប់រូបអាចគេចផុតពីភាពល្ងង់ខ្លៅគ្រប់បែបយ៉ាង នៅក្នុងជីវិតដោយសារតែការអប់រំធ្វើឱ្យមនុស្សគ្រប់រូបចេះគិតចេះពិចារណារកហេតុផល ស្គាល់ខុស ស្គាល់ត្រូវ ពិសេសចេះដោះស្រាយបញ្ហាដោយសុភវិនិច្ឆ័យ។ ការអប់រំត្រូវទទួលបានតាំងពីមនុស្សយើងកើតមករហូតដល់ស្លាប់ទៅវិញ មានន័យថាមនុស្សយើងគ្រប់រូបទទួលបានការអប់រំពេញមួយជីវិតតែម្តង។ ការសិក្សាអប់រំមាននៅគ្រប់មជ្ឈដ្ឋានទាំងអស់ ទាំងនៅក្នុងគ្រួសារ សាលារៀន និងសង្គមជាតិ។ ការអប់រំត្រូវបានគេទទួលស្គាល់ថា ជាលក្ខខណ្ឌដំបូងសម្រាប់ការបំពេញធនធានមនុស្ស សន្តិភាព និរន្តរភាព នៃការអភិវឌ្ឍការលូតលាស់ផ្នែកសេដ្ឋកិច្ច សមភាពយេនឌ័រ និងភាពទទួលខុសត្រូវជាពលរដ្ឋទូទាំងសកលលោក។ តាមរយៈប្រព័ន្ធអប់រំដ៏ខ្លាំងក្លាបាននាំមកនូវធនធានមនុស្សដ៏សម្បូរបែប ហើយបានចូលរួមដោយផ្ទាល់ និងដោយប្រយោលទៅលើការលូតលាស់ផ្នែកសេដ្ឋកិច្ច ជាពិសេសសង្គមមួយដែលពោរពេញទៅដោយការអប់រំប្រកបដោយគុណភាពនោះគឺ កាន់តែជួយជំរុញសង្គមនោះឱ្យឈានទៅរកអត្រានៃការច្នៃប្រឌិតផលិតភាពផ្ទាល់ខ្លួនកាន់តែខ្ពស់ តាមរយៈសមត្ថភាពដ៏រឹងមាំក្នុងការបង្ហាញ និងណែនាំនូវវិធីសាស្ត្រនៃការផលិតដ៏ថ្មីស្រឡាង ព្រមទាំងបច្ចេកវិទ្យាទំនើបៗដ៏លឿនរហ័សផងដែរ (J. Anne Anderson, 2005)។ ដើម្បីឱ្យការអប់រំមួយរីកចម្រើន និងមានគុណភាព គេចាំបាច់ត្រូវគិតទៅលើការអប់រំបណ្តុះមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ឱ្យមានទាំងសមត្ថភាព និងជំនាញខ្ពស់។ គ្រួសារឬសង្គមជាតិមួយរីកចម្រើនលូតលាស់មានការអភិវឌ្ឍទៅបានក៏បណ្តាលមកពីសមាជិកគ្រួសារ និងប្រទេសជាតិនោះសម្បូរទៅដោយអ្នកមានចំណេះដឹង មានជំនាញ មានសីលធម៌ ហើយចេះរស់នៅជាមួយគ្នានៅក្នុងសង្គមប្រកបដោយភាពសុខដុមរមនា។ ការអប់រំជាកត្តាមួយដ៏ចម្បងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិ។ គ្មានប្រទេសណាមួយកាត់ផ្តាច់ការអប់រំបាននោះទេ គេតែងតែផ្តល់អាទិភាពឱ្យវិស័យអប់រំជានិច្ច ដោយហេតុថាបើមិនមានវិស័យអប់រំទេ វិស័យដទៃទៀតក៏មិនអាចរីកចម្រើនបានដែរ ព្រោះសមាជិកទាំងអស់នៃក្រសួង ស្ថាប័ន ឬអង្គភាព ទាំងនោះមិនមានចំណេះដឹង និងជំនាញក្នុងការបំពេញកិច្ចការបាន។ ការងារទាំងឡាយ ទាំងពួងទាមទារឱ្យមនុស្សគ្រប់រូបមានសមត្ថភាពទើបអាចធ្វើការទាំងនោះបានហើយដើម្បីឱ្យមានជំនាញសមត្ថភាពគឺមនុស្សគ្រប់រូបត្រូវទទួលបានការអប់រំ។

ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពសម្រាប់បម្រើប្រទេសជាតិ មិនអាចកាត់ផ្តាច់ចេញពីការអប់រំបានឡើយ។ វិស័យអប់រំរីកចម្រើន និងមានប្រសិទ្ធភាពទាមទារជាចាំបាច់នូវកម្រិតសមត្ថភាពរបស់គ្រូបង្រៀនដែលក្រសួងអប់រំ យុវជន និងកីឡាបាននឹងកំពុងថែបំប៉ន។

កម្ពុជាបានឆ្លងកាត់ដំណាក់កាលជូចត់ជាច្រើនតាំងពីទសវត្សទី៧០ រហូតដល់ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩ គឺនៅថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៨០ ក្រសួងអប់រំ ត្រូវបានបង្កើតឡើងវិញ សាលារៀនគ្រប់កម្រិតសិក្សាក្នុងទូទាំងប្រទេសត្រូវបានបើកទ្វារទទួលសិស្សានុសិស្ស។ តាំងពីនោះមក កម្ពុជាមានឱកាសស្តារ និងកសាងប្រទេសពីបាតដៃទទេទើបមកដល់ថ្ងៃនេះ ហើយជាការលំបាកមួយរបស់កម្ពុជា ព្រោះធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធទាំងអស់ត្រូវបានបំផ្លិចបំផ្លាញស្ទើរគ្មានសល់នៅសម័យកម្ពុជាប្រជាធិបតេយ្យ។ យ៉ាងណាមិញ ប្រព័ន្ធអប់រំក៏ត្រូវបានបំបាត់អស់ ធ្វើឱ្យមនុស្សដែលសល់ពីរបបនេះសុទ្ធតែជាមនុស្សបាក់កម្លាំង ពិការ ហើយបញ្ញាវន្តត្រូវបានគេយកទៅសម្លាប់ចោលតិចណាស់ដែលបានរួចជីវិតមក។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យនេះ កម្ពុជាបានចាប់ផ្តើមអនុវត្តគោលនយោបាយអប់រំដោយជ្រើសរើសអ្នកដែលចេះអក្សរមកចូលបម្រើការក្នុងការងាររដ្ឋការ អនុវត្តគោលការណ៍អ្នកចេះច្រើនបង្រៀនអ្នកចេះតិច និងអ្នកចេះតិចបង្រៀនអ្នកមិនចេះសោះ។ ក្នុងស្ថានភាពដ៏លំបាកនេះ ការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនត្រូវបានចាប់ផ្តើមពីការប្រមូលគ្រូបង្រៀន សិស្សនិស្សិត និងអ្នកមានកម្រិតវប្បធម៌មួយចំនួនដែលនៅសេសសល់ពីការសម្លាប់មកបំពាក់បំប៉នចិត្តគរុកោសល្យ និងវិធីសាស្រ្តបង្រៀនរយៈពេលខ្លីនៅតាមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តទាំង១៨ រួចបញ្ជូនទៅសាលារៀនចំណេះទូទៅនៅទូទាំងប្រទេស។ ជាមួយគ្នានេះដែរ ការបំប៉នមន្ត្រីអប់រំក៏ត្រូវបានចាប់ផ្តើមផងដែរ តាមរយៈការបើកវគ្គបំប៉នប្រមូលផ្តុំនៅសាលាជាន់ខ្ពស់កម្មាភិបាលគ្រប់គ្រងអប់រំ ដែលបច្ចុប្បន្នក្លាយទៅជាវិទ្យាស្ថានជាតិអប់រំ[2] ។

ក្នុងអាណត្តិទី៦ ឆ្នាំ២០១៨-២០២៣នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដោយចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។ ទន្ទឹមនឹងនោះ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញានឹងសម្រេចឱ្យបាននូវមុំទី១ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្រ្ត និងបច្ចេកវិទ្យា" ដោយផ្តល់អាទិភាពលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សា

[2] (ក្រសួងអប់រំ យុវជន និងកីឡា-ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ២០១៦ ទំព័រ ១-២

ទុតិយភូមិ ៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣[3]។

ក្រសួងអប់រំ យុវជន និងកីឡាក៏បានធ្វើមូលដ្ឋានីយកម្ម មានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពស្តីពីការអប់រំឆ្នាំ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ដែលមានគោលនយោបាយពីរគឺ ១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងធានាភាពសក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ ទន្ទឹមនឹងនេះ ក្រសួងបាននឹងកំពុងអនុវត្តផែនការនយោបាយគ្រូបង្រៀន ក្នុងគោលបំណងលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន សមត្ថភាពគ្រូបង្រៀនដោយផ្សាភ្ជាប់ទៅនឹងការតម្លើងប្រាក់បៀវត្ស និងការលើកទឹកចិត្ត។ ក្រសួងបានបំប៉នគ្រូថ្នាក់ទី១២ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រទូទាំងប្រទេស បណ្តុះបណ្តាលគ្រូឧទ្ទេស៥៦ នាក់ ស្រី ២០នាក់ឱ្យមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ បំប៉នសមត្ថភាពគ្រូឧទ្ទេសគរុកោសល្យផ្នែកគណិតវិទ្យា វិទ្យាសាស្ត្រ និងកម្មសិក្សាគរុកោសល្យ អនុម័តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ បង្កើតការិយាល័យគាំទ្រគ្រូបង្រៀន អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាល គ្រូបង្រៀនកម្រិតមូលដ្ឋានទៅជាគ្រូបង្រៀនកម្រិតឧត្តមតាមប្រព័ន្ធពន្លឿនលើ៦មុខវិជ្ជា រួមមានគណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា អក្សរសាស្ត្រ និងប្រវត្តិវិទ្យា[4] ។

បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡាបានកំពុងយកចិត្តទុកដាក់លើយ៉ាងខ្លាំងលើការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនដែលជា ការងារស្នូលក្នុងការជំរុញ និងកែលម្អគុណភាពអប់រំ។ តាមរយៈសសរស្តម្ភទាំងប្រាំនៃការអប់រំគឺ ១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២) ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលំអបរិស្ថាន ៣) ការដាក់ឱ្យអនុវត្តអធិការកិច្ច ៤) ការពង្រឹងស្វ័យភាពសិក្សាមានរូបភាពផ្សេងៗដូចជាការប្រឡង ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ និង ៥) ការកែទម្រង់ឧត្តមសិក្សា[5] បញ្ជាក់ឱ្យឃើញថា ការលើកកម្ពស់គុណភាពអប់រំត្រូវមានកត្តាពាក់ព័ន្ធជាច្រើន ពិសេសគឺ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀននៅតាមកម្រិតភូមិសិក្សានៃគ្រឹះស្ថានសិក្សានីមួយៗ។

[3] ក្រសួងអប់រំ យុវជន និងកីឡា-លិខិតលេខ៥១៥២ អយក.រប ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០១៨

[4] (ក្រសួងអប់រំ យុវជន និងកីឡា- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣) ២០១៨ ទំព័រ ៤ និង១០

[5] Google. Usaid.com/km/Cambodia/education- វិស័យអប់រំ និងការគាំពារកុមារ

មិនត្រឹមតែប៉ុណ្ណោះយើងឃើញថា ដើម្បីពង្រឹងគុណភាពអប់រំ ក្រសួងតែងតែខិតខំតាមដាន ត្រួតពិនិត្យ បើកវគ្គបណ្តុះបណ្តាលគ្រូ សិក្ខាសាលា ការសាកល្បងនូវវិធីសាស្ត្របង្រៀនថ្មីៗ និងកំណែទម្រង់ផ្សេងៗទៀតក្នុងចេតនាជួយពង្រឹង និងលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាដែលជាបញ្ហាកើតមានយូរណាស់មកហើយក្នុងវិស័យអប់រំ។ តែទោះបីជាក្រសួងអប់រំ យុវជន និងកីឡា ឬស្ថាប័នពាក់ព័ន្ធដទៃទៀតយកចិត្តទុកដាក់ទៅលើការពង្រឹងគុណភាពអប់រំតាមរយៈការអនុវត្តសកម្មភាពកំណែទម្រង់ជាច្រើនយ៉ាងណាក៏ដោយ គេនៅតែសង្កេតឃើញថាមានបញ្ហាជាច្រើនកើតមានទាក់ ទងនឹងគុណភាពសិស្សដែលជាការសន្និដ្ឋានដំបូងគឺថាបណ្តាលមកពីសមត្ថភាពគ្រូ និងបញ្ហាជាច្រើនទៀតដែលនៅមិនទាន់អាចឆ្លើយតបនូវគោលបំណងដែលបានដាក់ចេញនៅឡើយ។

## ១.២-បញ្ហានៃការស្រាវជ្រាវ

សព្វថ្ងៃក្រសួងអប់រំ យុវជន និងកីឡាកំពុងយកចិត្តទុកដាក់ធ្វើកំណែទម្រង់វិស័យអប់រំដើម្បីធ្វើឱ្យវិស័យអប់រំនៅកម្ពុជាមានការរីកចម្រើន និងមានសក្តានុពលអាចប្រកួតប្រជែងទាំងក្នុងតំបន់ និង សកលលោក។ កន្លងមក ក្រសួងបានធ្វើការងារជាច្រើន ដូចជាការប្រឡងផ្ទៃក្នុងការប្រឡងពន្លឿនពីគ្រូកម្រិតមូលដ្ឋានទៅគ្រូកម្រិតឧត្តមដែលបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ និងនៅឆ្នាំសិក្សា ២០១៨-២០១៩ កន្លងមកនេះ ក្រសួងបានរើសគ្រូកម្រិតមូលដ្ឋានចំនួន ២១៥នាក់ ស្រី ១០៥នាក់ តាមគម្រោងសហការជាមួយអង្គការ SEIP ដើម្បីឱ្យចូលរៀនបំប៉នវគ្គ កម្មវិធីអភិវឌ្ឍគុណវុឌ្ឍិគ្រូបង្រៀន នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញរយៈពេល២ឆ្នាំពេញ ក្នុងន័យជួយបង្កើនសមត្ថភាពគ្រូបង្រៀន ប៉ុន្តែសិក្ខាកាមទាំងអស់មិនបានទទួលក្របខណ្ឌជាគ្រូបង្រៀនកម្រិតឧត្តមដូចគ្រូបង្រៀនវគ្គពន្លឿនដែលធ្វើនៅវិទ្យាស្ថានជាតិអប់រំឡើយដោយគ្រាន់តែដំឡើងគុណវុឌ្ឍិរបស់ពួកគាត់ឱ្យមានតម្លៃស្មើថ្នាក់បរិញ្ញាបត្រប៉ុណ្ណោះ។ ទោះបីជាក្រសួងអប់រំ យុវជន និងកីឡាឬស្ថាប័នពាក់ព័ន្ធដទៃទៀតយកចិត្តទុកដាក់ទៅលើការពង្រឹងគុណភាពអប់រំ តាមរយៈការអនុវត្តសកម្មភាពជាច្រើនយ៉ាងណាក៏ដោយ ក៏គេនៅតែសង្កេតឃើញថា សកម្មភាពទាំងនោះនៅតែមិនទាន់អាចឆ្លើយតបនូវគោលបំណងដែលបានដាក់ចេញនៅឡើយ។ ដោយមើលឃើញពីបញ្ហាដូចដែលបានរៀបរាប់ខាងលើនេះ ហើយទើបអ្នកស្រាវជ្រាវសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវក្នុងគោលបំណងដូចការរៀបរាប់ខាងក្រោមស្រាប់។

## ១.៣-គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងដូចខាងក្រោម៖

១. រកឱ្យឃើញនូវទស្សនៈនានាដែលកើតមានឡើងចំពោះវគ្គ រួមទាំងកម្មវិធីសិក្សានៃវគ្គបណ្តុះបណ្តាលនេះ។
២. សិក្សាប្រៀបធៀបពីគុណសម្បត្តិ និងគុណវិបត្តិទាំងឡាយតាមរយៈផលឆ្លើយតបក្នុងអំឡុងពេលបណ្តុះបណ្តាល និងក្រោយបណ្តុះបណ្តាល។

## ១.៤-សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវនៃប្រធានបទស្រាវជ្រាវខាងលើគឺៈ
១. តើលោកគ្រូ អ្នកគ្រូយល់ឃើញដូចម្តេចខ្លះ ចំពោះការរៀបចំ និងកម្មវីធីសិក្សានៃវគ្គបណ្តុះបណ្តាលនេះ?
២. តើមានផលឆ្លើយតបវិជ្ជមាន និងអវិជ្ជមានអ្វីខ្លះសម្រាប់លោកគ្រូ អ្នកគ្រូបង្រៀននៅតាមវិទ្យាល័យក្នុងអំឡុងពេលបណ្តុះបណ្តាល និងក្រោយពេលបណ្តុះបណ្តាល?

## ១.៥-សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវពីទស្សនៈរបស់សិក្ខាកាមរៀនវគ្គ TUP នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនេះគឺ ពិតជាមានសារៈសំខាន់ណាស់ព្រោះវាធ្វើឱ្យសាលារៀនអាចរៀបចំគម្រោងផែនការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនតាមកម្រិតសិក្សានីមួយៗ ហើយមិនត្រឹមតែប៉ុណ្ណោះ សាលារៀនក៏អាចទទួលបាននូវចំណេះដឹងទាក់ទងនឹងការបណ្តុះបណ្តាលគ្រូនេះដែរ។ លើសពីនេះទៅទៀត ក្រសួងក៏អាចមើលឃើញពីទិដ្ឋភាព និងទទួលបាននូវព័ត៌មានទាំងឡាយជុំវិញការបណ្តុះបណ្តាល ដើម្បីងាយស្រួលក្នុងការវាយតម្លៃ កែលម្អ និងបន្តនិរន្តភាពនៃវគ្គបំប៉ននេះ ហើយម៉្យាងវិញទៀត ក្រសួងងាយស្រួលក្នុងការរៀបចំផែនការអភិវឌ្ឍវិស័យអប់រំសម្រាប់ឆ្នាំបន្តបន្ទាប់។ មួយវិញទៀតប្រធានបទនេះនៅមានសារៈសំខាន់មួយទៀត គឺសម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកសិក្សាក្នុងការសិក្សារៀនសូត្រ និងធ្វើការសិក្សាស្រាវជ្រាវផ្សេងៗ។

## ១.៦-វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ដោយសារខ្លឹមសារស្រាវជ្រាវនៃប្រធានបទទស្សនៈរបស់សិក្ខាកាមរៀនវគ្គ TUP មានតែនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញប៉ុណ្ណោះ ដូច្នេះហើយ អ្នកស្រាវជ្រាវបានកំណត់យកទីតាំងនៃការស្រាវជ្រាវនៅតែសាកលវិទ្យាល័យភូមិន្ទភ្នំពេញនេះតែម្តង ដែលវគ្គសិក្សានេះ ទើបតែបានពីរជំនាន់ចាប់ពីឆ្នាំសិក្សា២០១៨មក។ ក្នុងនោះ អ្នកស្រាវជ្រាវបានជ្រើសរើសយកគំរូសំណាកតែសិក្ខាកាមដែលរៀននៅជំនាន់ទី២ ហើយការសិក្សាស្រាវជ្រាវនេះគឺ ផ្តោតតែទៅលើទស្សនៈយល់ឃើញរបស់លោកគ្រូអ្នកគ្រូ ដែលបានចូលរៀនវគ្គបំប៉នកម្មវិធីលើកកម្ពស់

គុណវុឌ្ឍិគ្រូបង្រៀន TUP ដោយផ្តោតតែទៅលើកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន ផលវិជ្ជមាន និងអវិជ្ជមាន និងផលឆ្លើយតបទាំងឡាយនៃការសិក្សាក្នុងវគ្គនេះតែប៉ុណ្ណោះ។

## ១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកជាប្រាំជំពូកដូចខាងក្រោម៖

ជំពូកទី១៖ សេចក្តីផ្តើមរួមមានលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់នៃ ការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី២៖ រំឭកទ្រឹស្តី ពិនិត្យមើលឯកសារ និងការសិក្សាពីមុនៗ ដើម្បីស្វែងយល់ពីភាពខុសគ្នារវាងការសិក្សាដែលកំពុងធ្វើជាមួយនិងការសិក្សាពីមុន។

ជំពូកទី៣៖ រៀបរាប់អំពីវិធីសាស្ត្រស្រាវជ្រាវដែលអ្នកសិក្សាស្រាវជ្រាវ បានយកមកប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវនេះ។ ក្នុងជំពូកនេះ អ្នកស្រាវជ្រាវបង្ហាញពីរបៀបនៃការសិក្សា ការប្រមូលសំណាក ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់គណនា និងការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

ជំពូកទី៤៖ លទ្ធផលនិងការបកស្រាយ៖ ក្នុងផ្នែកនេះ អ្នកស្រាវជ្រាវលើកឡើងពីលក្ខណៈជាក់ស្តែងដែលខ្លួនបានធ្វើការសិក្សាស្រាវជ្រាវរួចហើយគឺ ត្រូវឆ្លើយតបទៅនឹងចំណុចដែលបានចោទសួរនៅក្នុងចំណោទបញ្ហា។ ការបកស្រាយត្រូវបកស្រាយយ៉ាងលម្អិតទៅលើគោលបំណងនៃការស្រាវជ្រាវ ដោយយោងទៅលើលទ្ធផលនៃការស្រាវជ្រាវ ទ្រឹស្តី ឬខ្លឹមសារដែលមាននៅក្នុងកម្រងសំណួរ ។

ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ៖ ជំពូកនេះអ្នកស្រាវជ្រាវ ត្រូវធ្វើការសង្ខេបការសិក្សាស្រាវជ្រាវ រួចទាញជាសេចក្តីសន្និដ្ឋានលើចំណុចដែលបានវិភាគ និងផ្តល់យោបល់ ឬសំណូមពរទៅលើចំណុចដែលត្រូវកែលម្អ ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១-សេចក្តីផ្តើម

ក្រសួងអប់រំ យុវជន និងកីឡា ជាក្រសួងអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដែលមានចំនួនបុគ្គលិកបម្រើការច្រើនជាងគេ។ ប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងក្រសួងអប់រំ យុវជន និងកីឡាមានសារៈសំខាន់ណាស់ ព្រោះមិនត្រឹមតែជួយធ្វើសនិទានកម្មធនធានមនុស្សនិងមានចីរភាព ពិសេសការប្រើប្រាស់ក្នុងមុខងារសាធារណៈ។ ដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួនដូចជាគុណវុឌ្ឍិ សមត្ថភាពវិជ្ជាជីវៈ ការពង្រាយបុគ្គលិកអប់រំទៅតំបន់ដាច់ស្រយាល ជីវភាពរស់នៅរបស់មន្ត្រីអប់រំ លក្ខខណ្ឌបំពេញការងារ ការគ្រប់គ្រងធនធានមនុស្ស ការជ្រើសរើស និងការតែងតាំង គុណភាពបំពេញការងារនិងការគាំទ្រការបង្រៀន ក្រសួងបានកសាងគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន ដូចជាច្បាប់ស្តីពីការអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ការលើកកម្ពស់គុណភាពអប់រំ គឺជាការងារដ៏លំបាកមួយ ដែលតម្រូវឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើន។ ក្នុងកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យអប់រំ ក្រសួងបានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពជាច្រើនក្នុងគោលបំណងសម្រេចឱ្យបាននូវភាពឆ្លើយតបមួយ ក្នុងវិស័យអប់រំ និងអាចផលិតបាននូវធនធានមនុស្សប្រកបដោយសក្តានុពល អាចប្រកួតប្រជែងនៅក្នុងថ្នាក់តំបន់ និងអន្តរជាតិ។ ការងារនេះហើយដែលក្រសួងនបានចាប់ផ្តើមអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនឱ្យអាចអនុវត្តការងារក្នុងវិជ្ជាជីវៈបានល្អប្រសើរពោលគឺ អាចផលិតធនធានមនុស្សប្រកបដោយគុណភាពសមស្របតាមសម័យកាលនៃសង្គមសព្វថ្ងៃ។

## ២.២-និយមន័យពាក្យគន្លឹះ

គុណវុឌ្ឍិគឺ សំដៅលើសមត្ថភាព ចំណេះដឹង ឬជំនាញដែលមានភាពស៊ីទៅនឹងឱកាស ហើយអាចឱ្យមនុស្សមានសមត្ថភាពក្នុងមុខរបរវិជ្ជាជីវៈ និងតួនាទី (Business Dictionary) និងជាដំណើរការធ្វើឱ្យមានភាពរីចម្រើន និងល្អប្រសើរក្នុងអាជីព (វចនានុក្រមខ្មែរ ឆ្នាំ២០១១) ។ ម៉្យាងទៀត គុណវុឌ្ឍិសំដៅដល់លក្ខណៈសម្បត្តិលើសមត្ថភាពទទួលស្គាល់ជាផ្លូវការក្នុងក្របខណ្ឌអប់រំ ឬវិជ្ជាជីវៈ ដែលបញ្ជាក់ដោយសញ្ញាបត្រ ឬវិញ្ញាបនបត្រ [6]។ ការលើកកម្ពស់គុណវុឌ្ឍិ ជាការពង្រឹងសមត្ថភាពជំនាញក្នុងវិជ្ជាជីវៈ ដើម្បីបំពេញបាននូវតម្រូវការក្នុងតួនាទីឱ្យមាន

[6] ក្រសួងអប់រំ យុវជន និងកីឡា-គោលនយោបាយស្តីពីគ្រូបង្រៀន ២០១៣ ទំព័រទី៨

ភាពល្អប្រសើរ ហើយអាចឆ្លើយតបនឹងតម្រូវការសង្គមផងដែរ។ ក្រៅពីនេះ ការលើកកម្ពស់គុណវុឌ្ឍិសំដៅដល់ការធ្វើឱ្យប្រសើរឡើងនូវកម្រិតសមត្ថភាព ចំណេះដឹង និងចំណេះធ្វើ ក្នុងគោលដៅជួយឱ្យមនុស្សម្នាក់ ឬក្រុមមួយមានការរីកចម្រើនក្នុងវិជ្ជាជីវៈរបស់ខ្លួន ហើយអាចបំពេញការងារបានគុណផលខ្ពស់។ ការលើកកម្ពស់គុណវុឌ្ឍិ ត្រូវធ្វើឡើងដោយមានការគិតគូរត្រឹមត្រូវ និងមានការសិក្សាច្បាស់លាស់លើជំនាញពាក់ព័ន្ធជាច្រើន ពិសេសគឺ ជំនាញមានស្រាប់ដែលត្រូវអភិវឌ្ឍ និងជំនាញថ្មីដែលត្រូវដាក់បញ្ចូល។

គ្រូបង្រៀនគឺ ជាបុគ្គលិកអប់រំដែលមានភារកិច្ចបង្រៀននៅតាមគ្រឹះស្ថានសិក្សានានាទាំងរដ្ឋ និងឯកជន និងមានអាជ្ញាប័ណ្ណអប់រំត្រឹមត្រូវ[7]។ គ្រូបង្រៀនគឺ ជាមនុស្សម្នាក់ដែលអាចជួយសិស្សឱ្យសម្រេចបាននូវចំណេះដឹង សមត្ថភាព និងសីលធម៌ (Encyclopedia)។ គ្រូបង្រៀន អាចកំណត់ថាជាមនុស្សម្នាក់ដែលផ្ដល់ចំណេះដឹង លើមុខវិជ្ជាជាច្រើន (Dionne Nichols)។ គ្រូបង្រៀនគឺ ជាវិស្វករនៃព្រលឹងដែលអាចអភិវឌ្ឍនូវគំនិត ប្រាជ្ញាស្មារតី និងបំណិនឥរិយាបថរបស់សិស្សានុសិស្សឱ្យមានភាពល្អប្រសើរ។ លើសពីនេះ គ្រូបង្រៀនគឺ ជាអ្នកអប់រំប្រកបដោយគំនិតសុទិដ្ឋិនិយម និងនាំឱ្យសិស្សសម្រេចបាននូវទិសដៅជាក់លាក់មួយ។

ដូច្នេះហើយ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន គឺជាការងារស្នូលក្នុងការអភិវឌ្ឍធនធានមនុស្សដើម្បីសម្រេចបាននូវកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងអាចប្រែក្លាយពីធនធានមនុស្សទៅជាមូលធនមនុស្សនាថ្ងៃអនាគត។

## ២.៣-ទិដ្ឋភាពទូទៅ នៃការបណ្ដុះបណ្ដាលគ្រូ

### ២.៣.១-គោលនយោបាយកំណែទម្រង់វិស័យអប់រំ

ចាប់តាំងពីឆ្នាំ២០១៤ មកដល់បច្ចុប្បន្ន ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់គោលនយោបាយអប់រំបីដំណាក់កាលហើយ។ តាមរយៈកំណែទម្រង់នេះហើយ ដែលធ្វើឱ្យការអប់រំនៅកម្ពុជាមានលក្ខណៈល្អប្រសើរជាងមុន ពិសេសការកែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅឆ្នាំសិក្សា២០១៤-២០១៥ ដែលមានការចូលរួមពីអង្គភាពប្រឆាំងអំពើពុករលួយ ACU ធ្វើឱ្យមានការសាទរពីសំណាក់អាណាព្យាបាល មជ្ឈដ្ឋានជាតិ និងអន្តរជាតិយ៉ាងពេញទំហឹង។ តាមរយៈកំណែទម្រង់ និងគោលនយោបាយអប់រំ ក្រសួងមានទិសដៅវែងឆ្ងាយគឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្ដុះបណ្ដាលស្មារតីយុវជនយុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ និងគុណធម៌ខ្ពស់ ព្រមទាំងមាន

[7] យោងតាមអនុក្រឹត្យលេខ ១២៦ អនក្រ.បក ស្ដីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ២០០៨

សុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន[8] ។ ក្នុងដំណាក់កាលទី១ នៃការធ្វើកំណែទម្រង់វិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវគោលនយោបាយកំណែទម្រង់ចំនួន៨ចំណុចរួមមាន៖ (១)ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការអប់រំ (២) ការពង្រឹងការគ្រប់គ្រងបុគ្គលិក (៣) ការពង្រឹងការប្រឡងគ្រប់ប្រភេទ (៤) ការកែទម្រង់ឧត្តមសិក្សា (៥) ការអភិវឌ្ឍសម្រាប់យុវជននូវជំនាញបច្ចេកទេស និងជំនាញទន់ (៦) ការអនុវត្តន៍ស៊ីជម្រៅលើកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៧) ការកែទម្រង់ការងារអប់រំកាយ និងកីឡា (៨) ការបង្កើតធនាគារខួរក្បាលវិស័យអប់រំ។ បន្ទាប់មកនៅក្នុងឆ្នាំ ២០១៩ដដែល ក្រសួងក៏បានធ្វើកំណែទម្រង់បន្ត ដោយបន្ថែមចំណុចខ្វះខាតមួយចំនួនលើកំណែទម្រង់ចាស់ និងផ្តោតសំខាន់ទៅលើគ្រូបង្រៀន សំដៅធ្វើយ៉ាងណាឱ្យគ្រូដែលជាមន្ត្រីអប់រំនៅជិតជាប់នឹងសិស្សជាងគេនោះ មានសមត្ថភាពអាចកែប្រែមុខមាត់វិស័យអប់រំតាមរយៈការលើកកម្ពស់គុណភាពសិក្សារបស់សិស្សទាំងសាលារដ្ឋ និងឯកជនតាមរយៈការបង្កើនអាទិភាពនៃកម្មវិធីកំណែទម្រង់វិស័យអប់រំពីចំនួន៨ចំណុចទៅដល់១៥ចំណុចរួមមាន៖(១) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (២) ការពង្រាយគ្រូបង្រៀន (៣) កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន (៤) ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន (៥) ការពង្រឹងការងារអធិការកិច្ច (៦) វង្វាយតម្លៃលទ្ធផលសិក្សា (៧)កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ (៨) កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល (៩) ការកសាងអគារសិក្សា និងការជួសជុល (១០) ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា (១១) ការលើកកម្ពស់វិស័យអប់រំ (១២) ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន (១៣) ការអប់រំបច្ចេកទេស (១៤) ការបង្កើតសាលារៀនជំនាន់ថ្មី (១៥) ការរៀបចំគន្លងអាជីព និងបណ្តុះបណ្តាលនាយកសាលា[9]។ នៅក្នុងចំណុចទី២ ទី៣ ទី៤ និងទី៥ សុទ្ធតែគិតជាអាទិភាពលើការពង្រឹងសមត្ថភាពគ្រូ។

នៅក្នុងដំណាក់កាលចុងក្រោយនៃការកែទម្រង់នេះ ក្រសួងបាននិងកំពុងផ្តោតទៅលើសរសរស្តម្ភចំនួន៥ ក្នុងនោះដែរសរសរស្តម្ភទី១ ផ្តោតលើការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន នេះសបញ្ជាក់ថាក្រសួងបានយកចិត្តទុកដាក់ជាសំខាន់លើការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀន តាំងពីការពង្រាយគ្រូ ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ការកែទម្រង់មជ្ឈមណ្ឌលបណ្តុះ បណ្តាលគ្រូ ការពង្រឹងការងារអធិការកិច្ច ការរៀបចំគន្លងអាជីពគ្រូ និងការបណ្តុះបណ្តាលនាយកសាលាជាដើមគឺ សុទ្ធសឹងតែផ្តោតសំខាន់ទៅលើគ្រូបង្រៀន

8 ក្រសួងអប់រំ យុវជន និងកីឡា-យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ (២០១៨-២០២៣) ២០១៨ ទំព័រទី១

9 បទបង្ហាញស្តីពីសញ្ញាណគោលនយោបាយ និងកំណែទម្រង់អប់រំ យុវជន និងកីឡា ២០១៩ ស្លាយទី ១០

ព្រោះក្រសួងយល់ថាការកែទម្រង់គ្រូបង្រៀន អាចធ្វើឱ្យមានការប្រែប្រួលលើគុណភាពសិក្សារបស់សិស្ស ដែលបំពេញបាននូវសេចក្ដីត្រូវការរបស់សហគមន៍ ក៏ដូចជាសង្គម និងទីផ្សារការងារក្នុងតំបន់ និងសកលលោក។ មិនត្រឹមតែប៉ុណ្ណោះ ដើម្បីពង្រឹងសមត្ថភាពគ្រូ ក្រសួងក៏បានធ្វើការងារជាច្រើនផ្សេងៗទៀតរួមជាមួយនឹងភាគីពាក់ព័ន្ធទាំងអស់ ដោយបានដាក់ចេញនូវផែនការយុទ្ធសាស្រ្ត និងផែនការសកម្មភាពដើម្បីស្វែងរកនូវវិធីសាស្រ្តបង្រៀនល្អៗធៀបនឹងស្តង់ដារវិធីសាស្រ្តក្នុងតំបន់ ដើម្បីឱ្យកម្ពុជាអាចប្រជែងបាននូវសក្ដានុពលការងារដូចបណ្ដាប្រទេសក្នុងអាស៊ី និងពិភពលោកផងដែរ។

ផ្អែកតាមគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ និងផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៥ ដែលទទួលបានការយល់ព្រមពីក្រសួងអប់រំ យុវជន និងកីឡាលើកឡើងពីការលើកកម្ពស់គុណភាពគ្រូបង្រៀនដោយផ្សាភ្ជាប់នឹងការបង្កើនប្រាក់ចំណូល និងឋានៈក្នុងសង្គមរបស់គ្រូបង្រៀន។ ការកែទម្រង់នេះទទួលបានផលនៅពេលដែលសេវាកម្មបង្រៀនទាំងមូល ជាកម្មវត្ថុដើម្បីកសាងបទបញ្ញត្តិថ្មីៗសំដៅជួយដល់ការដឹកនាំលក្ខខណ្ឌនានារបស់គ្រូបង្រៀន។ ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀនក្នុងសសរស្តម្ភទី១ បានលើកឡើងគោលបំណង៧ចំណុចៈ

### ក. ទាក់ទាញអ្នកមានសមត្ថភាពចូលធ្វើគ្រូ

ដើម្បីទាក់ទាញអ្នកមានសមត្ថភាពឱ្យចូលធ្វើគ្រូ ក្រសួងបានរៀបចំការងារជាច្រើន ដូចជា ផ្តល់ផលប្រយោជន៍សង្គម និងហិរញ្ញវត្ថុ ដោយតម្លើងប្រាក់បៀវត្ស និងផលប្រយោជន៍សង្គម និងហិរញ្ញវត្ថុដទៃទៀត។ បើកទូលាយលើការជ្រើសរើសគ្រូ (អនុញ្ញាអ្នកមានសញ្ញាបត្របរិញ្ញាបត្រពីគ្រឹះស្ថានរដ្ឋ និងឯកជនទទួលបានអាជ្ញាប័ណ្ណឯអប់រំ) និងផ្តល់ការបំប៉នដល់គ្រូបង្រៀន ១២+២ ដើម្បីក្លាយជាគ្រូកម្រិតបរិញ្ញាបត្រ ព្រមទាំងរឹតបន្តឹងការជ្រើសរើសចូលបណ្តុះបណ្តាល (ប្រកួតប្រជែងចំណាត់ថ្នាក់ជាតិ លែងធ្វើចំណាត់ថ្នាកតាមខេត្ត)។ ពិសេសបេក្ខជនទទួលបាននិទ្ទេស A,B,C ក្នុងការប្រឡងសញ្ញាបត្រថ្នាក់ទី ១២ ត្រូវជាប់ជាស្វ័យប្រវត្តិ និងកែលម្អការប្រឡងចូលធ្វើគ្រូ ១).ធានាការប្រឡងឱ្យអនុវត្តតាមច្បាប់ យុត្តិធម៌ តម្លាភាព និងគណនេយ្យភាព ២).ប្រឡងសរសេរ ៣).សម្ភាសន៍ផ្ទាល់មាត់បេក្ខជនដែលបានជ្រើសរើស ៤).កែប្រែគោលការណ៍កំណត់អាយុ និង ៥).តាមដានអំឡុងពេលបណ្តុះបណ្តាល។

### ខ. ការបណ្តុះបណ្តាលគ្រូបង្រៀន

ក្រសួងបានធ្វើការកែទម្រង់កម្មវិធីបណ្តុហបណ្តាលគ្រូបង្រៀនគ្រប់កម្រិត រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរូបមន្ត ១២+២ (បរិញ្ញាបត្រអប់រំ) សម្រាប់សិស្ស

ថ្នាក់ទី ១២ ដែលជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដោយផ្តោតលើចិត្តគរុកោសល្យ ICT វិធីសាស្ត្របង្រៀន ភាសាបរទេស គណិតវិទ្យា និងវិទ្យាសាស្ត្រ។ ម៉្យាងវិញទៀត រៀបចំកម្មវិធីបណ្តុះបណ្តាលបរិញ្ញាបត្រជាន់ខ្ពស់បូក១ ចំពោះអ្នកមានបរិញ្ញាបត្រជាន់ខ្ពស់ឱ្យក្លាយជាគ្រូបង្រៀនវិទ្យាល័យ នៅវិទ្យាស្ថានជាតិអប់រំ ប៉ុន្តែការងារនេះមិនទាន់មានឃើញលេចេញជារូបរាងនៅឡើយទេ។ លើសពីនេះទៅទៀត ក្រសួងបានអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូផ្អែកតាមស្តង់ដាររដោយសាកល្បងតាមរូបមន្ត ១២+៤ ហៅថាបរិញ្ញាបត្រអប់រំ នៅមជ្ឈមណ្ឌលភូមិភាគចំនួនពីរគឺ នៅភ្នំពេញ និងខេត្តបាត់ដំបង ព្រមទាំងបង្កើនប្រសិទ្ធភាពកម្មសិក្សារបស់គ្រូបង្រៀនមុនពេលតាំងស៊ប់ក្នុងក្របខណ្ឌផងដែរ។

**គ. ការគ្រប់គ្រងគ្រូបង្រៀន**

ការធ្វើទំនើបកម្មផែនការតម្រូវការនិងផ្គត់ផ្គង់គ្រូបបង្រៀន ដោយបញ្ចូលទិន្នន័យពីគ្រប់ប្រព័ន្ធ (EMIS, HRMIS,HEMIS,NFEMIS,FMIS) និងការពង្រឹងការប្រើប្រាស់គ្រូបង្រៀន ផ្អែកតាមនិយាម និងគោលការណ៍ប្រើប្រាស់បុគ្គលិកដើម្បីកែលម្អការអនុវត្តការពង្រាយគ្រូបង្រៀន សំដៅធ្វើយ៉ាងណាឱ្យមានការគ្រប់គ្រងលើគ្រូបង្រៀនបានល្អប្រសើរ។ ជាងនេះទៀត ក្រសួងបានលើកកម្ពស់ដំណើរការ និងនីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនមានស្នាដៃល្អសម្រាប់ធានានិរន្តភាពគ្រឹះស្ថានសិក្សា ដោយមានការធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងបើកឱ្យមានការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្ត (ការជ្រើសរើស ការផ្តល់រង្វាន់ ការដាកពិន័យ ការផ្ទេរ ការវាយតម្លៃ វេទិការសាធារណៈ ប្រជុំសម្លេងសិស្ស ការវាយតម្លៃសេវាមូលដ្ឋាន ការបង្រៀនបំណិនជីវិត...)។ ការបណ្តុះវប្បធម៌រៀនពេញមួយជីវិត ដោយចែករំលែកបទពិសោធន៍ជាមួយបណ្តាញក្រុមអ្នកអប់រំ និងបង្កើនគុណវុឌ្ឍិគ្រូបង្រៀនឱ្យទទួលបានសញ្ញាបត្របរិញ្ញាបត្រ តាមរយៈកម្មវិធី១ខែកន្លះបីដងត្រូវបានអនុវត្តដើម្បីបង្កើនសមត្ថភាពគ្រូបង្រៀន។

**ឃ. ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន**

ក្រសួងបានអភិវឌ្ឍ និងអនុវត្តកម្មវិធីវិក្រឹតការគ្រូបង្រៀន (ពង្រឹងចំណេះដឹងភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសម្រាប់គ្រូបង្រៀននៅថ្នាក់ទី ៩ និងថ្នាក់ទី១២ និងបង្កើតប្រព័ន្ធវិក្រិតការរៀបរយ ដោយអនុវត្តការងារវិក្រិតការៈ ១)នៅនឹងកន្លែង ២)មិនរៀបរយតាមការចាំបាច់នៃវិស័យអប់រំ ៣).រៀបរយដែលមានប្រព័ន្ធកម្មវិធីត្រឹមត្រូវ។ ចំពោះគ្រូឧទ្ទេសវិញ ត្រូវបានបង្កើនគុណវុឌ្ឍិនៃការបណ្តុះបណ្តាលឱ្យឈានដល់កម្រិតយ៉ាងទាបព័ន្ធ)ផងដែរ។

ម៉្យាងវិញទៀត ក្រសួងបានអនុវត្តអាហារូបករណ៍ និងកម្មវិធីវិក្រឹតការពន្លឿនសម្រាប់ឱ្យគ្រូបង្រៀនទទួលបានបរិញ្ញាបត្រ/បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ១០០០កន្លែងក្នុងមួយឆ្នាំបង្កើតប្រព័ន្ធក្រេឌីត ដើម្បីរៀបចំឱ្យមានការឯកភាពគ្នាមួយលើរាល់ប្រភេទនៃវគ្គវិក្រឹតការ សម្រាប់ទទួលបាននូវការលើកកម្ពស់គុណវុឌ្ឍិ និងផលប្រយោជន៍បន្ថែម(បៀវត្ស ដំឡើងឋានៈ) ពង្រឹងប្រព័ន្ធគាំទ្រគ្រូបង្រៀននៅនឹងកន្លែង ដើម្បីគាំទ្រគ្រូនៅតាមសាលារៀន ក្នុងគោលដៅពង្រឹងចំណេះដឹងមុខវិជ្ជាឯកទេស និងគរុកោសល្យ ព្រមទាំងបង្កើតកម្មវិធីសម្រាប់គ្រូឧទ្ទេសវគ្គវិក្រឹតការនៃស្តង់ដារសម្រាប់សាលាគរុកោសល្យក្នុងការចុះជួយបំប៉នសមត្ថភាពគ្រូបង្រៀននៅនឹងកន្លែង។

**ង. លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន**

ក្រសួងក៏បានជួយសម្រួល និងលើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀនតាមរយៈការផ្តល់បៀវត្ស លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ អត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀននៅតំបន់ដាច់ស្រយាល និងជួបការលំបាក (បៀវត្ស ប្រាក់វិភាជន៍គ្រួសារ សិក្សានិងធានារ៉ាប់រងសុខភាព អាយុជីវិត កម្មវិធីកម្ចី/ឥណទាន ឧបត្ថម្ភធនធានសម្រាប់សង់ផ្ទះជូនគ្រូបង្រៀន ប្រាប់បន្ថែមម៉ោង ប្រាក់ឧបត្ថម្ភគ្រូបង្រៀន រួមទាំងរបបសោធននិវត្តន៍...)។ ក្រៅពីនេះ ក្រសួងក៏បាន ផ្តល់ឯកសារ សម្ភារសម្រាប់ការបង្រៀន និងរៀន និងឯកសារសម្រាប់ធ្វើការស្រាវជ្រាវ ផ្តល់សម្ភាររូបវ័ន្តបន្ថែម កែលម្អលក្ខខណ្ឌធ្វើការងារនៅសាលារៀនដាច់ស្រយាល និងសាលារៀនជួបការលំបាក ដូចជាបង្គន់អនាម័យ និងផ្ទះគ្រូបង្រៀនជាដើម ហើយ ក៏ទទួលស្គាល់ និងជូនរង្វាន់ដល់គ្រូបង្រៀនដែលមានស្នាដៃល្អ (រក្សាទុកក្នុងប្រព័ន្ធ)។ ផ្តល់ពានរង្វាន់គ្រូឆ្នើម(ស្នាដៃ និងបទពិសោធន៍ល្អ) ដើម្បីចែករំលែកនូវបទពិសោធន៍តាមមុខវិជ្ជា និងរៀបចំគន្លងអាជីពគ្រូបង្រៀន ។ លើសពីនេះ ក៏មានសកម្មភាពដទៃទៀតដូចជា ការរៀបចំបណ្តាញគាំទ្រជាប្រចាំជាក្លឹបសិក្សាសមាគមន៍វិជ្ជាជីវៈតាមមុខវិជ្ជាឯកទេស សម្រាប់ជួយផ្នែកបច្ចេកទេសតាមមុខវិជ្ជា ធ្វើការស្រាវជ្រាវ ដឹកនាំសន្និសីទវិជ្ជាជីវៈ ជួយបោះពុម្ពស្នាដៃ មេរៀនពិសោធន៍ល្អៗ និងបង្កើតក្រុមបច្ចេកទេសក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនដែលបានទទួលស្គាល់សម្រាប់ចុះជួយតាមមុខវិជ្ជា និងប្រជុំក្រុមបច្ចេកទេសតាមមុខវិជ្ជាឱ្យបានទៀងទាត់។

**ច. ពង្រឹងភាពជាអ្នកដឹកនាំក្នុងសាលារៀន**

ការដឹកនាំសាលារៀនមានសារៈសំខាន់ណាស់ ដើម្បីធ្វើយ៉ាងណាឱ្យការអប់រំទទួលបាននូវគុណភាព និងអាចឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស សហគមន៍ និងសង្គមជាតិ។ ដូចនេះហើយ ក្រសួងបានរៀបចំជាស្តង់ដាររបស់នាយកសាលារៀនដោយមានសៀវភៅណែ

នាំស្តីពីការគ្រប់គ្រងសាលា បណ្តុះបណ្តាលនាយកសាលាតាមស្តង់ដារដោយផ្តល់អាទិភាពលើ នារី និងបង្កើតក្រុមប្រឹក្សា សមាគមន៍នាយកសាលា និងយន្តការពង្រឹងការគាំទ្រនាយកសាលាជាដើម។ ជាងនេះទៀត ក្រសួងបានការពារ និងលើកកម្ពស់សិទ្ធិគ្រូបង្រៀន ដោយធានាថាគ្រូបង្រៀនទាំងអស់ទទួលបាននូវភាពយុត្តិធម៌ដូចគ្នា តាមរយៈការគ្រប់គ្រងសាលារៀនដែលមានតម្លាភាព ព្រមទាំងកែលម្អលក្ខខណ្ឌជ្រើសរើស បណ្តុះបណ្តាល ការបំពេញការងារ និងផលប្រយោជន៍គ្រូខុទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាផងដែរ។

**ឆ. ពង្រឹងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ**

ដើម្បីធ្វើឱ្យការងារទទួលបានប្រសិទ្ធផលខ្ពស់ ក្រសួងបានធ្វើការកែលម្អទិន្នន័យក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានគ្រូបង្រៀន រៀបចំយន្តការពិនិត្យតាមដាន វាយតម្លៃ ដោយផ្តោតលើស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន និយាមប្រើប្រាស់ លក្ខណៈសម្បត្តិ និងគន្លងអាជីពគ្រូបង្រៀននៅនឹងកន្លែងធ្វើការតាមរយៈការធ្វើអធិការកិច្ច និងការផ្តល់សិទ្ធិពេញលេញដល់នាយកសាលាក្នុងការផ្តល់មតិត្រឡប់ដល់គ្រូបង្រៀន ហើយការងារសំខាន់មួយទៀតគឺ ពង្រីកវិសាលភាព និងសមត្ថភាពនៃការងារអធិការកិច្ចដោយប្រមូលព័ត៌មានត្រឡប់ពីគ្រូ ដើម្បីធ្វើការកែលម្អគោលនយោបាយពាក់ព័ន្ធនឹងវិស័យអប់រំ ដែលមានការរៀបចំជាការអង្កេតជារៀងរាល់ឆ្នាំសំដៅតាមដានទស្សនៈរបស់គ្រូ លក្ខខណ្ឌធ្វើការងារ និងកម្មវិធីលើកទឹកចិត្តផ្សេងៗ។ ជាមួយគ្នានេះដែរគឺ កំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចចិត្តលើការគ្រប់គ្រង និងអភិវឌ្ឍអង្គភាព[10]។

## ២.៣.២-គោលនយោបាយគ្រូបង្រៀន

គោលនយោបាយនេះមានចក្ខុវិស័យ កសាងគ្រូបង្រៀនឱ្យមានទាំងចំណេះដឹង ជំនាញ សីលធម៌ និងសមត្ថភាពអនុវត្តវិជ្ជាជីវៈខ្លួនដោយមានការទទួលស្គាល់ពីសង្គម។ ព្រមទាំងមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពសក្តិសិទ្ធិ។

ដើម្បីសម្រេចបានតាមគោលបំណងខាងលើ ក្រសួងមានយុទ្ធសាស្ត្រសំខាន់ៗដូចជា ៖

**(ក) កសាងលិខិតបទដ្ឋានគតិយុត្តនិងយន្តការ** តាមរយៈការត្រួពិនិត្យឡើងវិញ កែលម្អ និងកសាងលិខិតបទដ្ឋានគតិយុត្ត ការកសាងយន្តការចាំបាច់សម្រាប់ផ្សព្វផ្សាយ អនុវត្ត គាំទ្រ ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តគោលនយោបាយ និងតាមរយៈការកសាងផែនការសកម្មភាព

[10] បណ្ឌិត ហង់ជួន ណារ៉ុន-សន្និបាតអប់រំ(ចក្ខុវិស័យកំណែទម្រង់វិស័យអប់រំ) ២០១៥ ស្លាយ ១៩-២៩

ជាក់លាក់ និងកម្មវិធីលម្អិតដើម្បីអនុវត្តគោលនយោបាយ (ខ) **ទាក់ទាញអ្នកមានសមត្ថភាពឱ្យប្រកបវិជ្ជាជីវៈជាគ្រូបង្រៀន** តាមរយៈការលើកកម្ពស់ជីវភាព តម្លៃវិជ្ជាជីវៈ សេចក្តីថ្លៃថ្នូរ និងការយកចិត្តទុកដាក់ពីសង្គម ការលើកកម្ពស់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន ការកំណត់លក្ខណៈវិនិច្ឆ័យ និងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ការជ្រើសរើស ការធ្វើទំនើបកម្មស្តង់ដារនៃកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិ និងការប្រកួតប្រជែងក្នុងតំបន់ និងសកលលោក (គ) **កំណត់ស្តង់ដារប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន** តាមរយៈការធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន ការបង្កើនប្រសិទ្ធភាពកម្មសិក្សាមុនពេលតាំងស៊ប់ក្នុងក្របខណ្ឌ និងការកំណត់កម្រិតស្វ័យភាពរបស់គ្រូបង្រៀន **(ឃ) អភិវឌ្ឍគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន** តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ការប្រែក្លាយសាលាគរុកោសល្យឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ការបង្កើនគុណវុឌ្ឍិ និងបទពិសោធបុគ្គលិកអប់រំនៅមជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន និងពង្រឹងមុខងាររបស់មជ្ឈមណ្ឌលអភិវឌ្ឍគ្រូបង្រៀន ដើម្បីបន្តអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន (ង) **ធ្វើសនិទានកម្មគ្រូបង្រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការរបស់គ្រឹះស្ថានសិក្សា** តាមរយៈការធ្វើទំនើបកម្មផែនការតម្រូវការ និងផ្គត់ផ្គង់គ្រូបង្រៀនសម្រាប់ការបណ្តុះបណ្តាលមុនពេលបម្រើការងារ ការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់គ្រូបង្រៀនតាមនិយាម និងតាមគោលការណ៍ ការលើកកម្ពស់ការគ្រប់គ្រង និងរៀបចំក្របខណ្ឌគ្រូបង្រៀន ការលើកកម្ពស់ដំណើរការ និងនីតិវិធីនៃការជ្រើសរើស និងរក្សាទុកគ្រូបង្រៀនដែលមានស្នាដៃល្អ សម្រាប់ធានានិរន្តរភាពគ្រឹះស្ថានសិក្សា ការធ្វើប្រតិភូកម្មការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនទៅថ្នាក់ក្រោមជាតិតាមគោលការណ៍កំណត់ និងការលើកកម្ពស់ការចូលរួមរបស់គណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកពាក់ព័ន្ធក្នុងការបង្កើនសមិទ្ធផលសិក្សារបស់សិស្ស **(ច) ការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលកំពុងបម្រើការងារ** តាមរយៈការបណ្តុះវប្បធម៌ឱ្យចេះរៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹង និងបទពិសោធជាមួយ បណ្តាញក្រុមអ្នកអប់រំ ការរៀបចំយន្តការប្រកបដោយប្រសិទ្ធភាព ដើម្បីគាំទ្រគ្រូបង្រៀននៅនឹងកន្លែងធ្វើការ និងការរៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការ និងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈ **(ឆ) ការលើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀន** តាមរយៈការលើកកម្ពស់លក្ខខណ្ឌធ្វើការងារ និងរស់នៅរបស់គ្រូបង្រៀនដោយការផ្តល់បៀវត្ស លាភការ សុខុមាលភាពសង្គម អត្ថប្រយោជន៍ទូទៅ និងអត្ថប្រយោជន៍ពេលចូលនិវត្តន៍ ជាពិសេសអ្នកគ្រូ និងគ្រូបង្រៀនបម្រើការនៅតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ការទទួលស្គាល់ និងជូនរង្វាន់ចំពោះគ្រូបង្រៀនដែល

មានស្នាដៃល្អ និងការលើកកម្ពស់ភាពរីកចម្រើននៃអាជីព ស្វ័យភាព និងការសម្រេចចិត្តក្នុងវិជ្ជាជីវៈរបស់គ្រូបង្រៀនដែលកំណត់ក្នុងច្បាប់សំដៅកែលម្អលទ្ធផលសិក្សារបស់សិស្ស (ជ) **ការពង្រឹងប្រសិទ្ធភាព ភាពជាអ្នកដឹកនាំសាលារៀន** តាមរយៈការពង្រឹងយន្តការភាពជាអ្នកដឹកនាំសាលារៀនឱ្យមានប្រសិទ្ធភាព ការធានាសិទ្ធិរបស់គ្រូបង្រៀនស្របតាមច្បាប់ស្តីពីការអប់រំ ការធ្វើឱ្យប្រសើរឡើងលក្ខខណ្ឌតម្រូវខាងវិជ្ជាជីវៈសម្រាប់ជ្រើសរើស បណ្តុះបណ្តាល បំពេញការងារ និងផលប្រយោជន៍សម្រាប់គ្រូឧទ្ទេស និងគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ការកំណត់ និងអនុវត្តវិធានការរដ្ឋបាលដល់គ្រូបង្រៀន គ្រូឧទ្ទេស និងគណៈគ្រប់គ្រងនៃគ្រឹះស្ថានសិក្សាសាធារណៈសំដៅធានាការអនុវត្តគោលការណ៍ និងបំពេញលក្ខខណ្ឌតម្រូវនៃច្បាប់ (ឈ) **ការពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រូបង្រៀន**តាមរយៈការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀន ការបង្កើត និងប្រើប្រាស់យន្តការពិនិត្យតាមដាន និងវាយតម្លៃដើម្បីកែលម្អលទ្ធផលបំពេញការងាររបស់គ្រូបង្រៀន ការបង្កើនប្រសិទ្ធភាព ការប្រើប្រាស់លទ្ធផលវាយតម្លៃការប្រតិបត្តិរបស់គ្រូបង្រៀនដើម្បីអភិវឌ្ឍសមិទ្ធិអប់រំ និងការកំណត់សិទ្ធិគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ក្នុងការធ្វើសេចក្តីសម្រេចលើការគ្រប់ គ្រង និងអភិវឌ្ឍអង្គភាព[11] ។

### ២.៣.៣-ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន

#### ក. ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា

ដើម្បីឱ្យការពង្រឹងគុណភាពអប់រំទទួលបានជោគជ័យ គ្រូគឺកត្តាសំខាន់បំផុតដែលអាចបង្កើតធនធានមនុស្សសម្រាប់ចូលរួមក្នុងវិស័យនានានៅពេលបច្ចុប្បន្ន និងនៅពេលអនាគត។ ការរៀបចំធ្វើឱ្យមានភាពប្រសើរឡើងនៅក្នុងវិស័យអប់រំ ត្រូវបានគិតគូរយ៉ាងហ្មត់ចត់ពីគ្រប់ទិដ្ឋភាពទាំងអស់ ដោយក្នុងនោះ លិខិតបទដ្ឋានផ្សេងៗត្រូវបានតាក់តែងឡើង ដើម្បីបង្ហាញផ្លូវក្នុងការអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធិភាព។ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ត្រូវបានបង្កើតឡើង សម្រាប់ជាសូចនាករវាស់ស្ទង់លើ លក្ខណៈសម្បត្តិទាំងឡាយដែលគ្រូបង្រៀនត្រូវតែមាន។ វាបានផលប្រយោជន៍ជាច្រើនដូចជា ១) កែលម្អការបង្រៀន និងរៀន ២) ផ្តល់ចក្ខុវិស័យសម្រាប់បណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ៣) កែលម្អកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ៤) រៀបចំផែនការអភិវឌ្ឍសាលារៀន ៥)ធ្វើឱ្យគ្រូបង្រៀនមានលទ្ធភាព និងមានឱកាសជាច្រើនក្នុងការស្វែងរកសេវាការងារទាំងក្នុងស្ថាប័នរដ្ឋ និងស្ថាប័នឯកជន ៦)បង្កើនសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនឱ្យមានកម្រិតប្រហាក់ប្រហែលប្រទេសនៅក្នុងតំបន់ និង៧) ផ្តល់មូលដ្ឋាន

[11] ក្រសួងអប់រំ យុវជន និងកីឡា-គោលនយោបាយស្តីពីគ្រូបង្រៀន ២០១៣ ទំព័រទី២-៤

គ្រឹះដើម្បីជំរុញឡើងឋានន្តរស័ក្តិ។ ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀនមានភាពខុសគ្នាពីប្រទេសមួយទៅប្រទេសមួយដែលផ្អែកលើកត្តាជាច្រើនដូចជាកត្តាបច្ចេកវិទ្យា កត្តាសេដ្ឋកិច្ច កត្តាសង្គម និងកត្តាវប្បធម៌ជាដើម។ ដោយឡែក ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅកម្ពុជា បានកំណត់ជាបួនសមាសភាគធំៗគឺ ចំណេះដឹងវិជ្ជាជីវៈ ការប្រតិបត្តិវិជ្ជាជីវៈ ការសិក្សាវិជ្ជាជីវៈ និងសីលធម៌វិជ្ជាជីវៈ។

**១. ចំណេះដឹងវិជ្ជាជីវៈ**

1) ត្រង់នេះមានសារៈសំខាន់ណាស់ ព្រោះត្រូវតែដឹងច្បាស់ពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សាច្បាស់លាស់ និងឥរិយាបថរបស់សិស្សម្នាក់ៗ ហើយក៏យល់ដឹងផងដែរពីប្រភេទគ្រួសារ និងកត្តាផ្សេងៗដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស (យេនឌ័រ ពិការភាព និងក្រុមជនជាតិភាគតិច...) ព្រមទាំងយល់ដឹងពីវិធីដោះស្រាយកត្តាទាំងនេះ។
2) យល់ដឹងពីគោលនយោបាយអប់រំ ជាពិសេសគោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅហើយពេញចិត្តក្នុងការអនុវត្តនៅសាលារៀន។
3) យល់ពីទ្រឹស្តីក្នុងការរៀបចំកិច្ចតែងការបង្រៀន ដូចជាវត្ថុបំណង វិធីសាស្ត្របង្រៀន និងអាច ជ្រើសរើសវិធីវាយតម្លៃលទ្ធផលសិក្សាបានសមស្រប។
4) យល់ពីខ្លឹមសារ កម្មវិធីសិក្សា ហើយមានសមត្ថភាពពន្យល់មេរៀនបានច្បាស់លាស់ និងយល់ពីរបៀបបញ្ច្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយផ្សេងទៀត ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។
5) យល់ពីបរិស្ថានអប់រំក្នុងថ្នាក់រៀន និងក្នុងសហគមន៍ ពិសេសយល់ពីរបៀបរៀនរបស់សិស្ស ភាពខុសគ្នារវាងទេពកោសល្យ ល្បឿន និងរបៀបសិក្សា ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។

**២. ការប្រតិបត្តិវិជ្ជាជីវៈ**

1) គ្រូបង្រៀន ត្រូវរៀបចំកិច្ចតែងការបង្រៀនឱ្យបានច្បាស់លាស់ប្រកបដោយប្រសិទ្ធភាពស្របតាមកម្មវិធីសិក្សាដោយផ្អែកលើសៀវភៅសិស្ស សៀវភៅគ្រូ និងសម្ភារសិក្សាផ្សេងៗទៀត ដែលអាចរកបាន។ ដើម្បីគាំទ្រដល់កិច្ចតែងការបង្រៀន គ្រូបង្រៀនត្រូវរៀបចំសម្ភារបង្រៀន និងរៀនដើម្បីរិះរកមធ្យោបាយសម្រេចបានការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព។

2) គ្រូបង្រៀនក៏ប្រើប្រាស់វិធីវាយតម្លៃលទ្ធផលសិក្សាផ្សេងៗគ្នា ដែលស្របទៅតាមតម្រូវការ និងទេពកោសល្យរបស់សិស្ស ។
3) គ្រូបង្រៀនត្រូវបញ្ជូនព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតា ឬអាណាព្យាបាល អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស។
4) គ្រូបង្រៀនផ្តល់ឱ្យសិស្សគ្រប់រូប នូវបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព និងធ្វើឱ្យមានការប្រឹងប្រែងអស់ពីសមត្ថភាព ហើយលើកទឹកចិត្តសិស្សឱ្យកាន់តែមានការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន។ គ្រូបង្រៀនត្រូវចូលរួមក្នុងការអភិវឌ្ឍសាលារៀន ដើម្បីគាំទ្រការសិក្សា និងសុខុមាលភាពរបស់សិស្ស និងគ្រូបង្រៀនឯទៀត។
5) គ្រូបង្រៀនត្រូវចេះប្រើប្រាស់វិធីបង្រៀនឱ្យសម្បូរបែប ដើម្បីសម្រួលដល់ការសិក្សារបស់សិស្ស និងសម្រេចបានវត្ថុបំណងមេរៀន ។
6) គ្រូបង្រៀនគួរមានសមត្ថភាព ផ្តល់ជាមធ្យោបាយឱ្យស្របទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្ស តាមរយៈការអនុវត្តវិធីបង្រៀនសមស្របសម្បូរបែប ដោយបង្កឱកាសឱ្យសិស្សចូលរួមគិតបានល្អិតល្អន់ និងដោយច្នៃប្រឌិត។
7) គ្រូបង្រៀនត្រូវចេះប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន សារទូរគមនាគមន៍ និងធនធានក្នុងបណ្ណាល័យបើមានលទ្ធភាព ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព។

**៣. ការសិក្សាវិជ្ជាជីវៈ**

1) គ្រូបង្រៀនគឺជាអ្នកលើកទឹកចិត្ត និងជាអ្នកធានាឱ្យសិស្សទទួលបានជោគជ័យ ក្នុងការសិក្សា។ ដូច្នេះ គាត់ត្រូវតែស្វ័យសិក្សា វាយតម្លៃការបង្រៀន ដើម្បីអភិវឌ្ឍខ្លួនឯង និងប្រើប្រាស់ផែនការសម្រាប់ដឹកនាំស្វ័យសិក្សាមុខវិជ្ជាជីវៈជាប្រចាំ ស្របតាមជីវភាពរស់នៅជាក់ស្តែង។
2) គ្រូបង្រៀនត្រូវអភិវឌ្ឍផ្នែកបច្ចេកវិទ្យាព័ត៌មាន សារគមនាគមន៍ និងបំណិនផ្សេងៗសម្រាប់អនុវត្តក្នុងការបង្រៀន ហើយធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងជាមួយអ្នកផ្សេងៗទៀត នៅក្នុងសហគមន៍។
3) គ្រូបង្រៀនត្រូវលើកកម្ពស់កម្រិតសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនតាមរយៈការអាន និងការស្រាវជ្រាវ ប្រភពឯកសារផ្សេងៗ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយក្នុងន័យកែលំអការបង្រៀន និងរៀន ហើយត្រូវមានទំនាក់ទំនងល្អជាមួយគ្រូដទៃទៀតក្នុងការសិក្សាវិជ្ជាជីវៈ។

**៤. សីលធម៌វិជ្ជាជីវៈ**

សីលធម៌វិជ្ជាជីវៈ គឺពាក់ព័ន្ធទៅនឹងគ្រប់ទិដ្ឋភាពទាំងអស់ក្នុងវិជ្ជាជីវៈគ្រូបង្រៀន ដែល

ជារួមមានការប្តេជ្ញាចិត្តបង្រៀនសិស្ស ប្រើប្រាស់មនសិការវិជ្ជាជីវៈប្រកបដោយគតិបណ្ឌិត និងមានចំណេះដឹងគ្រប់គ្រាន់តាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងច្បាប់ស្តីពីការអប់រំ។

1) គ្រូបង្រៀនត្រូវគោរពពេលវេលាតាមភារកិច្ច មានវត្តមានជាប្រចាំនៅក្នុងសាលារៀន មានការស្លៀកពាក់សមរម្យ និងមានឥរិយាបថថ្លៃថ្នូរ។ គាត់គួរតែចូលរួមក្នុងគ្រប់សកម្មភាពទាំងក្នុង និងក្រៅម៉ោងទាំងអស់របស់សាលារៀនឱ្យបានសមស្របតាមករណីដែលអាចធ្វើបាន។
2) គ្រូបង្រៀនមានប្រសិទ្ធភាពគឺមិនរើសអើងសិស្ស ទោះនៅក្នុងកាលៈទេសៈណាក៏ដោយ ដូចជាបញ្ហាយេនឌ័រ ជនជាតិភាគតិច ពិការភាព ភាពក្រីក្រ និងត្រូវចេះថៃទាំសិស្សផ្តល់លទ្ធភាព ឱ្យសិស្សប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាព ហើយយកចិត្តទុកដាក់ដល់សិស្សឱ្យបានស្មើៗគ្នា រួចបង្ហាញពីភាពយុត្តិធម៌ក្នុងការត្រួតពិនិត្យលទ្ធផលសិក្សា។
3) នៅពេលទាក់ទងជាមួយសិស្ស គ្រូបង្រៀនត្រូវមានការគោរពសិស្សដោយមិននិយាយមើលងាយ ឬដាក់ទណ្ឌកម្មពួកគេតាមរបៀបហឹង្សាឡើយ។
4) គ្រូបង្រៀនប្រកាន់ចរិយាសម្បត្តិមានសុជីវធម៌ និងអាកប្បកិរិយាថ្លៃថ្នូរ សម្រាប់ធ្វើការសហការជាមួយសហការី និងមាតាបិតាសិស្ស ដើម្បីផលប្រយោជន៍សិស្ស ផ្តល់ជាគំរូដល់សិស្សក្នុងការរស់នៅ និងរៀនសូត្របានល្អ ពិសេសចេះលើកកម្ពស់ស្មារតីសិស្សឱ្យរឹងប៉ឹង និងវិជ្ជមានហើយបង្កើតស្មារតីលះបង់ និងការរួមចំណែកចំពោះសហគមន៍ទាំងមូល[12]។

### ខ. ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀននៅអាស៊ីអាគ្នេយ៍

បើសង្កេតមើលការកំណត់ពីស្តង់ដារនៃគ្រូបង្រៀននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដែលសិក្សាស្រាវជ្រាវក្នុងចំណោម ១១ ប្រទេសវិញ គ្រូបង្រៀនទាំងអស់ត្រូវមានលក្ខណៈសម្បត្តិដូចជា៖

**១. ចំណេះដឹងគរុកោសល្យ** ( Pedagogical Skills )

គ្រូបង្រៀនត្រូវមានជំនាញ ដើម្បីជួយសិស្សឱ្យចេះធ្វើការពិចារណាបានស៊ីជម្រៅចេះបង្កើតថ្មី និងចេះដោះស្រាយបញ្ហាដោយខ្លួនឯង មិនមែនត្រឹមតែការប្រើប្រាស់នូវការបង្រៀនតាមលក្ខណៈប្រពៃណីដែលគ្រូម្នាក់ៗមានស្រាប់ ឬទេពកោសល្យពីធម្មជាតិឡើយ ប៉ុន្តែជាចំណេះដឹង និងជំនាញដែលអាចឆ្លើយតបបានសមស្របនឹងសេចក្តីត្រូវការរបស់សិស្ស និងធ្វើឱ្យសិស្សដែលមានភាពផ្សេងៗគ្នាទទួលបាននូវគោលដៅសិក្សាស្មើៗគ្នានិងអត្រាខ្ពស់បំផុត។ ជំនាញនេះគ្រូម្នាក់ត្រូវគិតលើចំណុចខ្លះដូចខាងក្រោម៖

---

[12] លោក ព្រឹង មរកត-ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន ២០១៩ ស្លាយ ៣៥, ៤៦,៤៧,៦០,៦៦ និង៦៧

- អប់រំដោយគិតពីគោលដៅអប់រំរយៈពេលវែងរបស់រដ្ឋ វត្ថុបំណង រួមផ្សំនឹងកម្មវិធីសិក្សារបស់សាលា ឬក្រសួង។
- កំណត់នូវយុទ្ធសាស្ត្របែបនវានុវត្តន៍ដែលសមស្របនឹងវត្ថុបំណងមេរៀន សមត្ថភាព ចំណង់ចំណូលចិត្ត និងបែបផែននៃការរៀនរបស់សិស្សនីមួយៗ។
- ប្រើប្រាស់នូវធនធាន និងបច្ចេកវិទ្យាសមរម្យធៀបនឹងវត្ថុបំណងមេរៀន សមត្ថភាព និង ចំណង់ចំណូលចិត្តសិស្ស
- ផ្តល់នូវការអនុវត្តជាក់ស្តែង មេរៀនមានទាន់សម័យកាល មធ្យមសមស្របនឹងសមត្ថភាពសិស្ស និងពេលវេលា។
- បង្កើតវត្ថុបំណងមេរៀន និងលទ្ធផលរំពឹងទុកឱ្យមានភាពស៊ីចង្វាក់ទៅនឹងស្ថានភាពជីវិតរស់នៅជាក់ស្តែងរបស់សិស្ស។
- ផ្តល់ឱកាសឱ្យសិស្សក្នុងការសិក្សាទាំងក្នុង និងក្រៅម៉ោងពីបរិបទនៃការអប់រំ

របាយការណ៍នៃសិក្ខាសាលាមួយបានបង្ហាញថា ជំនាញគរុកោសល្យត្រូវការយល់ដឹងពីមុខវិជ្ជាមេរៀនឯកទេស ស្គាល់សិស្ស របៀបរៀនរបស់សិស្ស រៀបចំវិធីសាស្ត្រ និងប្លង់មេរៀនដែលមានប្រសិទ្ធភាពក្នុងការបង្រៀនដោយផ្អែកលើសៀវភៅសិក្សាគោល និងសម្ភារឧបទ្ទេសផ្សេងៗ។

**២. ជំនាញវាយតម្លៃសិស្ស** (Student Assessment Skills)

ការវាយតម្លៃការយល់ដឹងរបស់សិស្សគឺជាកត្តាសំខាន់ណាស់ ព្រោះដើម្បីវាស់ស្ទង់ពីការផ្ទេរចំណេះដឹង និងលទ្ធផលដែលសិស្សទទួលបាន។ ការវាស់ស្ទង់ចំណេះដឹងសិស្សតាមរយៈការប្រើប្រាស់នូវវិធីសាស្ត្រផ្សេងៗជាច្រើន សំដៅស្វែងរមតិយោបល់ត្រឡប់ពីសិស្ស និងធ្វើឱ្យសិស្សមានការខិតខំប្រឹងប្រែងក្នុងការសិក្សាផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ការវាយតម្លៃនេះជួយឱ្យគ្រូបង្រៀនអាចយល់ដឹងពីប្រសិទ្ធភាពនៃការបង្រៀន និងអាចវាស់ពីកម្រិតសមត្ថភាពដែលសិស្សផ្សេងៗទទួលបាន មានភាពស្មើគ្នាឬអត់។ ការវាយតម្លៃនេះមានទិសដៅដូចជាៈ ១) ត្រួតពិនិត្យការយល់ដឹង ដំណើរការ និងផលសម្រេចដោយប្រើប្រាស់នូវវិធីសាស្ត្រផ្សេងៗជាច្រើន ២) ផ្តល់នូវមតិត្រឡប់ដល់សិស្ស និងទទួលសំណូមពរពីសិស្សក្នុងការកែលម្អ និងអភិវឌ្ឍចំណេះដឹង និង៣) ប្រើប្រាស់លទ្ធផលនៃការវាយតម្លៃដើម្បីកំណត់ពីការសម្រេចបានរបស់វត្ថុបំណងមេរៀន។

**៣. ការគ្រប់គ្រងថ្នាក់រៀនមានប្រសិទ្ធភាព** (Skills Essential to Effectively Manage a Classroom)

វាជាសមត្ថភាពដែលគ្រូមានបច្ចេកទេសបកស្រាយខ្លឹមសារមេរៀន បានដោយមានភាពរលូន និងគ្មានការរំខានពីអាកប្បកិរិយារបស់សិស្ស។ ការងារនេះជាទិដ្ឋភាពដ៏លំបាកមួយ ហើយវិធីសាស្ត្រក្នុងការគ្រប់គ្រងថ្នាក់រៀនឱ្យបានល្អនេះ នៅតែជាបញ្ហាពិភាក្សាក្នុងចំណោមលោកគ្រូ អ្នកគ្រូ ដែលពេលខ្លះអាចឱ្យគ្រូបោះបង់ការបង្រៀនក៏មានដែរ។ សំខាន់បំផុត ការគ្រប់គ្រងថ្នាក់រៀនត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធខ្លាំងទៅនឹងការលើកទឹកចិត្ត វិន័យ និងការគោរព។ ចំណុចនេះគ្រូត្រូវគិតលើះ

- ចាប់មេរៀនដោយប្រើប្រាស់ពេលវេលាកំណត់សមស្រប
- គ្រប់គ្រងអាកប្បកិរិយារបស់សិស្ស ដើម្បីឱ្យសិស្សមានវិន័យ និងចូលរួមសហការជានិច្ច
- លើកទឹកចិត្តជានិច្ចឱ្យសិស្សមានការចូលរួមបានពីគ្រប់ស្ថានភាពនៃសិស្សបានស្មើៗគ្នា
- បង្កើត និងរក្សាបាននូវពេលវេលាសមស្របតាមជំហាននីមួយៗ និងផ្សាភ្ជាប់នឹងការគោរពវិន័យ ដោយយកចិត្តទុកដាក់លើការគ្រប់គ្រងសិស្ស។
- បង្កើតបរិយាកាសចូលរួមយ៉ាងសកម្មលើការអនុវត្តមេរៀន ដោយការបង្រៀនមានភាពច្បាស់ លាស់ ត្រឹមត្រូវ និងស៊ីជម្រៅ។

**៤. ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ** ( Professional Development Skills )

ដោយការមានការរីកចម្រើនផ្នែកបច្ចេកវិទ្យា និងបច្ចេកទេស គ្រូបង្រៀនចាំបាច់ត្រូវមានការលើកកម្ពស់គុណវុឌ្ឍិបន្ថែម ដើម្បីឱ្យការបង្រៀនមានប្រសិទ្ធភាព និងដើរទាន់សម័យកាល និងតម្រូវការរបស់សិស្ស។ គ្រូបង្រៀនគួរតែបានបំពាក់នូវជំនាញផ្សេងៗសម្បូរបែប ចំណេះដឹងឯកទេស ភាសាបរទេស និងបទពិសោធន៍ជាក់ស្តែងជាដើម ដើម្បីអនុវត្តការងារ ព្រោះសិស្សនៅសតវត្សទី២១នេះត្រូវការចំណេះដឹង ជំនាញ ដែលជាតម្រូវការនៃការវិវត្តសកលភាវូបនីកម្មសេដ្ឋកិច្ចពិភពលោកជាចាំបាច់។ ទាក់ទងនឹងលក្ខណៈសម្បត្តិនេះ គ្រូត្រូវះ

- កំណត់នូវតម្រូវការ និងគម្រោងសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ
- អភិវឌ្ឍជំនាញដើម្បីរៀបចំការងារក្រៅពីការបង្រៀនដែលមានប្រសិទ្ធភាព
- វាយតម្លៃឱ្យបានទៀងទាត់ និងស៊ីជម្រៅលើជំនាញវិជ្ជាជីវៈ និងប្រសិទ្ធភាពនៃការបង្រៀន
- អនុវត្តជំនាញក្នុងការងារគ្រប់គ្រងដោយផ្អែកលើសាលារៀន(School-based Management)
- អនុវត្តការងារស្វ័យសិក្សាដោយខ្លួនឯងលើជំនាញអាជីព

***លក្ខណៈសម្បត្តិពីរយ៉ាងទៀតដែលគេចាត់ទុកថាជាស្តង់ដាររបស់គ្រូបង្រៀននៅតំបន់អាស៊ីអាគ្នេយ៍ផងដែរគឺ***

**៥. ក្រមសីលធម៌វិជ្ជាជីវៈ** ( Professional Ethics and Morality )

ក្រមសីលធម៌វិជ្ជាជីវៈជាការអនុវត្តផ្ទាល់ខ្លួនរបស់គ្រូបង្រៀន។ គ្រូត្រូវបង្ហាញអត្តចារិកដែលមានសីលធម៌ខ្ពស់ មានការគោរព សុភាពរាបសារ និងបំរើការងារជាគំរូក្នុងសេវាកម្មអប់រំព្រមទាំងជាអ្នកបង្ហាញនូវការយល់ឃើញបែបវិជ្ជមានទៅគ្រប់មជ្ឈដ្ឋានទាំងអស់ រួមផ្សំនឹងការលើកទឹកចិត្ត ការលះបង់ដោយមនសិការ និងជាអ្នកផ្តល់តម្លៃ ក្រមសីលធម៌ក្នុងវិស័យអប់រំសម្រាប់ប្រទេសជាតិ។

**៦. ការយល់ដឹងពីសង្គមមនុស្ស** ( Social and Human Dimension Competencies )

គ្រូបង្រៀនត្រូវមានឧត្តមភាព ដែលសិស្សរំពឹងខ្ពស់ថាអាចជួយឱ្យពួកគេសម្រេចបាននូវការសិក្សាដែលមានសក្តានុពល។ គ្រូជាអ្នកយល់ដឹងបានជ្រៅជ្រះទៅលើការងារផ្សេងៗ និងចំណេះដឹងពីបញ្ហាសង្គម ពិសេសលើសិទ្ធិរបស់កុមារ បរិស្ថានដែលអាចជះឥទ្ធិពលលើការសិក្សា សុខភាពរបស់សិស្ស និងមានជំនាញក្នុងការប្រាស្រ័យទាក់ទងជាមួយសិស្ស[13]។

## ២.៣.៤- ក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន

គ្រូបង្រៀនត្រូវតែជាជនគំរូនៃមហាជនទូទៅ ទោះស្ថិតក្នុងលក្ខខណ្ឌពេលវេលា ឬទីកន្លែងណាក៏ដោយ ព្រោះគ្រូជាអ្នកដែលផ្តល់សេវាអប់រំឱ្យពលរដ្ឋមានការយល់ដឹង ក្រៅពីមជ្ឈដ្ឋានគ្រួសារ និងសង្គម។ ក្រោយពីក្មេងដឹងក្តី និងចាប់ផ្តើមចូលរៀនសូត្រនៅសាលារៀនពេលនោះអ្វីៗទាំងអស់ត្រូវទទួលបានពីគ្រូ និងមជ្ឈដ្ឋានសាលា។ ដូច្នេះហើយ ទើបគ្រូបង្រៀននិងគ្រឹះស្ថានសិក្សាទាំងអស់ ត្រូវយកចិត្តទុកដាក់លើការបណ្តុះបណ្តាលសិស្សឱ្យមានការរីកចម្រើនផ្នែកសតិបញ្ញា ការយល់ដឹង ចំណេះ ជំនាញ សីលធម៌រស់នៅ និងការប្រាស្រ័យទាក់ទងគ្នាក្នុងសង្គមបានល្អប្រសើរ។ ក្នុងនោះដែរគ្រូត្រូវគោរពតាមករណីយកិច្ចមួយចំនួនដូចខាងក្រោម៖

### ក. ករណីយកិច្ចគ្រូបង្រៀន

- គោរពជីវិត រាងកាយ ចិត្ត និងសេចក្តីថ្លៃថ្នូររបស់មនុស្សក្នុងពេលប្រកបវិជ្ជាជីវៈ (មាត្រា ៥)
- ប្រកាន់ខ្ជាប់សីលធម៌ក្នុងការប្រកបវិជ្ជាជីវៈ (មាត្រា ៥)
- រក្សាការសម្ងាត់វិជ្ជាជីវៈក្នុងលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ និងបទបញ្ញត្តិនានាដើម្បីផលប្រយោជន៍របស់អ្នកសិក្សា (មាត្រា៥)
- ប្រកាន់ខ្ជាប់នូវឥស្សរភាពវិជ្ជាជីវៈដែលមានជាអាទិ៍៖ ឯករាជ្យ សេរីភាព និងឧត្តមភាពក្នុងពេលបំពេញវិជ្ជាជីវៈរបស់ខ្លួន (មាត្រា ៦)
- ស្តាប់ពិនិត្យ ឱ្យដំបូន្មាន ឬធ្វើអាណាព្យាបាលអ្នកសិក្សាទូទៅដោយមិនលម្អៀង និងមិនរើសអើងគ្រប់លក្ខខណ្ឌ (មាត្រា ៧)

[13] SEAMEO INNOTECH, Teaching Competency Standards in Southeast Asian Countries 2010 page11-30

- ប្រកាន់ខ្ជាប់មនសិការវិជ្ជាជីវៈ (មាត្រា ៨)
- រៀបចំកិច្ចតែងការបង្រៀន ដើម្បីកំណត់ការពន្យល់ សំដៅធានាគុណភាពនិងប្រសិទ្ធភាពនៃការបង្រៀន (មាត្រា ៨)
- ភ្ញាក់រលឹកក្នុងការសិក្សាស្រាវជ្រាវបន្ថែមនូវចំណេះដឹងរបស់ខ្លួន
- មានការស្វ័យវាយតម្លៃជាប្រចាំទាំងសីលធម៌ អាកប្បកិរិយា និងលើការប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន(មាត្រា ៩)
- ចូលរួម និងគាំទ្រគ្រប់សកម្មភាពអប់រំ ទោះក្នុងរូបភាពណាក៏ដោយ (មាត្រា ១០)
- និយាយស្តីដោយមានការប្រុងប្រយ័ត្ន និងគិតទៅដល់ប្រតិឃាតនៃពាក្យសម្តីរបស់ខ្លួនចំពោះអ្នកសិក្សា និងសាធារណជនក្នុងការផ្តល់ព័ត៌មានអំពីការអប់រំទាំងសាធារណៈនិងទាំងឯកជនតាមគ្រប់មធ្យោបាយផ្សព្វផ្សាយ (មាត្រា ១១)

**ខ.ករណីយកិច្ចគ្រូបង្រៀនចំពោះអាណាព្យាបាលសិស្ស**

- មានភក្តីចំពោះមុខសិស្សភាពស្មោះត្រង់ មិនមែនពុតត្បុតលើកិត្យានុភាពរបស់គ្រូឡើយ
- អត់ធ្មត់ អំណត់អត់ធន់ និងឧស្សាហ៍ព្យាយាមមិនខ្លាចលំបាក និងនឿយហត់
- យកចិត្តទុកដាក់ក្នុងការពន្យល់បកស្រាយ និងសម្របសម្រួលដល់អ្នកសិក្សានូវចំណេះដឹងនា នាស្រេបតាមមុខវិជ្ជា ឬឯកទេសរបស់ខ្លួន (មាត្រា ១៥)
- ជួយអ្នកសិក្សា ជួយបង្រៀនបន្ថែមដល់អ្នកសិក្សារៀនយឺត ដោយមិនរើសអើង
- ដឹកនាំសកម្មភាពក្នុងថ្នាក់ ក្រៅថ្នាក់ និងលើកទឹកចិត្តដល់អ្នកសិក្សាជាប់ជាប្រចាំ (មាត្រា ១៧)
- បង្រៀនមិនត្រូវដាក់សម្ពាធយកជាប្រយោជន៍លើអ្នកសិក្សាឡើយ (មាត្រា ១៧)
- ជួយសម្រួលដល់អ្នកសិក្សាក្នុងការទទួលបាននូវផលប្រយោជន៍ផ្នែកសង្គម ដោយមិនលម្អៀង និងមានទំនាក់ទំនងជាមួយមាតាបិតា ឬអ្នកអាណាព្យាបាលរបស់អ្នកសិក្សាដើម្បីតាមដានលើរាល់សកម្មភាពសិក្សា (មាត្រា ១៨)
- មិនត្រូវប្រព្រឹត្តសកម្មភាពខុសច្បាប់ ដែលនាំឱ្យមានការប៉ះពាល់ដល់ការបង្រៀន និងការរៀន និងការប្រឡងរបស់អ្នកសិក្សាឡើយ (មាត្រា ១៩) ។

**គ. ករណីយកិច្ចគ្រូបង្រៀនត្រូវចៀសវាង**

- ធ្វើប្រជាភិថុតិចំពោះអ្នកសក្សាឡើយ (មាត្រា ១១)
- ផ្សព្វផ្សាយអំពីការវិនិច្ឆ័យវិន័យរដ្ឋបាលបុគ្គលនៅក្នុងមជ្ឈដ្ឋានអប់រំ ក៏ដូចជាក្នុងមជ្ឈដ្ឋានសាធារណៈឡើយ (មាត្រា ១១)
- ផ្សំគំនិតប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យខូចប្រយោជន៍អ្នកសិក្សាក្នុងសេវាអប់រំឡើយ (មាត្រា ១២)

- ដាក់ទណ្ឌកម្មផ្លូវកាយ និងផ្លូវចិត្តដែលនាំឱ្យមានផលប៉ះពាល់ដល់អ្នកសិក្សាទេ (មាត្រា ១២)
- ធ្វើការរៃអង្គាសប្រាក់ ឬប្រមូលប្រាក់ក្រៅផ្លូវការ ឬធ្វើអាជីវកម្មនានាក្នុងថ្នាក់រៀនឡើយ (មាត្រា ១៣)
- ប្រកបមុខរបរផ្សេងក្នុងបរិវេណគ្រឹះស្ថានសិក្សា (មាត្រា ១៣)
- ប្រព្រឹត្តអំពើទាំងឡាយណា ដែលធ្វើឱ្យអាប់ឱនកិត្តិយស និងវិជ្ជាជីវៈរបស់ខ្លួន (មាត្រា ១៤)
- ផ្តល់ការសម្របសម្រួលគ្រប់បែបយ៉ាង ដែលនាំឱ្យខ្លួនធ្វើខុសច្បាប់ និងបទបញ្ជាឡើយ (មាត្រា ១៤)[14]

### ឃ. តួនាទី និងគុណសម្បត្តិគ្រូបង្រៀនក្នុងយុគសម័យឌីជីថល

នៅឆ្នាំ ២០៣០ ក្រសួងមានចក្ខុវិស័យគឺ ធ្វើយ៉ាងណាឱ្យទទួលបានគ្រូបង្រៀនប្រកបដោយសមត្ថភាព មនសិការ និងវិជ្ជាជីវៈដែលផ្តល់ការគាំទ្រដល់អ្នកសិក្សា ឱ្យទទួលបានការអប់រំមានគុណភាពកម្រិតខ្ពស់។ ក្នុងយុគសម័យឌីជីថលនេះ គ្រូបង្រៀនត្រូវមានលក្ខណៈសម្បត្តិជាច្រើនដូចជា៖

១) គ្រូជាអ្នកបង្ហាត់បង្រៀន និងជាមគ្គុទ្ទេសក៍ដែលជួយគាំទ្រ និងបង្ហាញផ្លូវសិស្ស (Teacher as coach and guide)។

២) គ្រូជាអ្នកកំណត់គោលដៅនៃការរៀន និងសួរសំណួរអោយសិស្សចេះគិត ធ្វើអត្ថាធិប្បាយ និងរកចម្លើយ (Teacher as goal setter and questioner) ហើយបង្រៀនតាមបែបការរៀនដោះស្រាយបញ្ហា (Problem-Based Learning) និង ការរៀនតាមបែបត្រិះរិះ (Inquiry-Based Learning)។

៣) គ្រូរៀបចំដំណើរការរៀន (Teacher as learning designer): ដោយឈរលើមូលដ្ឋាននៃការយល់ដឹងរបស់សិស្ស ដើម្បីអោយសិស្សកាន់តែយល់ច្បាស់គ្រូត្រូវរៀបចំសកម្មភាពអោយសិស្សរៀន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

៤) គ្រូជាអ្នករៀបចំបរិបទ (Teacher as context provider)៖ ដើម្បីអោយសិស្សមានសមត្ថភាពយល់ដឹងបានច្បាស់ពីស្ថានភាពជាក់ស្តែងនៃការអប់រំ។

៥) គ្រូជាអ្នកត្រួតពិនិត្យការរៀនសូត្រ និងធានាគុណភាពនៃការរៀនរបស់សិស្ស (Teacher as rigor provider and quality assurer)។

[14] រាជរដ្ឋាភិបាល-អនុក្រិត្យស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន ២០០៨ ទំព័រទី៣-១៥

៦) គ្រូត្រូវមានចំណេះដឹងបច្ចេកវិទ្យា (Technology Knowledge): ចំណេះដឹងពីអក្ខរកម្ម កុំព្យូទ័រ អិនធ័រណែត វីដេអូឌីជីថល ក្ដារខៀនឆ្លាត និងកម្មវិធីកុំព្យូទ័រ (Digital system, Information Technology and Computer Literacy)។

៧) គ្រូត្រូវាមានចំណេះដឹងពីខ្លឹមសារមេរៀន (Content Knowledge): ចំណេះដឹងពីមុខវិជ្ជាឯកទេសដែលត្រូវបង្រៀន។

៨) គ្រូតត្រូវមានចំណេះដឹងគរុកោសល្យ (Pedagogical Knowledge): វិធីសាស្ត្របង្រៀន និងដំណើរការបង្រៀនដូចជា ការរៀន ផ្ដោតលើបញ្ហា (Problem-Based Learning: PBL) ការរៀនផ្ដោតលើការចងចាំនៃខួរក្បាល (Brain-Based Learning) ការរៀនតាមបែបគម្រោង (Project Method) វិធីសាស្ត្រស្វែងរកដោយខ្លួនឯង (Discovery Method) ការសិក្សាដោយខ្លួនឯង (Self-Study Method, Inquiry-Based Learning) ការគ្រប់គ្រងថ្នាក់រៀន វាយតម្លៃ ការរៀបចំកិច្ចតែងការបង្រៀន និងវិធីរៀនរបស់សិស្ស[15]។

## ២.៣.៥- កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនគឺ ជាចំណែកមួយដ៏សំខាន់ក្នុងការចូលរួមលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា និងដើម្បីផលិតបាននូវធនធានមនុស្ស ឬអាចក្លាយជាមូលធនមនុស្សនៅពេលអនាគត ព្រមទាំងអាចជ្រៀតចូលប្រគួតប្រជែងក្នុងទីផ្សារការងារថ្នាក់តំបន់ និងពិភពលោក។ ដោយមានការសហការគ្នារវាងក្រសួងអប់រំ យុវជន និងកីឡា ជាមួយធនាគារពិភពលោកបានរៀបចំឱ្យមានគម្រោងមួយគឺ ការអភិវឌ្ឍគុណភាពវិស័យអប់រំនៅមធ្យមសិក្សាបឋមភូមិ Secondary Education Improvement Project (SEIP) ដោយផ្ដោតលើសាលាចំនួន១០០ នៅទូទាំងប្រទេស។ ទាក់ទងនឹងគម្រោងនេះ ក្រសួងអប់រំ រួមទាំងធនាគារពិភពលោកបានធ្វើកំណែទម្រង់ជាច្រើនដូចជា ការពង្រឹងលើវិធីសាស្ត្របង្រៀន កម្មវិធីសិក្សា វិន័យសិក្សា និងការពង្រឹងទំនាក់ទំនងរវាងសាលា និងសហគមន៍ជាដើម ហើយពិសេសជាងនេះទៅទៀតគឺ គម្រោងនេះបានជ្រើសរើសគ្រូកម្រិតមូលទាំងអស់មកចូលរៀនអភិវឌ្ឍចំណេះដឹងតាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន Teacher Upgrading Program(TUP) នៅសាកលភូមិន្ទភ្នំពេញពីឆ្នាំសិក្សា២០១៨-២០១៩ មកដល់បច្ចុប្បន្ន។

### ក. លក្ខណៈទូទៅនៃវគ្គបណ្ដុះបណ្ដាល TUP

[15] បទបង្ហាញស្ដីពីសញ្ញាណគោលនយោបាយ និងកំណែទម្រង់អប់រំ យុវជន និងកីឡា ២០១៩ ស្លាយទី ២៥-២៦

វគ្គនេះមានរយៈពេលសិក្សាតែពីរឆ្នាំមាន ៩៥០ម៉ោង ដែលគិតសរុបរួមមានជាង ១៨ខែ ដោយការសិក្សាធ្វើឡើងតែថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ហើយជាការងាយស្រួលសម្រាប់លោកគ្រូអ្នកគ្រូដែលមកចូលរួម ព្រោះពួកគាត់អាចរៀនបណ្ដើរធ្វើការបណ្ដើរ។ ការសិក្សាទាំងស្រុងនៃវគ្គផ្ដោតសំខាន់ទៅលើកម្មវិធីពីរគឺ ចំណេះដឹងឯកទេស និងវិធីសាស្ត្របង្រៀន ដែលការៀនោះទៀតសោត សិក្ខាកាមទាំងអស់ត្រូវផ្សាភ្ជាប់នឹងការអនុវត្តផ្ទាល់នៅតាមសាលាដែលខ្លួនធ្វើការ។ សិក្ខាកាមដែលមករៀនសុទ្ធតែមកពីសាលាផ្សេងៗគ្នាទូទាំងប្រទេសដែលទទួលយកការអនុវត្តគម្រោង SEIP ព្រមទាំងទទួលការឧបត្ថមពីម្ចាស់ជំនួយគឺ ធនាគារពិភពលោក។ មកដល់បច្ចុប្បន្ន វគ្គបណ្ដុះបណ្ដាលនេះបានដំណើរការអស់រយៈពេលពីរឆ្នាំហើយ ដោយមានអ្នកសិក្សាជំនាន់ទី១ចំនួន ១៩៧នាក់ ស្រី ៩៦នាក់ និងជំនាន់ទី២ មាននិស្សិតចំនួន ៧០៦នាក់ ស្រី ២៦០នាក់ [16] ហើយការសិក្សាផ្ដោតសំខាន់លើមុខវិជ្ជាវិទ្យាសាស្ត្រពិតស្របតាមគោលនយោបាយកំណែទម្រង់វិស័យអប់រំលើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែល៦មុខវិជ្ជានោះគឺ គណិតវិទ្យា ភាសាខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា។

**ខ. ចក្ខុវិស័យ វត្ថុបំណង និងគោលបំណងនៃវគ្គបណ្ដុះបណ្ដាល TUP**

វគ្គបណ្ដុះបណ្ដាលនេះ បានកំណត់ចក្ខុវិស័យ អភិវឌ្ឍសមត្ថភាពគ្រូបង្រៀនតាមរយៈការផ្ដល់ចំណេះដឹង ជំនាញ សីលធម៌ និងសមត្ថភាពវិជ្ជាជីវៈដែលទទួលស្គាល់ដោយសង្គម។ ក្នុងន័យនេះក្រសួងអប់រំ បានផ្ដោតការយកចិត្តទុកយ៉ាងខ្លាំងលើការអភិវឌ្ឍសមត្ថភាពគ្រូ និងលក្ខខណ្ឌផ្សេងៗទៀត ដែលអាចជួយធ្វើការផ្លាស់ប្ដូរផ្នត់គំនិតអវិជ្ជមានមួយចំនួនដែលកើតឡើងក្នុងមជ្ឈដ្ឋានបុគ្គលិកអប់រំ។ ម្យ៉ាងវិញទៀត វគ្គនេះមានគោលបំណង អភិវឌ្ឍគ្រូបង្រៀនដោយផ្ដោតគុណភាព សមត្ថភាព និងទំនួលខុសត្រូវក្នុងក្របខណ្ឌអាជីព ដូចជាការផ្ដល់លក្ខខណ្ឌដែលអាចទៅរួចដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធិភាព និងភាពស័ក្ដិសិទ្ធិ។ ដើម្បីសម្រេចបាននូវចក្ខុវិស័យ និងគោលបំណងខាងលើក្រសួងបានលើកយកនូវវត្ថុបំណងចំនួន៤ គឺ ១)ទាក់ទាញ និងលើកទឹកចិត្តបុគ្គលដែលមានសមត្ថភាពឱ្យចូលបម្រើការជាគ្រូបង្រៀន ២)ពង្រឹងគុណភាពបណ្ដុះបណ្ដាលគ្រូត្រៀមក្នុងអាជីពណាមួយ (Pre-service) ៣)ពង្រឹងការអភិវឌ្ឍអាជីពជាប្រចាំ និងបណ្ដុះបណ្ដាលបំប៉នក្នុងក្របខណ្ឌមានស្រាប់ (In-service) សម្រាប់គ្រូ និង ៤)ពង្រឹងលក្ខខណ្ឌចាំបាច់សម្រាប់គ្រូ ដើម្បីបំពេញសកម្មភាពការងារឱ្យមានប្រសិទ្ធិភាព និងភាពស័ក្ដិសិទ្ធិ។

**គ. យុទ្ធសាស្ត្រនៃវគ្គបណ្ដុះបណ្ដាល**

[16] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ-របាយការណ៍របស់មហាវិទ្យាល័យអប់រំ ២០១៩

ដើម្បីសម្រេចបាននូវវត្ថុបំណងទាំងបួន និងគោលនយោបាយគ្រូបង្រៀនឆ្នាំ ២០១៣ ក្រសួងនិងអង្គការដៃគូបានគ្រោងយុទ្ធសាស្ត្រចំនួន៩គឺ

- អភិវឌ្ឍវិធានច្បាប់ និងប្រព័ន្ធច្បាប់ដែលមានស្រាប់
- ទាក់ទាញបុគ្គលដែលមានសមត្ថភាពឱ្យចូលធ្វើគ្រូ
- កំណត់នូវស្តង់ដារនៃប្រព័ន្ធបណ្តុះបណ្តាលគ្រូ
- អភិវឌ្ឍមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូ
- ផ្តល់ភាពងាយស្រួល និងសមហេតុផលដល់គ្រូដើម្បីសម្រេចនូវតម្រូវការស្ថាប័នអប់រំ
- ផ្តល់នូវការបណ្តុះបណ្តាលត្រៀម (Pre-service) និងអភិវឌ្ឍអាជីពសម្រាប់គ្រូ
- គ្រូបង្រៀនត្រូវបានលើកទឹកចិត្ត និងថែរក្សាក្នុងប្រព័ន្ធ
- ពង្រឹងប្រសិទ្ធភាពនៃភាពជាអ្នកដឹកនាំសាលារៀន
- ពង្រឹងប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃលើគ្រូបង្រៀន[17]។

តាមរយៈយុទ្ធសាស្ត្រទាំងប្រាំបួននេះ ក្រសួងសង្ឃឹមថានឹងអាចសម្រេចបាននូវគុណភាពនៃការបណ្តុះបណ្តាលគ្រូ និងអាចឆ្លើយតបនឹងគោលនយោបាយអប់រំជាតិ សម្រាប់អភិវឌ្ឍធនធានមនុស្សស្របតាមការចង់បានរបស់ប្រទេសជាតិ ដែលរំពឹងថានឹងអាចក្លាយជាប្រទេសឧស្សាហកម្មនៅឆ្នាំ ២០៣០ និងស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពចំណុចទី៤ស្តីពីការអប់រំមានគុណភាព SDG4 ។ ម្យ៉ាងវិញទៀត យោងតាមការសិក្សាស្រាវជ្រាវរបស់អង្គការយូនីស្កូបានបញ្ជាក់ថា ការបណ្តុះបណ្តាល និងការជួយគាំទ្រគ្រូបង្រៀននៅក្នុងកំឡុងពេលប្រាំឆ្នាំដំបូងនៃការបង្រៀនក្នុងថ្នាក់គឺ ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយដើម្បីជំរុញការវិវត្តិវិជ្ជាជីវៈរបស់គ្រូបង្រៀនបាន ដោយផ្តល់ឱកាសសិក្សាសម្រាប់គ្រូ ធ្វើទស្សនៈកិច្ចផ្លាស់ប្តូរបទពិសោធរវាងសាលា សិក្ខាសាលា ការគាំទ្រពីអ្នកប្រឹក្សា និងអធិការវិក្រឹតការ និងការប្រឹក្សារវាងគ្រូក្នុងក្រុមមុខវិជ្ជាដូចគ្នា[18]។ ទាំងអស់នេះហើយដែលឆ្លុះបញ្ចាំងឱ្យឃើញពីការខិតខំប្រឹងប្រែងរបស់ក្រសួង រួមទាំងភាគីពាក់ព័ន្ធទាំងអស់ក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។

[17] Ministry of Education Youth and Sport- Operational Manual for Teacher Upgrading Program, SEIP, 2017 page 1-2

[18] បណ្ឌិត ហង់ជួន ណារ៉ុន-សន្និបាតអប់រំ(ចក្ខុវិស័យកំណែទម្រង់វិស័យអប់រំ) ២០១៥ ស្លាយទី ១៤

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១-ការរៀបចំស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់វិធីសាស្ត្របែបចម្រុះមានទាំងបែបបរិមាណវិស័យនិងបែបគុណវិស័យ ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលបានកំណត់រួចនៅក្នុងជំពូកទី១។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយប្រើកម្រងសំណួរ ដែលមានសំណួរបែបពាក់កណ្ដាលរចនាសម្ព័ន្ធ (Semi-structured Questionnaires) ដោយមានសំណួរទម្រង់បិទ និងទម្រង់បើកដើម្បីប្រមូលទិន្នន័យពីគ្រូបង្រៀនជំនាន់ទី២ទាំងប្រាំមួយមុខវិជ្ជា ដែលកំពុងសិក្សានៅសាកលភូមិន្ទភ្នំពេញរៀងរាល់ចុងសប្ដាហ៍ថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។ កម្រងសំណួរដែលត្រូវយកមកប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ គឺធ្វើឡើងសម្រាប់សាកសួរព័ត៌មានរបស់សិក្ខាកាមដែលចូលរៀនបំប៉នតាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន នៅសាកលភូមិន្ទភ្នំពេញប៉ុណ្ណោះ។

## ៣.២-វិធីសាស្ត្រប្រមូលទិន្នន័យ

មុននឹងឈានដល់ដំណាក់កាលប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានប្រើប្រាស់លិខិតឧទ្ទេសនាមដែលចេញដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា យកទៅសុំការអនុញ្ញាតពីឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីចុះប្រមូលទិន្នន័យពីលោកគ្រូ អ្នកគ្រូដែលកំពុងរៀនវគ្គ TUP តាមគោលដៅដែលបានកំណត់យក។ បន្ទាប់មកទៀត អ្នកស្រាវជ្រាវ បានទាក់ទងទៅលោកគ្រូប្រធានសម្របសម្រួលវគ្គ ដោយជម្រាបគាត់មុន៣ថ្ងៃដោយប្រាប់ពីគោលបំណងនៃការចុះប្រមូលទិន្នន័យនៃការស្រាវជ្រាវ ដើម្បីផ្ដល់ព័ត៌មានដល់គ្រូបង្រៀនពាក់ព័ន្ធ និងសុំណាត់ជួបពួកគាត់នៅពេលវេលាសមស្របណាមួយដែលអាចធ្វើបានទុកជាមុន។ នៅពេលទៅដល់សាលារៀន អ្នកស្រាវជ្រាវបានបង្ហាញលិខិតឧទ្ទេសនាមបេសកកម្មចុះប្រមូលទិន្នន័យនោះទៅលោកប្រធានគ្រប់គ្រង និងសម្របសម្រួលវគ្គ ដើម្បីសុំការអនុញ្ញាតពីគាត់ធ្វើការប្រមូលទិន្នន័យ ដោយកោះអញ្ជើញគ្រូបង្រៀនដែលពាក់ព័ន្ធ ប្រជុំធ្វើការណែនាំក្នុងការបំពេញកម្រងសំណួរ និងធ្វើការបំពេញកម្រងសំណួរនោះ ដោយគោរពតាមក្រមសីលធម៌អ្នកស្រាវជ្រាវ តាមការស្ម័គ្រចិត្ត និងគ្មានការបង្ខិតបង្ខំឡើយ។ ក្នុងការបំពេញកម្រងសំណួរនេះ ប្រើប្រាស់ពេលវេលាប្រហែល៣០នាទី។ ចំណែកគ្រូបង្រៀនមួយចំនួនធំក្រោយពេលទទួលបានការណែនាំក្នុងការបំពេញរួចហើយ ក៏សុំយកទៅបំពេញនៅផ្ទះ ព្រោះពួកគាត់ត្រូវចូលរៀនវិញ ដោយមិនចង់ប៉ះពាល់ដល់ម៉ោងសិក្សារបស់ពួកគាត់។ ក្នុងករណីគ្រូ

បង្រៀនយកទៅបំពេញនៅផ្ទះ  អ្នកស្រាវជ្រាវបានស្នើសុំទុកពេលឱ្យពួកគាត់មួយសប្តាហ៍ ព្រោះពួកគាត់រៀនតែថ្ងៃសៅរ៍  និងថ្ងៃអាទិត្យប៉ុណ្ណោះ  និងបានកំណត់កាលបរិច្ឆេទច្បាស់លាស់ ដើម្បីសុំប្រមូលកម្រងសំណួរវិញ ហើយចំពោះលោកគ្រូអ្នកគ្រូដែលមិនបានផ្តល់កម្រងសំណួរមកវិញតាមពេលវេ លាកំណត់ អ្នកស្រាវជ្រាវបានសុំការយោគយល់ពីអ្នកគ្រប់គ្រងវគ្គក្នុងការជួយសម្របសម្រួលប្រមូលទុករហូតគ្រប់ចំនួន ទើបគាត់ផ្តល់ដំណឹងមកអ្នកស្រាវជ្រាវទៅយកជាលើកចុងក្រោយ។  ក្នុងការចុះទៅប្រមូលទិន្នន័យទាំងអស់នេះ អ្នកស្រាវជ្រាវបានប្រើប្រាស់រយៈពេលសរុបជិត៣សប្តាហ៍  គិតចាប់ពីថ្ងៃណែនាំក្នុងការបំពេញ  និងចែកកម្រងសំណួរដំបូងរហូតដល់ថ្ងៃប្រមូលចុងក្រោយ ។

## ៣.៣-ការជ្រើសរើសសំណាក

បើយោងតាមរបាយការណ៍ស្ថិតិដើមឆ្នាំ២០១៩-២០២០ របស់ដេប៉ាតឺម៉ង់មហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញបានបង្ហាញថា សិក្ខាកាមដែលបានចូលរៀនជំនាន់ទី២នេះមានចំនួនសរុប  ៧០២នាក់  ដោយសិក្សាលើ៦មុខវិជ្ជា  ដែលលលោកគ្រូអ្នកគ្រូទាំងសុទ្ធសឹងជាគ្រូបឋមភូមិដែលបង្រៀននៅថ្នាក់ទី៧ដល់ថ្នាក់ទី៩  ឬអាចបង្រៀនកម្រិតទុតិយភូមិនៅបណ្តាអនុវិទ្យាល័យ  និងវិទ្យាល័យស្ទើរគ្រប់ខេត្តក្រុងទូទាំងប្រទេស។ ដោយសារកត្តាពេលវេលា អ្នកស្រាវជ្រាវបានកំណត់យកចំនួនគំរូសំណាក ១៥ ភាគរយប៉ុណ្ណោះ ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការសិក្សាស្រាវជ្រាវ។

អ្នកស្រាវជ្រាវ  បានកំណត់យកលោកគ្រូអ្នកគ្រូដែលជាសិក្ខាកាមគ្រប់មុខវិជ្ជាទាំង៦ មានដូចជា គណិតវិទ្យា ភាសាខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា ដោយគិត ១៥% នៃចំនួនសិក្ខាកាមតាមមុខវិជ្ជានីមួយៗ តាមរូបមន្តសមាមាត្រដូចខាងក្រោម៖

តារាងទី១៖ ការជ្រើសរើសសំណាក

| ល.រ | មុខវិជ្ជា | ចំ.សិក្ខាកាមសរុប | ចំនួន%សំណាក | ចំនួនសំណាក |
|---|---|---|---|---|
| ១ | គណិតវិទ្យា | ១៨៣ | ១៥ | ២៧ |
| ២ | ភាសាខ្មែរ | ២១៨ | ១៥ | ៣៣ |
| ៣ | រូបវិទ្យា | ៩៤ | ១៥ | ១៤ |
| ៤ | គីមីវិទ្យា | ៤៨ | ១៥ | ០៧ |
| ៥ | ជីវវិទ្យា | ៨០ | ១៥ | ១២ |

| | | | | |
|---|---|---|---|---|
| ៦ | ប្រវត្តិវិទ្យា | ៧៩ | ១៥ | ១២ |
| សរុប | | ៧០២នាក់ | | ១០៥ |

## ៣.៤-ឧបករណ៍ស្រាវជ្រាវ

ការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរតែមួយប្រភេទប៉ុណ្ណោះក្នុងការប្រមូលទិន្នន័យទាំងតាមបែបបរិមាណ និងគុណវិស័យ។ កម្រងសំណួរត្រូវបានបង្កើតឡើងដោយផ្អែកលើសំណួរស្រាវជ្រាវក្នុងជំពូកទី១ និងទ្រឹស្តីនានាទាក់ទងនឹងការលើកម្ពស់គុណភាពសមត្ថភាពមន្ត្រីអប់រំ និងការអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ដែលផ្តោតជាសំខាន់ចំណុចមួយចំនួនដូចជា ការយល់ឃើញរបស់សិក្ខាកាមចំពោះវគ្គ ការរៀបចំកម្មវិធីសិក្សា ចំណេះដឹងថ្មីៗដែលសិក្ខាកាមបានទទួលពីវគ្គបណ្តុះបណ្តាល និងកម្រិតនៃការអនុវត្តចំណេះដឹងរបស់លោកគ្រូអ្នកគ្រូក្រោយបញ្ចប់មេរៀននីមួយៗ។

## ៣.៥-កម្រងសំណួរ និងគោលបំណង

ដើម្បីងាយស្រួលក្នុងការសម្គាសន៍ និងវិភាគទិន្នន័យ អ្នកស្រាវជ្រាវបានចែកកម្រងសំណួរជា ពីរផ្នែកគឺ៖

ផ្នែកទី១៖ មាន៦សំណួរជាព័ត៌មានទូទៅរបស់អ្នកផ្តល់ចម្លើយរួមមាន ខេត្តក្រុង ស្រុក ឈ្មោះសាលាកំពុងបម្រើការ ភេទ អាយុ កម្រិតវប្បធម៌ មុខវិជ្ជាឯកទេស និងបទពិសោធន៍ការងារបង្រៀន។

ផ្នែកទី២ ៖ មានសំណួរចំនួន ១៦ គឺចាប់ពីសំណួរទី៧ ដល់២២ ដែលជាសំណួរបែបបរិមាណ និងគុណវិស័យ ហើយផ្តោតសំខាន់លើទស្សនៈយល់ឃើញរបស់សិក្ខាកាមទាក់ទងទៅនឹងវគ្គបណ្តុះបណ្តាល ដំណើរការវគ្គ កម្មវិធីសិក្សា វិធីសាស្រ្តបង្រៀន បញ្ហាប្រឈមនានា និងការអនុវត្តចំណេះដឹងរបស់សិក្ខាកាមក្រោយទទួលការបណ្តុះបណ្តាល TUP។ ការៀបចំកម្រងសំណួរបែបនេះគឺ ដើម្បីស្វែងរយកឱ្យឃើញនូវការយល់ដោយផ្ទាល់របស់លោកគ្រូ អ្នកគ្រូ និងផលតបស្នងវិជ្ជមាន អវិជ្ជមានមួយចំនួនក្នុងកំឡុងពេល និងក្រោយទទួលការបណ្តុះបណ្តាល ព្រមទាំងអាចចូលរួមវាស់ស្ទង់ពីកម្រិតនិរន្តភាពនៃការអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន TUP នៅសាកលភូមិន្ទភ្នំពេញផងដែរ។

## ៣.៦-ការវិភាគទិន្នន័យ

ដោយយោលទៅតាមកម្រងសំណួរ និងប្រធានបទនៃការស្រាវជ្រាវ ការវិភាគទិន្នន័យត្រូវធ្វើឡើងតាមបែបបរិមាណវិស័យផង និគុណវិស័យផង ដោយលទ្ធផលនៃចម្លើយនឹងត្រូវបានបញ្ចូលកក្នុងកម្មវិធី Microsoft Excel សម្រាប់សំណួរបែបបរិមាណ និងសំណួរបែបគុណ

វិស័យវិញ អ្នកស្រាវ ជ្រាវបានប្រមូលដកស្រង់ចម្លើយទាំងអស់រៀបទៅតាមសំណួរនីមួយៗ ក្នុងកម្មវិធី Excel ផងដែរ ដោយធ្វើការស្រង់ពាក្យពេចន៍ អត្ថន័យក្នុងចម្លើយដែលដូចគ្នា ឬប្រហាក់ប្រហែលគ្នា ដើម្បីទាញព័ត៌មានបន្ថែមអំពីដំណើរការទាំងមូល ដើម្បីគាំទ្រចម្លើយបែបបរិមាណវិស័យ និងលើកបានពីអនុសាសន៍ សេចក្តីសន្និដ្ឋានក្នុងការដោះស្រាយបញ្ហាប្រឈមនានាក្នុងការអនុវត្តកម្មវិធីលើកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន TUP សម្រាប់ឆ្នាំសិក្សាបន្តបន្ទាប់ទៀតនិង ដើម្បីឱ្យការអនុវត្តកម្មវិធីនេះកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

## ៣.៧-ក្រមសីលធម៌នៃការស្រាវជ្រាវ

ក្រមសីលធមិ ពិតជាចាំបាច់ណាស់សម្រាប់អ្នកសិក្សាស្រាវជ្រាវ អ្នកចូលរួម និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ ដោយឡែក ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានកំណត់នូវក្រមសីលធមិមួយយ៉ាងច្បាស់លាស់ ក្នុងគោលបំណង គោរព និងផ្តល់តម្លៃដល់អ្នកចូលរួម និងទិន្នន័យមានភាពជឿជាក់ និងអាចទទួលយកបាន។ ដើម្បីរក្សាបាននូវក្រមសីលធមិ អ្នកស្រាវជ្រាវបានទទួលលិខិតអនុញ្ញាតពីថ្នាក់ក្រសួង និងវិទ្យាស្ថានជាតិអប់រំ និងបានយកទៅដាក់ប្រគល់ជូនមន្ទីរអប់រំខេត្ត ដើម្បីសុំលិខិតអនុញ្ញាតក្នុងការចុះទៅសាលាគោលដៅ។ ដោយការស្រាវនេះធ្វើឡើងតែមួយសាលាគឺសា កលភូមិន្ទភ្នំពេញ ដូចនេះអ្នកស្រាវជ្រាវគ្រាន់សុំការអនុញ្ញាតពីសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ និងមហាវិទ្យាល័អប់រំនៃគណៈគ្រប់គ្រងវគ្គប៉ុណ្ណោះ។ ទន្ទឹមគ្នានេះដែរ នៅគ្រប់ការសម្ភាសន៍ និងការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវបានតែងតែជម្រាបជូនអ្នកចូលរួម អំពីក្រមសីលធមិរបស់ការសិក្សាស្រាវជ្រាវ ដែលរក្សាការសម្ងាត់ចំពោះរាល់ចម្លើយរបស់អ្នកចូលរួម ដែលមិនបង្ហាញនូវអត្តសញ្ញាណរបស់អ្នកចូលរួមឡើយ ហើយរាល់ព័ត៌មានទាំងឡាយដែលបាផ្តល់ឱ្យ គឺត្រូវបានប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «ទស្សនៈយល់ឃើញរបស់សិក្ខាកាមរៀនវគ្គបំប៉នកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលភូមិន្ទភ្នំពេញ» សម្រាប់បំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំនៅវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៨-២០១៩ ហើយរាល់ព័ត៌មានទាំងអស់ត្រូវបានរក្សាជាការសម្ងាត់។ កម្រងសំណួរ និងចម្លើយដែលបានមកពីកម្រងសំណួរ ត្រូវបានប្រើប្រាស់សម្រាប់តែការសរសេរនិក្ខេបបទតែម្យ៉ាងគត់។ អ្នកចូលរួមគ្រប់រូបអាចមានសិទ្ធិពេញលេញ ក្នុងការបដិសេធ មិនឆ្លើយសំណួរណាមួយ ឬបញ្ឈប់ការចូលរួមក្នុងការបំពេញកម្រងសំណួរនេះបាន ដោយមិនមានបញ្ហាអ្វីឡើយ។ ម្យ៉ាងទៀត អ្នកស្រាវជ្រាវមិនបានធ្វើការថតសំឡេង ឬកត់ឈ្មោះអ្នកចូលរួម នៅក្នុងកម្រងសំណួរ ដើម្បីបានអត្តសញ្ញាណអ្នកផ្តល់ចម្លើយឡើយ

# ជំពូកទី៤
# វិធីសាស្ត្រវិភាគទិន្នន័យ

## ៤.១-ព័ត៌មាន និងលក្ខណៈនៃវគ្គសិក្សា TUP

### ៤.១.១-ព័ត៌មានមុនការបណ្តុះបណ្តាល

ក្រាបទី១៖ ព័ត៌មានអំពីវគ្គបណ្តុះបណ្តាល




តាមក្រាបខាងលើបង្ហាញថា សិក្ខាកាមបានទទួលព័ត៌មានអំពីវគ្គសិក្សាមិនបានច្បាស់លាស់មានអត្រាខ្ពស់ជាងគេគឺស្មើនឹង ៦៤.៧៦% ឯការទទួលព័ត៌មានបានច្បាស់លាស់មានតែ ១៦.១៩% និងមិនដឹងពីព័ត៌មានអ្វីសោះពីវគ្គរហូតដល់ទទួលគម្រោងមាន ១៩.០៥%។

តាមទិន្នន័យក្នុងក្រាបបញ្ជាក់ឱ្យដឹងថា ភាគច្រើននៃសិក្ខាកាមដែលមករៀនវគ្គមិនបានទទួលព័ត៌មានអំពីវគ្គបានច្បាស់លាស់នៅឡើយទេ ព្រោះពួកគាត់ថាមិនការផ្សព្វផ្សាយអំពីវគ្គបានទូលំទូលាយឡើយ ហើយប្រភពព័ត៌មានទាំងនោះភាគច្រើនជាការនិយាយតគ្នា ដោយមិនមានលក្ខណៈផ្លូវការណាមួយទេ។ ម៉្យាងទៀត សិក្ខាកាមខ្លះក៏មិនបានដឹងពីព័ត៌មានអ្វីឡើយរហូតដល់សាលាពួកគាត់ទទួលយកគម្រោងតែម្តង។

ការផ្សព្វផ្សាយព័ត៌មានបានទូលំទូលាយ ដល់ស្ថាប័ន និងបុគ្គលិកទាំងអស់ឱ្យបានដឹងច្បាស់ពីការអនុវត្តគម្រោង អាចធ្វើឱ្យមានលើកទឹកចិត្តក្នុងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ព្រោះការងារជាទូទៅត្រូវការការចូលរួមជាចាំបាច់ ដើម្បីកែប្រែយន្តការណាមួយឱ្យមានស្ថានភាពប្រសើរជាងមុន ពិសេសលើការបង្រឹងគុណភាពអប់រំដោយផ្អែកលើលទ្ធផលនៅតាមសាលារៀន។

### ៤.១.២-ប្រភពព័ត៌មាន

ក្រាបទី២៖ ប្រភពព័ត៌មានអំពីវគ្គ




ក្រាបខាងលើបង្ហាញថា ប្រភពព័ត៌មានពីវគ្គសំខាន់បំផុតគឺ នាយកសាលាដែលអត្រាភាគរយខ្ពស់ជាងគេ ស្មើនឹង ៥៧.១៤% ។ បន្ទាប់មកគឺ ក្រសួងមាន ១២.៣៨% មន្ទីរអប់រំមាន ៩.៥២% និងប្រភពខាងការិយាល័យអប់រំស្រុកមានអត្រាទាបជាងគេ ស្មើនឹង ១.៩០%។

បើសង្កេតលើប្រភពនៃព័ត៌មានសំខាន់ ដែលសិក្ខាកាមទទួលបានវិញ ភាគច្រើនពួកគាត់បានទទួលពីនាយកសាលាគាត់តែម្តង ព្រោះទើបតែពេលបានទទួលគម្រោង SEIP ប៉ុណ្ណោះ ដែលលោកគ្រូអ្នកគ្រូមានឱកាសនឹងបានដាក់ពាក្យចូលរៀន។ រីឯប្រភពព័ត៌បន្ទាប់បន្សំផ្សេងៗទៀត ដូចជាមន្ទីរ ស្រុក និងក្រសួងវិញសិក្ខាកាមមិនសូវបានទទួលព័ត៌មានអ្វីឡើយ ដោយសារសាលានៅតាមខេត្តភាគច្រើនស្ថិតនៅឆ្ងាយពីប្រភពទាំងអស់នោះផងដែរ និងណាមួយពួកគាត់មានទំនាក់ទំនងសំខាន់តែជាមួយនាយកសាលា។

ការជ្រើសរើសយកប្រភពនៃការផ្តល់ព័ត៌មានទៅកាន់ប្រភពមួយផ្សេងទៀតគឺ ពិតជាសំខាន់ដើម្បីឱ្យព័ត៌មាននោះមានភាពច្បាស់លាស់ និងមានប្រសិទ្ធភាព។ នៅតាមសាលានីមួយៗគឺ លោកគ្រូអ្នកគ្រូទាំងអស់បំពេញការងារជាប្រចាំ និងមមាញឹកច្រើនលើការរស់នៅប្រចាំថ្ងៃធ្វើឱ្យចាកឆ្ងាយពីការទទួលព័ត៌មានផ្សេងៗ។ ដូច្នេះនាយកសាលា ត្រូវតែជាតួអង្គដ៏សំខាន់ក្នុងការផ្តល់ព័ត៌មានផ្សេងៗដូចជាសេចក្តីណែនាំ និងលិខិតរដ្ឋបាលជាដើមដល់បុគ្គលិក។

## ៤.២-លក្ខខណ្ឌ និងមូលហេតុនៃការចូលរៀន

### ៤.២.១-លក្ខខណ្ឌនៃការចូលរៀន

ជាទូទៅបុគ្គលិកអប់រំនៅសាលា ដែលបានទទួលយកជាសាលាគម្រោងទើបមានឱកាសអាចចូលរួមក្នុងវគ្គបំប៉ន TUP ប៉ុន្តែមិនមែនមានន័យថាគ្រូៗទាំងអស់នៅសាលានោះអាចមករៀនបានដែរគឺ ត្រូវការជ្រើសរើសទៅតាមមុខវិជ្ជា (គណិតវិទ្យា ភាសាខ្មែរ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងប្រវត្តិវិទ្យា) បទពិសោធការងារ និងលក្ខខណ្ឌដទៃទៀតដោយផ្អែកតាមសាលា និងខេត្តផ្សេងៗគ្នា។ ម្យ៉ាងវិញទៀត លោកគ្រូអ្នកគ្រូដែលមានបំណងចង់ទទួលការបំប៉ននេះត្រូវបំពេញពាក្យស្នើសុំ ដែលផ្តល់ដោយនាយកសាលា ឬដោយមន្ទីរ ហើយសាលាឬគម្រោង និងមន្ទីរជាអ្នកសម្រេចការជ្រើសរើសឱ្យចូលរៀន ដូចមានបង្ហាញតាមរយៈក្រាបខាងក្រោម៖

**ក្រាបទី៣៖ បទពិសោធការបំពេញការងារ**




តាមរយៈក្រាបបង្ហាញថា អត្រារយៈពេលបំពេញការងាររបស់សិក្ខាកាមចាប់ពី១០ឆ្នាំទៅ ២០ឆ្នាំ មានចំនួន៤៦.៧០%ដែលជាទិន្នន័យខ្ពស់ជាងគេ និងចន្លោះពី ១ឆ្នាំទៅ៥ឆ្នាំ មានអត្រាទាបជាងគេគឺ ៣.៨០%។

ដោយសារនៅតាមសាលានីមួយៗដែលទទួលគម្រោង SEIP ភាគច្រើនគម្រោងបានផ្តោតជាសំខាន់ជាមួយគ្រូបង្រៀនដែលមានអតីតភាពការងារយូរឆ្នាំ និងកំពុងត្រូវការការបំប៉នចំណេះដឹង និងវិធីសាស្ត្រ បច្ចេកទេសថ្មីៗទៀត ពិសេសក្នុងចន្លោះវ័យនេះ គឺជាវ័យដែលកំពុងពេញបម្រើការងាររួមផ្សំនឹងបទពិសោធចាស់ផងដែរ។ ចំណែកគ្រូក្មេងៗមានអត្រាទាប។ មាន

អគ្រាទាបមានន័យថាពួកគាត់ទើបតែចេញពីការបណ្តុះបណ្តាលគរុកោសល្យ និងមានចំណេះដឹង បច្ចេកទេសថ្មីៗ ជាងលោកគ្រូ អ្នកគ្រូដែលបានចេញបំរើការជាយូរឆ្នាំមកហើយ។

តាមរយៈបទពិសោធន៍ការងារ វាជាកត្តាមួយដែលទាមទារឱ្យធ្វើការបណ្តុះបណ្តាលគ្រូបង្រៀនចាស់ៗជាការចាំបាច់ ដើម្បីជួយបង្កើតសមត្ថភាព ចំណេះដឹង ក៏ដូចជាវិធីសាស្រ្តបង្រៀនថ្មីៗដល់ពួកគាត់ និងដើម្បីឱ្យពួកគាត់ទទួលបានចំណេះ ជំនាញ និងបច្ចេកទេសថ្មីៗសម្រាប់ជំរុញ និងបង្ហាត់បង្រៀនសិស្សានុសិស្សឱ្យមានគុណភាព ចំណេះ បំណិន និងមានឥរិយាបថវិជ្ជមានក្នុងការរស់នៅ។

### ក្រាបទី៨៖ អ្នករៀបចំការចូលរៀន




តាមរយៈក្រាបឃើញថា សិក្ខាកាមដែលបានចូលរៀនតាមរយៈនាយកសាលា ឬខាងគម្រោងជាអ្នកជ្រើសរើសមាន ៨៥.៧១% និង ១៤.២៩%ទៀតគឺតាមរយៈការដាក់ពាក្យសុំនៅការិយាល័យស្រុក និងមន្ទីរ។

ស្ទើរតែទាំងអស់នៃសិក្ខាកាម ដែលបានមកចូលរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនមានសុទ្ធតែជាការជ្រើសរើសរបស់នាយកសាលា និងគម្រោងផ្ទាល់តែម្តង ដោយការជ្រើសរើសនោះមានការសម្រេចលើឯកទេស ឬមុខវិជ្ជាដែលជាតម្រូវការរបស់សាលា និងខ្លះទៀតផ្តោតលើអតីតភាពនៃការងាររបស់បុគ្គលិកដែលត្រូវរើស។ ឯលោកគ្រូអ្នកគ្រូជាសិក្ខាកាមខ្លះទៀតបានដាក់ពាក្យនៅមន្ទីរអប់រំ ហើយភាគច្រើនជាខេត្តឆ្ងាយៗដូចជា រតនគិរី និងមណ្ឌលគិរីជាដើម។

នាយកសាលាជាអ្នកផ្តើមក្នុងការទទួលយកគម្រោងមកអនុវត្ត និងមានឆន្ទៈចង់កែប្រែការបង្រៀននៅក្នុងសាលាឱ្យមានប្រសិទ្ធភាពជាងមុន។ ហេតុដូចនេះហើយ អ្នកគ្រប់គ្រងរួមនឹងមន្ត្រីអនុវត្តគម្រោងគឺ ជាអ្នកកំណត់មុខសញ្ញាលោកគ្រូអ្នកគ្រូដែលត្រូវបំប៉នចំណេះដឹងថ្មីពិសេស ជាលោកគ្រូអ្នកគ្រូដែលអាចមានឥទ្ធិពលបញ្ជ្រាបចំណេះដឹង និងវិធីសាស្ត្រទាំងឡាយទៅបុគ្គលិកបង្រៀនដទៃទៀត ព្រោះសាលានីមួយៗមានគ្រូបានមករៀនមានចំនួនតិចតួចនៅឡើយ។

### ៤.២.២-មូលហេតុនៃការចូលរៀន

**ក្រាបទី៥៖ ហេតុផលនៃការចូលរៀន**




យោងតាមការស្រង់មតិ និងក្រាបបង្ហាញថាទិសដៅនៃការចូលរៀនរបស់សិក្ខាកាមភាគច្រើន ដើម្បីចង់បានចំណេះដឹងដែលមានអត្រាខ្ពស់ជាងគេគឺ ៧៧.៨៦% និងក្រៅពីនោះមានហេតុផលពីរទៀតដូចជា ការចង់បាននូវសញ្ញាបត្រមាន ១៣.៧៤% និងចង់ប្តូរក្របខណ្ឌពីគ្រូកម្រិតមូលដ្ឋានមកជាគ្រូកម្រិតឧត្តមមាន ៨.៤០%។

ភាគច្រើននៃសិក្ខាកាមដែលមករៀនស្ទើរតែទាំងអស់ សុទ្ធតែប៉ងដើម្បីបំប៉នចំណេះដឹងបច្ចេកទេស បទពិសោធ វិធីសាស្ត្របង្រៀន និងចំណេះដឹងថ្មីផ្សេងៗ ពិសេសគឺ មុខវិជ្ជាឯកទេសក្នុងទិសដៅ យកទៅជំរុញនូវការបង្រៀនសិស្សឱ្យទទួលបានលទ្ធផលល្អប្រសើរជាងមុន ហើយឆ្លើយតបនឹងការពង្រឹងគុណភាពអប់រំនៅតាមសាលានីមួយៗផងដែរ។ ចំណែកហេតុផលដទៃទៀតវិញមានដូចជា ចង់បានសញ្ញាបត្រ និងចង់ប្តូរក្របខណ្ឌក៏ជាទិន្នន័យមួយគួរឱ្យកត់សម្គាល់ ។ សិក្ខាកាមមួយចំនួនចង់បានសញ្ញាបត្រដោយពួកគាត់យល់ថាការសិក្សាមានរយៈពេលតែ ២ឆ្នាំគឺ អាចទទួលបានសញ្ញាបត្របរិញ្ញាបត្រ និងមួយវិញទៀតពួកគាត់សង្ឃឹមថា

ក្រសួងអប់រំនឹងអាចប្តូរក្របខណ្ឌពីគ្រូបង្រៀនកម្រិតមូលដ្ឋាន ទៅជាគ្រូបង្រៀនកម្រិតឧត្តម ពេលបញ្ចប់វគ្គសិក្សា។

បើសង្កេតមើលលើគោលបំណង ដែលសិក្ខាកាមចង់បានភាគច្រើនសុទ្ធតែអាចទទួលយកបានព្រោះជាវាក៏គោលបំណងដែលក្រសួង និងសាលាចង់បានដែរ គឺដើម្បីតែការបំពេញសេចក្តីត្រូវការរបស់សាលា និងសិស្សានុសិស្សក្នុងសតវត្សថ្មីនេះ។ ប៉ុន្តែការចង់ប្តូរក្របខណ្ឌវិញ វាទើបជាការលំបាកពីព្រោះមិនទាន់មានសារាចរណែនាំណា ឬអនុក្រឹតណាដែលបញ្ជាក់ថា បញ្ចប់វគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននេះនឹងត្រូវបានប្តូរក្របខណ្ឌជាគ្រូបង្រៀនកម្រិតឧត្តមនៅឡើយ។ ដូចនេះហើយបញ្ហានេះ ស្ថិតនៅតែជាបញ្ហាសម្រាប់ចំណាត់ការរបស់ក្រសួងអប់រំដដែល។

## ៤.៣-ទស្សនៈអំពីពេលវេលានៃការសិក្សា

កម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន បានកំណត់ពេលសិក្សានៅចុងសប្តាហ៍គឺថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ រយៈពេលពីរឆ្នាំ ដើម្បីរក្សានិរន្តភាពការងារនៅតាមសាលាផង និងអាចឱ្យសិក្ខាកាមមករៀនបានដោយមិនប៉ះពាល់ដល់ការងារបង្រៀនផង។ ក្នុងកំឡុងរយៈពេលពីរថ្ងៃចុងសប្តាហ៍ វគ្គតម្រូវឱ្យសិក្ខាកាមទាំងប្រាំមួយមុខវិជ្ជារៀន ៩ម៉ោងក្នុងមួយថ្ងៃគឺ ព្រឹកពីម៉ោង៧ដល់ម៉ោង ១១និង៣០នាទី ល្ងាចពីម៉ោង ១ដល់ម៉ោង ៥និង៣០នាទី ដើម្បីបំពេញតាមក្រេឌីដដែលបានកំណត់។ ដូច្នេះហើយ សិក្ខាកាមទាំងអស់ត្រូវការការខិតខំប្រឹងប្រែងច្រើនដើម្បីទទួលយកចំណេះដឹងក្នុងវគ្គ និងតាមរយៈការអនុវត្តនេះសិក្ខាកាមទាំងអស់ បានផ្តល់ទស្សនៈមួយចំនួនដូចខាងក្រោម៖

**ក្រាបទី៦៖ ទស្សនៈពីពេលវេលាសិក្សា**



ទាក់ទងទៅនឹងពេលវេលានៃការសិក្សា ជារួមលោកគ្រូអ្នកគ្រូដែលឯកភាពទាំងស្រុង មាន ៤៧.៦២% គឺជិតពាក់កណ្តាលនៃសិក្ខាកាមទាំងអស់ និងមិនឯកភាពលើការកំណត់រយៈនេះមាន រហូត ២៨.៥៧%។ ទន្ទឹមនឹងនេះក៏មានសិក្ខាកាម ២៣.៨១%ដែរដែលយល់ថាវាការធម្មតាសម្រាប់។

សិក្ខាកាមជិតពាក់កណ្តាលគឺ មានការយល់ស្របទាំងស្រុងលើការកំណត់រយៈពេលនៃការសិក្សារបស់វគ្គព្រោះពួកគាត់យល់ថា ពេលវេលានេះអាចឱ្យគាត់បានមករៀនបណ្តុះបណ្តាលបន្ថែមចំណេះដឹងផង និងអាចបំពេញការងារនៅសាលារបស់ពួកគាត់ផងដែរដោយមិនមានការប៉ះពាល់អ្វីឡើយ ហើយម្យ៉ាងទៀត ជាពេលចុងសប្តាហ៍ទំនេរពីការបង្រៀន ហើយសិក្សាតែរយៈពេល ២ឆ្នាំនឹងអាចទទួលបានសញ្ញាបត្រថ្នាក់បរិញ្ញាបត្រ ពិសេសខ្លឹមសារមេរៀនសមស្របនឹងពេលវេលាផងដែរ។ ប៉ុន្តែអ្វីដែលគួរឱ្យកត់សម្គាល់ ទិន្នន័យសិក្ខាកាមដែលមិនយល់ស្របក៏មានអត្រាខ្ពស់ដែរ ហើយតាមរយៈចម្លើយរបស់ពួកគាត់យល់ឃើញថា ការសិក្សានេះមានរយៈពេលមិនសាកសមឡើយ ព្រោះពេលវេលាខ្លីពេក ក្នុងមួយថ្ងៃៗ សិក្ខាកាមត្រូវរៀនរហូតដល់ ៩ម៉ោង ដែលជាពេលវេលាមួយច្រើនពេក មិនសូវបានសម្រាក ពោលគឺ ការងារស្រាវជ្រាវច្រើន និងមុខវិជ្ជារៀនក៏ច្រើន មិនសមនឹងពេលវេលា ការធ្វើដំណើរឆ្ងាយមានការនឿយហត់ រៀនមិនសូវចូលដោយសារបញ្ហាសុខភាព។ ព្រមជាមួយនេះក៏មានសិក្ខាកាមខ្លះដែលគាត់គិតថាពេលវេលានេះមិនមានបញ្ហាអ្វីសម្រាប់គាត់ដែរ។

ការកំណត់ពេលវេលាសិក្សាជាការងារងាយស្រួល ប៉ុន្តែការកំណត់ពេលឱ្យបានត្រឹមត្រូវ និងអាចទទួលយកបានទាំងអស់ទើបវាជាការលំបាក។ ជាការពិត ការអនុវត្តការងារច្រើនក្នុងពេលវេលាតែមួយ ហើយចង់ឱ្យបានលទ្ធផលល្អនោះ មិនមែនជាការងាយស្រួលឡើយ។ យ៉ាងណាមិញកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនត្រូវសិក្សាតែរយៈពេល ២ឆ្នាំ និងផ្តល់ជូននូវសញ្ញាបត្រស្មើនឹងកម្រិតបរិញ្ញាបត្រដែលជាទូទៅត្រូវរៀន ៤ឆ្នាំយ៉ាងតិច។ ហេតុដូច្នេះហើយ ការកំណត់ពេលវេលាសមរម្យ ជាការសំខាន់ព្រោះវាពាក់ព័ន្ធនឹងបរិយាកាសសិក្សាលក្ខខណ្ឌការងារប្រចាំថ្ងៃ រួមផ្សំនឹងបញ្ហាសុខភាពផងដែរ។

## ៤.៤-ទស្សនៈអំពីសមត្ថភាព និងកម្មវិធីសិក្សា

### ៤.៤.១-សមត្ថភាពសិក្ខាកាមធៀបនឹងកម្មវិធីសិក្សា

**ក្រាបទី៧៖ កម្មវិធីសិក្សា និងសមត្ថភាពសិក្ខាកាម**




ឆ្លងតាមក្រាប បញ្ជាក់ឱ្យដឹងពីការយល់ឃើញរបស់សិក្ខាកាមទាក់ទងនឹងសមត្ថភាព លោកគ្រូអ្នកគ្រូដែលមកបំប៉នធៀបនឹងកម្មវិធីសិក្សាដែលបានដាក់ឱ្យបង្រៀន ដោយអត្រានៃការយល់ស្របមានចំនួន ៦៨.៥៧% ដែលមានលក្ខណៈបង្គួរ។ ចំណែកទិន្នន័យដែលយល់ថា មិនទាន់សមស្របមាន ២៦.៦៧% មិនសមស្របមាន ២.៨៦% និងមិនដឹងច្បាស់មាន ១.៩០%។

តាមរយៈការដកស្រង់នូវចម្លើយ និងការវិភាគទិន្នន័យ កម្មវិធីសិក្សាដែលបានដាក់ចេញនេះសិក្ខាកាមអាចទទួលយកបានព្រោះពួកគាត់គិតថា មានចំណេះដឹង និងវិធីសាស្ត្រល្អៗជាច្រើនដែលពួកគាត់បានទទួល និងបានអនុវត្តផ្ទាល់នៅសាលាគាត់ផងដែរ។ ចំណែកសិក្ខាកាមមួយចំនួនទៀតយល់ថាមិនទាន់សមស្រប និងមិនសមស្របនឹងទទួលយកបានទេ ដោយពួកគាត់សង្កេតឃើញថា គ្រូដែលមករៀនជាគ្រូចាស់ៗ ហើយសមត្ថភាពនៅមានកម្រិតទាប មេរៀនខ្លះជ្រៅ និងថ្មីពេក មិនធ្លាប់ដឹងពីមុនមកសោះ ពិសេសគឺមេរៀនស្រាវជ្រាវច្រើន មិនសក្តិសមពេលវេលាសិក្សា។ ម្យ៉ាងវិញទៀតការសិក្សាច្រើនមុខវិជ្ជា ហើយច្រើនម៉ោងមួយថ្ងៃ គ្រូឧទ្ទេសបង្រៀនតាមក្រេឌីតដែលបង្រៀនលឿនពេកចាប់មិនសូវបាន ណាមួយមេរៀនខ្លះហាក់ដូចជាចាកឆ្ងាយមុខវិជ្ជាឯកទេស និងមិនសូវចំទិសដៅដែលសិក្ខាកាមចង់បាន។

ការបណ្តុះបណ្តាលដែលទទួលបានប្រសិទ្ធភាពខ្ពស់ គួរតែអាចបំពេញបាននូវតម្រូវការនៃអ្នកសិក្សា និងអាចស្គាល់ពីអ្នកសិក្សាឱ្យបានច្បាស់មុនការបណ្តុះបណ្តាលជារឿងមួយកាន់តែប្រសើរថែម ទៀត។ ជាទូទៅកម្មវិធីសិក្សាណាក៏មិនអាចបំពេញបានឱ្យស្មើភាពគ្នាទៅលើសមត្ថភាពនៃអ្នកសិក្សាដែរ ប៉ុន្តែត្រូវមានសមស្របទៅនឹងសមត្ថភាពនៃសិក្សាភាគច្រើន។

ម្យ៉ាងវិញទៀត អ្នករៀបចំការបណ្តុះបណ្តាលដាច់ខាតត្រូវយកចិត្តទុកដាក់លើសិក្ខាកាមដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការរៀនសូត្រ និងទទួលយកចំណេះដឹងទាំងអស់។

### ៤.៤.២-កម្មវិធីសិក្សា

ក្រាបទី៨៖ ទស្សនៈពីកម្មវិធីសិក្សា




បើផ្តោតទៅលើកម្មវិធីសិក្សាក្នុងវគ្គទាំងមូល ជារួមសិក្ខាកាមយល់ថាល្អមានអត្រាខ្ពស់ជាងគេស្មើនឹង ៦៥.៧១% និង អត្រាល្អណាស់មាន ២៣.៨១% ។ ចំណែកអ្នកដែលគិតថាមិនទាន់ល្អមាន ៩.៥២% និងមិនល្អទេមាន ០.៩៥% ដែលសរុបមិនទាន់ល្អ និងមិនល្អផងមាន ១០.៤៧%។

ស្ទើរតែ ៩០%នៃសិក្ខាកាមយល់ថាកម្មវិធីសិក្សាទាំងមូលមានលក្ខណៈល្អគួរអាចទទួលយកបាន ព្រោះបានផ្តល់មេរៀនល្អ គំនិតល្អ បទពិសោធ បច្ចេកទេស និងវិធីសាស្ត្រទោះបីមានមេរៀនខ្លះត្រូវការកម្រិតយល់ដឹងខ្ពស់ក៏ដោយ ហើយអ្វីដែលសំខាន់ពួកគាត់យល់ថាគឺ ជាហេតុផលផ្ទាល់ខ្លួនរបស់គាត់ទាក់ទងទៅនឹងសមត្ថភាពទទួលយកទៅវិញទេ។ ឯលោកគ្រូអ្នកគ្រូមួយចំនួននៅតែគិតថាមិនសមស្របទេ ព្រោះមេរៀនខ្លះជ្រៅៗពេក ពិសេសវាចាកឆ្ងាយឯកទេស និងពីអ្វីដែលគាត់ត្រូវអនុវត្តនៅសាលាជាក់ស្តែងរបស់គាត់។

ការកែប្រែ និងផ្លាស់ទម្លាប់នៃការបង្រៀន និងរៀនរបស់សិស្សនៅតាមសាលានីមួយៗ គឺ ពិតជាលំបាក ដែលក្រសួងសម្រេចធ្វើការកែទម្រង់កាប្រឡង និងចុងក្រោយបានផ្តោតលើការបង្រឹងសមត្ថភាពនៃមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ស្របតាមគោលនយោបាយទី២របស់ក្រសួង

អប់រំផងដែរ។ ហេតុនេះការចាប់ផ្តើមពីគ្រូបង្រៀនមុនគេ ជាការងារចាំបាច់ណាស់ ព្រោះគ្រូជាអ្នកដែលនៅជិតសិស្សជាងអ្នកណាៗទាំងអស់ ហើយគាត់ត្រូវមានសមត្ថភាពទាំងចំណេះដឹង និងវិធីសាស្ត្រក្នុងការផ្ទេរទៅសិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពថែមទៀត។

## ៤.៥-វិធីសាស្ត្របង្រៀន និងការប្រតិបត្តិ

តាមរយៈការសិក្សា សិក្ខាកាមទាំងអស់សុទ្ធតែបានទទួលនូវចំណេះដឹង បទពិសោធ និងវិធីសាស្ត្រល្អៗក្នុងការពង្រឹងគុណភាពរៀន និងបង្រៀនដែលវិធីសាស្ត្រទាំងនោះតម្រូវឱ្យសិក្ខាកាមទាំងអស់ចេះប្រើប្រាស់ បត់បែនតាមកាលៈទេសៈ តាមស្ថានភាព និងសមត្ថភាពរបស់សិស្សានុសិស្សផងដែរ ព្រមទាំងត្រូវចេះច្នៃបង្កើតវិធីសាស្ត្រងាយដែលអាចឱ្យសិស្សឆាប់ចេះ និងមានគុណភាពប្រសើរជាងមុន។ វិធីសាស្ត្រទាំងនោះមានដូចជា វិធីសាស្ត្ររិះរក(IBL) ស្ថាបនានិយម បញ្ញត្តិនិយម គុក្កុតាគំនិត វិធីសាស្ត្រសួរសំណួរ គ្រាប់តាម ប្លុំមតាក់សូណូមី ពិសោធវិទ្យាសាស្ត្រ សហការ ឧទ្ទេស សិស្សមជ្ឈមណ្ឌល លើកទឹកចិត្ត សូក្រាត អនុមានញែក អនុមានរួម និងវិធីសាស្ត្រស្រាវជ្រាវអប់រំជាដើម។ ទន្ទឹមនឹងការសិក្សានេះដែរ សិក្ខាកាមទាំងអស់ក៏បានយកទៅអនុវត្តនៅសាលារៀងៗខ្លួនផងដែរ ហើយបង្ហាញនូវការយល់ឃើញលើសមត្ថភាពនៃការប្រើប្រាស់វិធីសាស្ត្រទាំងនោះតាមរយៈទិន្នន័យដូចក្នុងក្រាបខាងក្រោមនេះ៖

**ក្រាបទី៩៖ ការប្រើប្រាស់វិធីសាស្ត្របង្រៀន**




ផ្អែកតាមក្រាបបង្ហាញថា ក្រោយទទួលបានចំណេះដឹងផ្សេងៗពីវគ្គ សិក្ខាកាមភាគច្រើនគឺ ៧២.៣៨% គិតថាអាចយកចំណេះដឹង និងវិធីសាស្ត្រទាំងនោះទៅអនុវត្តបាននៅតាម

សាលារបស់ពួកគាត់ និង ២០.៩៥% គិតថាអាចប្រើប្រាស់បានខ្លះ ហើយនិង ៦.៦៧% យល់ថាមិនអាចយកទៅអនុវត្តបានឡើយ។

លោកគ្រូអ្នកគ្រូភាគច្រើន អាចយកវិធីសាស្ត្រដែលបានរៀនទាំងអស់ទៅអនុវត្តបាននៅតាមសាលារបស់ពួកគាត់ ដោយផ្តល់អំណះអំណាងមួយចំនួនថា កំឡុងពេលរៀនពួកគាត់សុទ្ធតែបានសាកល្បងជាមួយសិស្សរួចហើយ ពោលគឺពួកគាត់យល់ថាជាវិធីសាស្ត្រល្អ មានភាពបត់បែនបានច្រើនយ៉ាងផ្អែកតាមស្ថានភាពរបស់សិស្ស និងធ្វើឱ្យពួកគេទាំងអស់មានការចាប់អារម្មណ៍ និងសកម្មជាងមុន។ ព្រមជាមួយគ្នានេះសិក្ខាកាមផ្សេងទៀត គិតវិធីទាំងអស់នោះអាចអនុវត្តបានតែមួយចំនួនប៉ុណ្ណោះព្រោះនៅតាមសាលាចំនួនសិស្សច្រើន និងត្រូវការពេលវេលាក៏ច្រើនដែរ ដែលវាមិនសមនឹងម៉ោងសិក្សានៅសាលា គ្រូមិនបានមករៀនច្រើនជាងគ្រូដែលបានរៀន ជាហេតុធ្វើឱ្យមិនសូវមានការសហការ ពេលខ្លះគណៈគ្រប់គ្រងក៏មិនសូវជួយសម្របសម្រួលដែរ រីឯសិស្សខ្លះមិនចូលចិត្តមេរៀនបែបស្រាវជ្រាវទៀត។ ទន្ទឹមនឹងនេះក៏មានសិក្ខាកាម ដែលគិតថាមិនអាចយកទៅអនុវត្តនៅសាលាខ្លួនបានដែរ ដោយហេតុថាមានការខ្វះខាតច្រើនលើសម្ភារឧបទ្ទេស សម្ភារសិក្សា វិធីសាស្ត្រភាគច្រើនត្រូវការពេលវេលាច្រើនដើម្បីអនុវត្ត និងចំណេះដឹងរបស់សិស្សតាមសាលានៅមានកម្រិតនៅឡើយ។

ការសិក្សាពីទ្រឹស្តីគួបផ្សំជាមួយការអនុវត្តជាក់ស្តែង អាចឱ្យសិក្ខាកាមមានភាពរឹងមាំលើការ ងារបង្រៀនជាជាងគ្រាន់តែបង្រៀនពីទ្រឹស្តី។ កម្មវិធីសិក្សានៅក្នុងវគ្គនេះ បានផ្តោតជាសំខាន់លើការសិក្សាឯកទេស និងវិធីសាស្ត្រ រួមផ្សំនឹងការយកកិច្ចការ និងវិធីសាស្ត្រទាំងនោះទៅអនុវត្តនៅសាលាជាក់ស្តែងផងនោះ អាចធ្វើឱ្យពួកគាត់មានបទពិសោធច្រើន ព្រោះជាទូទៅពេលដែលពួកគាត់មានបញ្ហាកំឡុងពេលអនុវត្ត គឺតែងមានការកែលម្អពីគ្រូឧទ្ទេសក្នុងវគ្គ។ ដូចនេះ ការយកចិត្តទុកដាក់របស់សិក្ខាកាមក្នុងការអនុវត្តតាមគោលការណ៍របស់គម្រោងជាការងារសំខាន់ និងជួយចូលរួមកែលម្អការបង្រៀនរបស់គ្រូដែលមិនបានមករៀនឱ្យមានភាពល្អប្រសើរធៀបនឹងស្តង់ដាររគម្រោងចង់បាន។

## ៤.៦-បញ្ហាប្រឈម និងដំណោះស្រាយ

### ៤.៦.១-បញ្ហាប្រឈម

**ក្រាបទី១០៖ បញ្ហាប្រឈម**




តាមរយៈក្រាបគេសង្កេតឃើញថា មានបញ្ហាប្រឈមជាច្រើនដែលលេចឡើងនៅក្នុងវគ្គសិក្សានេះប៉ុន្តែបញ្ហាប្រឈមដែលមានអត្រាខ្ពស់ជាងគឺ ការធ្វើដំណើរមាន ៣០.២៣% និងបញ្ហាប្រឈមធំទី២គឺថវិកាចំណាយដែលវគ្គបានផ្តល់ជូនមាន ២៦.៥១% ហើយនិងប្រឈមទី៣សំដៅលើភាសាបរទេសមាន ១៥.៨១%។ ចំណែកឯបញ្ហាប្រឈមដទៃទៀតមានអត្រាតិចតួចដូចជា វិធីសាស្រ្តបង្រៀន ៩.៣០% មុខវិជ្ជាឯកទេស ៨.៣៧% ខ្លឹមសារ ៧.៤៤% សម្ភារឧបទេស ០.៩៣% និងបច្ចេកទេស ICTមាន ០.៤៧%។ ក្រាបនេះក៏បង្ហាញពីដែលអ្នកគិតថាមិនមានបញ្ហាប្រឈមសោះមាន ០.៩៣%ដែរ។

បញ្ហាប្រឈមដែលមានអត្រាខ្ពស់ជាងគេក្នុងចំណោមបញ្ហាទាំងអស់គឺ ការធ្វើដំណើរ ព្រោះថាភាគច្រើននៃសិក្ខាកាមមកសិក្សាជាគ្រូបង្រៀននៅតាមខេត្តផ្សេងៗ ដូចជារបាត់ដំបង រតនគិរី និងមណ្ឌលគិរីជាដើម ហើយម្យ៉ាងវិញទៀត បញ្ហានេះមានការទាក់ទងទៅនឹងបញ្ហាថវិកាដែលជាបញ្ហាចម្បងទីពីរផងដែរ ដោយហេតុថាសិក្ខាកាមដែលមកពីខេត្តភាគច្រើនមិនចង់ធ្វើដំណើរមកនៅថ្ងៃសុក្រមុនការសិក្សា ព្រោះត្រូវចំណាយលើថ្លៃស្នាក់នៅមួយយប់ទៀត។ ដូចនេះ ទើបពួកគាត់សម្រេចចិត្តធ្វើដំណើរទាំងយប់ថ្ងៃសុក្រ ដើម្បីឱ្យមកទាន់រៀននៅព្រឹងថ្ងៃសៅរ៍ ដែលជាហេតុនាំឱ្យមានបញ្ហាប្រឈមនឹងសុវត្ថិភាពច្រើន ពេលខ្លះក៏មានការយឺតយ៉ាវ និងមិនមានអារម្មណ៍ក្នុងការសិក្សាដែរ។ ឯបញ្ហាថវិកានេះទៀតសោត សិក្ខាកាមមួយចំនួនយល់ថាមានចំណាយច្រើន របស់របរថ្លៃៗ និងត្រូវចំណាយថវិកាផ្ទាល់ខ្លួនបន្ថែមទៀត ហើយជួនកាល ការបើកប្រាក់ឧបត្ថម្ភនៅតាមសាលាខ្លះមានការយឺតយ៉ាវទៀតផង។ បញ្ហាមួយទៀត

ដែលគួរឱ្យកត់សម្គាល់ដែរគឺ ភាសាបរទេស ដោយពួកគាត់ផ្ដល់មូលហេតុខ្លះថា មកពីលោកគ្រូអ្នកគ្រូចាស់ពីមុនមិនសូវបានរៀនភាសា ពិសេសពាក្យបច្ចេកទេស និងមេរៀនជាច្រើនដែលត្រូវការភាសាអង់គ្លេសដើម្បីស្វែងយល់ ប៉ុន្តែពួកគាត់ត្រូវការខិតខំប្រឹងប្រែងច្រើននៅត្រង់ចំណុចនេះ។ ក្រៅពីបញ្ហាទាំងបីនេះ បញ្ហាដទៃទៀតក៏មានកើតឡើងផងដែរប៉ុន្តែគ្រាន់តែជាបញ្ហាប្រឈមបន្ទាប់បន្សំប៉ុណ្ណោះ និងអាចដោះស្រាយបាន ដូចជា ខ្លឹមសារមេរៀន (មេរៀនខ្លះជ្រៅពេក ពិបាកយល់ មេរៀនច្រើនពេលវេលាតិច) មុខវិជ្ជាឯកទេស (មេរៀនដូចជាចាកឆ្ងាយពីឯកទេសពេក ខ្ពស់ជាងអ្វីដែលនៅសាលាជាក់ស្ដែង) វិធីសាស្ត្រមាន (វិធីសាស្ត្រថ្មីពេក ច្រើនពេក ពិបាកអនុវត្តដោយសារស្ថានភាពសិស្សមិនដូចគ្នា) សម្ភារឧបទេសមាន (សាលាភាគច្រើនខ្វះសម្ភារអនុវត្ត) និងបច្ចេកទេស ICT (មានការប្រើបច្ចេកវិទ្យាច្រើន និងមិនសូវមានមូលដ្ឋានគ្រឹះពីមុន)។

ដោយសារមានគាំទ្រពីគម្រោង SEIP របស់ធនាគារពិភពលោក រួមនឹងក្រសួងអប់រំ យុវជន និងកីឡា ហើយវាជាគម្រោងថ្មីមួយ និងដូចជាការសាកល្បងដែរ។ ដូចនេះហើយទើបការអនុវត្តមានជួបនូបញ្ហាប្រឈមជាច្រើន និងត្រូវធ្វើការដោះស្រាយ ដូចការមករៀនម្ដងៗដែលសិក្ខាកាមត្រូវធ្វើដំណើរផ្លូវឆ្ងាយប្រឈមមុខនឹងបញ្ហាសុវត្ថិភាពច្រើនតាមផ្លូវ ដោយវគ្គសិក្សានេះមានតែនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមួយប៉ុណ្ណោះ។ ការផ្ដល់ជូននូវភាពងាយស្រួលសម្រាប់លោកគ្រូអ្នកគ្រូដែលចង់រៀន អាចធ្វើឱ្យដំណើរការនៃវគ្គមានភាពល្អប្រសើរ និងទទួលបាននូវផលតបស្នងជាវិជ្ជមានផងដែរ។

### ៤.៦.២-ដំណោះស្រាយ

**ក្រាបទី១១៖ ដំណោះស្រាយបញ្ហាប្រឈម**



ក្រាបខាងលើនេះបង្ហាញថា អត្រានៃការដោះស្រាយបញ្ហាប្រឈមបានខ្លះមានភាគរយខ្ពស់ជាងគេស្មើនឹង ៥៥.៧១% និងដោះស្រាយបានមាន ៧.៦២% រីឯទិន្នន័យមិនទាន់បានដោះស្រាយវិញមាន ៣១.៤៣% ហើយនិងមិនមានដំណោះស្រាយសោះមាន ១៣.៣៣%។ បើមើលលើការដោះស្រាយទាំងពីរគឺ ដោះស្រាយបាន និងបានខ្លះមានជាង ៥០%ដែរ។

បើសង្កេតមើលបញ្ហាប្រឈម និងដំណោះស្រាយនៅមិនទាន់មានតុល្យភាពគ្នានៅឡើយ ព្រោះការដោះស្រាយនេះគ្រាន់តែបានដោះស្រាយលើបញ្ហាតូចតាចដូចជា ខ្លឹមសារមេរៀន វិធីសាស្ត្របង្រៀន និងបច្ចេកទេសខ្លះប៉ុណ្ណោះ ប៉ុន្តែបញ្ហាដែលប្រឈមខ្លាំងដូចជា ការធ្វើដំណើរ ថវិកា និងភាសា គឺមិនទាន់មានដំណោះស្រាយឡើយ ភាគច្រើនសិក្ខាកាមជាអ្នកទទួលបន្ទុកដោះស្រាយដោយខ្លួនឯង ហើយមួយវិញទៀត ទិន្នន័យពីការមិនទាន់ដោះស្រាយ និងមិនមានដំណោះស្រាយមានអត្រាខ្ពស់ទៀតផង។ បើគិតជារួមការដោះស្រាយបញ្ហាប្រឈមទាំងឡាយដែលកើតមានឡើងស្ទើរតែមិនមានឡើយ ថ្វីត្បិតតែអត្រានៃការដោះស្រាយបានខ្លះមានចំនួនខ្ពស់ជាងគេក៏ដោយ។

ការអនុវត្តគម្រោងនីមួយៗ ជាទូទៅគេតែងគិតទៅលើដំណើរការ បញ្ហាប្រឈមឬផលប៉ះពាល់ និងលទ្ធផលរំពឹងទុក តាមរយៈការធ្វើការសាកល្បង ពិនិត្យ តាមដាន និងវាយតម្លៃត្រឹមត្រូវ។ មិនត្រឹមតែប៉ុណ្ណោះគេក៏គិតផងដែរថា បើមានបញ្ហាអ្វីមួយកើតឡើង តើគេនឹងដោះស្រាយដោយវិធីណា និងមានវិធានការអ្វីខ្លះ។ បញ្ហាប្រឈមទាំងអស់ ពេលខ្លះត្រូវការការចូលរួមសិក្សាឱ្យបានច្បាស់លាស់ និងដោះស្រាយពីភាគីពាក់ព័ន្ធទាំងទើបអាចមានប្រសិទ្ធភាព និងប្រសិទ្ធផល។

## ៤.៧- ប្រសិទ្ធភាព និងនិរន្តរភាពនៃវគ្គ

### ៤.៧.១-ការអនុវត្តជាក់ស្តែង

**ក្រាបទី១២៖ ការអនុវត្តជាក់ស្តែង**



ចំពោះលទ្ធភាពនៃការអនុវត្តអ្វីដែលបានរៀនពីវគ្គវិញគឺ ភាគច្រើនមាន៥៣.៣៣% គិតថាអាច យកទៅប្រតិបត្តិបានចន្លោះពី ៥០%ទៅ៦៥% ប៉ុណ្ណោះ និង ២២.៨៦% អាចអនុវត្តបានពី ៦៥%ទៅ ៨០%។ ចំណែកសិក្ខាកាមមានរហូតដល់ ១៨.១០%គិតថាអនុវត្តបាន ៥០%ឬក្រោម៥០% ដែលជាទិន្នន័យគួរឱ្យកត់សម្គាល់ ហើយពិសេសជាងនេះទៀត ការអនុវត្តបានចន្លោះពី ៨០%ទៅ១០០%មានតែ ៤.៧៦% ប៉ុណ្ណោះ។

តាមការស្ទង់មតិ ក្រោយពីបានទទួលការសិក្សាពីចំណេះដឹង និងវិធីសាស្រ្តទាំងឡាយ អត្រាលទ្ធភាពនៃសិក្ខាកាម ក្នុងអនុវត្តតាមគម្រោងនៅមានកម្រិតនៅឡើយ ព្រោះពួកគាត់គិតថាអ្វីៗដែលគាត់បានទទួលបានពីវគ្គសិក្សា ពេលខ្លះក៏មិនទាន់យល់ច្បាស់ និងស្ថានភាពនៅតាមសាលា និងកន្លែងសិក្សាមិនដូចគ្នា ដោយសាលាជាក់ស្តែងមានពេលវេលាតិច តែវិធីសាស្រ្តទទួលបានត្រូវការពេលវេលាច្រើន។ ម៉្យាងវិញទៀត វិធីសាស្រ្តថ្មីពេក សិស្សមិនសូវទទួលបាន ពិសេសគឺចំណេះដឹងសិស្សនៅតាមសាលានៅមានកម្រិតទាបនៅឡើយ ហើយសាលាមិនមានសម្ភារឧបទេសគ្រប់គ្រាន់ឡើយ ដូចជាសម្ភារពិសោធជាដើម។ លើសពីនេះទៅទៀត ក្នុងមួយសាលា មានលោកគ្រូអ្នកគ្រូដែលមិនបានមករៀនច្រើន ហើយមិនសូវទទួលយកវិធីសាស្រ្តថ្មី នៅតែអនុវត្តវិធីសាស្រ្តចាស់នៅឡើយ។ បន្ថែមលើសពីនោះគឺ សិស្សនៅវិទ្យាល័យមានចំនួនច្រើន និងមិនងាយក្នុងការកែទម្លាប់ចាស់របស់សិស្សឡើយ។ ក្រៅពីនេះសិក្ខាកាមដែលយល់ថាអាចអនុវត្តបាន ដោយពួកគាត់ផ្តល់គំនិតថាវាការតម្រូវរបស់សម័យកាល ព្រមទាំងមានការគាំទ្រពីសាលា និងគម្រោងទាំងមូល ដូចនេះត្រូវតែអនុវត្តឱ្យបានប្រសើរជាងមុន។

ជាការពិតគ្រប់ការងារទាំងអស់ ត្រូវធ្វើដោយយកចិត្តទុកដាក់ និងមានមនសិការខ្ពស់ទើបអាចទទួលបានលទ្ធផលល្អ។ យ៉ាងណាមិញនៅក្នុងសាលាក៏ដូច្នោះដែរ ត្រូវមានការប្តេជ្ញាចិត្តចូលរួមធ្វើការងារដោយមិនរុញរាពីសំណាក់លោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រងទាំងអស់។ បើសិនជា លោកគ្រូអ្នកគ្រូ រួមនិងអ្នកគ្រប់គ្រងទាំងអស់មានការព្យាយាម ខិតខំប្រឹងប្រែងប្រកបដោយទឹកចិត្តចង់លើកកម្ពស់គុណភាពអប់រំនៅក្នុងសាលាឱ្យមានលក្ខណៈល្អប្រសើរជាងមុន គឺប្រាកដជាអាចធ្វើបាន។

### ៤.៧.២-ទស្សនៈអំពីវគ្គសិក្សា TUP

**ក្រាបទី១៣៖ ទស្សនៈអំពីវគ្គ**




តាមក្រាបបង្ហាញថា សិក្ខាកាមមានការពេញចិត្តលើវគ្គមាន ៥៦.១៩% ដែលជាទិន្នន័យខ្ពស់ជាងគេធៀបនឹងអត្រាផ្សេងៗទៀត។ បន្ទាប់ពីនោះគឺ ពេញចិត្តណាស់មាន ៣៩.០៥% និងមិនសូវពេញចិត្តមានតែ ៤.៧៦%ប៉ុណ្ណោះ។ តាមទិន្នន័យនេះបញ្ជាក់ថា សិក្ខាកាមមានអារម្មណ៍វិជ្ជមានច្រើនលើវគ្គសិក្សានេះ។

បើសរុបទិន្នន័យទាំងពេញចិត្ត និងពេញចិត្តណាស់ស្មើនឹង ៩៥.២៤% ដែលបញ្ជាក់ថា ស្ទើរតែទាំងអស់នៃសិក្ខាកាម បានមករៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន សុទ្ធតែមានការពេញចិត្ត និងយល់ស្របចំពោះការបង្កើតឡើង ក៏ដូចជាការរៀបចំដំណើរការបណ្តុះបណ្តាលទាំងមូលដូច្នោះដែរ ព្រោះពួកគេយល់ឃើញថា វគ្គនេះមានចំណុចល្អៗជាច្រើនដូចជាការផ្តល់ចំណេះដឹង បច្ចេកទេស បទពិសោធ និងបែបបទនៃការសិក្សាថ្មីៗដែលពួកគាត់មិនដែលបានជួបពីមុន ពិសេសគឺ វិធីសាស្ត្របង្រៀនល្អៗ ដែលគ្រូៗអាចប្រើប្រាស់ដោយមានការបត់បែនតាមចំណេះដឹងច្រើនជាងមុន និងជាវិធីសម្រាប់ជាសេចក្តីត្រូវការរបស់សិស្សសម័យសតវត្សទី២១នេះផងដែរ។ ម៉្យាងវិញទៀត វគ្គនេះបានជួយបំពេញការខ្វះខាតលើចំណេះដឹងឯកទេសបានមួយចំនួន ហើយជាសំខាន់ការសិក្សានេះបានជួយកែប្រែនូវឥរិយាបថអវិជ្ជមានមួយចំនួននៅសាលារៀនរបស់គាត់ដូចជា ការគោរពពេលវេលាបង្រៀន ការគោរពក្រមសីលធម៌វិជ្ជាជីវៈ ពោលគឺ មានការអនុវត្តការងារបានប្រសើរជាងមុន ព្រោះពីមុនការងារមានភាព

យឺតយ៉ាវ ស្ពឹកស្រពន់ និងមិនសូវមានការយកចិត្តទុកដាក់ប៉ុន្មានឡើយ។ ទន្ទឹមនឹងការពេញចិត្តនេះក៏នៅមានភាពអវិជ្ជមានមួយចំនួនដែរ ដោយពួកគាត់យល់ឃើញថា វគ្គសិក្សានេះនៅមានចំណុចខ្វះខាតខ្លះដូចជា ការសិក្សាមានសភាពដូចជា ចាប់បញ្ច្រកចំណេះដោយរយៈពេលសិក្សាខ្លី ឯកម្មវិធីសិក្សាច្រើន ហើយមួយវិញទៀតសិក្ខាកាមខ្លះយល់ថា ការសិក្សាលើផ្នែកឯកទេសបានតិចតួច ភាគច្រើនផ្តោតតែទៅលើការសិក្សាស្រាវជ្រាវ និងផ្នែកអប់រំច្រើនពេក ឯអ្នកសិក្សាភាគច្រើនសុទ្ធតែមកពីខេត្តដែលត្រូវធ្វើមករៀនរៀងរាល់សប្តាហ៍ មិនងាយបានជុំក្រុម ធ្វើការងារមិនទាន់ និងណាមួយកំពុងមានភារកិច្ចបង្រៀននៅសាលាទៀតផង។

វគ្គសិក្សាទាំងមូលបានផ្តល់ចំណេះដឹងថ្មីៗជាច្រើនក្នុងការពង្រឹង និងបង្កើនសមត្ថភាពការងាររបស់លោកគ្រូអ្នកគ្រូកម្រិតមូលដ្ឋាន ឱ្យមានកម្រិតយល់ដឹងប្រហាក់ប្រហែលនឹងគ្រូបរិញ្ញាបត្រ ទោះបីមានការខ្វះខាតលើចំណុចខ្លះ និងត្រូវមានដំណោះស្រាយក៏ដោយ ក៏វាជាយន្តការកែទម្រង់មួយដែលមានសារៈសំខាន់ដែរ។ មិនត្រឹមតែប៉ុណ្ណោះ វគ្គបានចូលរួមក្នុងការកែប្រែទម្លាប់អវិជ្ជមានមួយចំនួនពីមុនៗមក ដូចជាការមិនគោរពពេលវេលា និងការមិនគោរពវិន័យការងារជាដើម ដែលជាជម្ងឺកើតឡើងជាយូរយារណាស់មកហើយ។ ហេតុនេះ អ្វីដែលទទួលបានពីវគ្គសិក្សានេះ គួរតែត្រូវបានអនុវត្តឱ្យអស់ពីលទ្ធភាព និងមនសិការខ្ពស់។

### ៤.៧.៣-និរន្តភាពនៃវគ្គ

**ក្រាបទី១៤៖ និរន្តភាពនៃវគ្គ**




យោងតាមក្រាបបង្ហាញថា សិក្ខាកាមទាំងអស់ ១០០% ចង់ឱ្យមានវគ្គសិក្សានេះបន្តទៀត ដោយមិនមានសិក្ខាកាមណាម្នាក់មិនចង់បន្តនិរន្តភាពនៃវគ្គនេះឡើយ។

ក្រោយការដកស្រង់មតិលើសិក្ខាកាមចំនួន ១០៥នាក់ សម្រាប់៦មុខវិជ្ជារួចមក ឃើញថាពួកគាត់ទាំងអស់គ្នា សុទ្ធតែសង្ឃឹមថាឱ្យមានការបណ្តុះបណ្តាលវគ្គនេះសម្រាប់ឆ្នាំសិក្សាក្រោយទៀត គឺមិនត្រឹមតែជាលោកគ្រូអ្នកគ្រូដែលនៅសាលាគម្រោង SEIP ប៉ុណ្ណោះទេ ប៉ុន្តែសិក្ខាកាមទាំងអស់ ចង់ឱ្យលោកគ្រូអ្នកគ្រូនៅគ្រប់សាលាទូទាំងប្រទេសមានឱកាសក្នុងការសិក្សានេះដែរ ព្រោះពួកគាត់ចង់ឱ្យគ្រូទាំងអស់ទទួលបានចំណេះដឹងបន្ថែម និងមានសមត្ថភាពសមមូលគ្នា ព្រមជាមួយនឹងការអនុវត្តការដូចៗគ្នាមិនថាសាលានៅតំបន់ក្រុង និងជនបទឡើយ។

ដោយយោងតាម គោលនយោបាយអប់រំចំណុចទី២ គឺការពង្រឹងសមត្ថភាពមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ការអនុវត្តគម្រោងគួរតែត្រូវបានពង្រីកទៅគ្រប់សាលាទាំងអស់ ព្រោះជាការងារចាំបាច់មួយ ក្នុងការលើកកម្ពស់គុណភាពអប់រំ ពិសេសលទ្ធផលសិស្សានុសិស្សពេលឆ្លងភូមិសិក្សានីមួយៗ និងសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់ និងពិភពលោក។ គ្រូបង្រៀនគឺ ជាចំណែកមួយយ៉ាងសំខាន់ និងមិនអាចខ្វះបាន ព្រោះអ្វីទាំងអស់ក្នុងមជ្ឈដ្ឋានអប់រំសាលារៀនត្រូវផ្សារភ្ជាប់នឹងពួកគាត់ ហើយបន្ទាប់ពីនោះទើបជាគណៈគ្រប់គ្រង សហគមន៍ និងអ្នកពាក់ព័ន្ធដទៃទៀត។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន សំណូមពរ និងអនុសាសន៍

## ៥.១-សេចក្តីសន្និដ្ឋាន

ស្នាដៃស្រាវជ្រាវនេះបានបង្ហាញឱ្យឃើញ ពីទស្សនៈនានាចំពោះដំណើរការនៃការអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដូចជា ការអនុវត្តកម្មវិធីសិក្សារបស់វគ្គ ការកំណត់ពេលវេលានៃវគ្គ បញ្ហាប្រឈមនានាជុំវិញការបណ្តុះបណ្តាលចំណេះដឹងទាំងឡាយដែលសិក្ខាកាមទទួលបាន និងសមត្ថភាពនៃការអនុវត្តចំណេះដឹងក្នុងវគ្គ។ ព្រមជាមួយគ្នានេះ ការស្រាវ ជ្រាវនេះ ក៏បានបង្ហាញឱ្យឃើញពីទស្សនៈជារួមសម្រាប់កម្មវិធីនេះផងដែរ ដែលរាល់ចំណុចទាំងអស់ សុទ្ធតែបានបញ្ជាក់ពីគុណប្រយោជន៍ និងបញ្ហាប្រឈមដូចការសន្និដ្ឋានលទ្ធផលខាងក្រោមនេះ៖

### ៥.១.១-ការកំណត់ពេលវេលា និងការអនុវត្តកម្មវិធីសិក្សានៃវគ្គ

ជាសរុបរួមការកំណត់ពេលវេលា និងកាអនុវត្តកម្មវិធីសិក្សានៃវគ្គទាំងមូលមានលក្ខណៈល្អ ព្រោះវាបានផ្តល់ឱកាសសិក្សាដោយមិនប៉ះពាល់ដល់ការបង្រៀន និងផ្តល់នូវចំណេះដឹងបច្ចេកទេស និងវិធីសាស្ត្រល្អៗដល់លោកគ្រូអ្នកគ្រូ គួបផ្សំនឹងការអនុវត្តជាក់ស្តែងនៅសាលា។ ប៉ុន្តែទន្ទឹមនឹងនេះ ក៏នៅមានចំណុចខ្វះខាតមួយចំនួនដូចជា កម្មវិធីសិក្សាខ្លះមានកម្រិតខ្ពស់ហួសពីសមត្ថភាពសិក្ខាកាម និងចាកឆ្ងាយពីមុខវិជ្ជាឯកទេសពេក មេរៀនស្រាវជ្រាវមានភាពគ្របដណ្តប់ច្រើនពេក ការបង្រៀនពេលខ្លះលឿនពេក និងពេលវេលាសិក្សាក្នុងមួយថ្ងៃច្រើនម៉ោងពេក ដែលទាំងនេះសុទ្ធសឹងជាបញ្ហាដែលត្រូវដោះស្រាយ។

### ៥.១.២-ការអនុវត្តចំណេះដឹង និងវិធីសាស្ត្របង្រៀន៖

ក្រោយទទួលបានចំណេះដឹង និងវិធីសាស្ត្រផ្សេងៗពីវគ្គសិក្សា លោកគ្រូអ្នកគ្រូស្ទើរតែទាំងអស់សុទ្ធតែអាចយកចំណេះដឹងនោះទៅអនុវត្តបាន គ្រាន់តែការអនុវត្តនោះនៅមានកម្រិតមធ្យមនៅឡើយ ព្រោះការទទួលចំណេះដឹងមិនទាន់បានច្បាស់លាស់ ស្ថានភាពនៅតាមសាលា និងកន្លែងសិក្សាមិនដូចគ្នា ដោយសាលាជាក់ស្តែងមានពេលវេលាតិច តែវិធីសាស្ត្រទទួលបានត្រូវការពេលវេលាច្រើន។ ម្យ៉ាងវិញទៀត វិធីសាស្ត្រថ្មីពេកធៀបនឹងចំណេះដឹងសិស្សនៅតាមសាលានៅមានកម្រិតទាបនៅឡើយ ហើយសាលាមិនមានសម្ភារឧបទេសគ្រប់គ្រាន់ ដូចជាសម្ភារពិសោធជាដើម។ លើសពីនេះទៅទៀត ក្នុងមួយសាលាមានលោកគ្រូអ្នកគ្រូដែលមិនបានមករៀនច្រើន ហើយមិនសូវទទួលយកវិធីសាស្ត្រថ្មីនៅតែបន្តអនុវត្តវិធីសាស្ត្រ

ចាស់នៅឡើយ។ បន្ថែមលើសពីនោះគឺ សិស្សនៅវិទ្យាល័យមានចំនួនច្រើន និងមិនងាយក្នុងការកែទម្លាប់ចាស់របស់ពួកគេឡើយ។

### ៥.១.៣-បញ្ហាប្រឈមនៃវគ្គសិក្សា

តាមរយៈការសិក្សាស្រាវជ្រាវនេះឃើញថា បញ្ហាប្រឈមជាច្រើនដែលបានកើតឡើងនៅក្នុងវគ្គ ហើយបញ្ហាដែលសំខាន់ជាងគេនោះគឺ ការធ្វើដំណើរ។ ជាការពិតអ្នកសិក្សាស្ទើរតែអស់សុទ្ធតែមកពីបណ្ដាខេត្ត ដែលពួកគាត់ភាគច្រើនត្រូវធ្វើដំណើរទាំងយប់ ព្រោះដោយការមិនចង់ចំណាយលើថ្លៃផ្ទះសំណាក់មួយយប់មុនការសិក្សា។ បញ្ហានេះ វាមានការទាក់ទងទៅនឹងថវិកាដែលគម្រោងបានផ្ដល់ឱ្យ ដោយពួកគាត់គិតថា ថវិកាដែលផ្ដល់ជូនតិចពេកមិនសមនឹងការចំណាយ។ រីឯបញ្ហាប្រឈមដទៃទៀត មិនមានអ្វីជាការចោទខ្លាំងនោះឡើយ។

### ៥.១.៤-ទស្សនៈអំពីវគ្គ

ទោះបីជា មានការលើកឡើងនូវបញ្ហាលំបាកខ្លះក៏ដោយ ជាទិដ្ឋភាពរួមលើការអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន TUP នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺមានលក្ខណៈល្អអាចទទួលយកបាន។ ការបណ្ដុះបណ្ដាលនេះពិតជាបានចូលរួមចំណែកក្នុងការពង្រឹង និងលើកកម្ពស់សមត្ថភាពគ្រូបង្រៀន នៅមធ្យមសិក្សាបឋមភូមិនៃសាលាគម្រោង ឱ្យមានកម្រិតប្រហាក់ប្រហែលនឹងគ្រូបរិញ្ញាបត្រ ជាពិសេសការផ្ដល់ចំណេះដឹងលើផ្នែកឯកទេស និងវិធីសាស្ត្របង្រៀនសម្បូរបែបស្របតាមសម័យកាលនៃការអប់រំនៅសតវត្សទី២១ និងបានចូលរួមចំណែកកែប្រែនូវផ្នត់គំនិតអវិជ្ជមាននៃការបំពេញការងារមួយចំនួនរបស់លោកគ្រូអ្នកគ្រូឱ្យមានស្ថានភាពល្អប្រសើរជាងមុន។ មិនត្រឹមតែប៉ុណ្ណោះ វគ្គនេះនឹងអាចជួយលើកកម្ពស់នូវក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងការអនុវត្តគោលនយោបាយគ្រូបង្រៀនរបស់ក្រសួងអប់រំឱ្យសម្រេចបានតាមទិសដៅដែលបានកំណត់ក្នុងចក្ខុវិស័យនាពេលអនាគត បើការអនុវត្តនៃវគ្គនៅតែបន្តនិរន្តភាពឱ្យបានទូទាំងប្រទេស។

## ៥.២-សំណូមពរ

បើទោះបីជាលទ្ធផលដែលបានរកឃើញបង្ហាញថា ការអនុវត្តកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ស្ថិតក្នុងកម្រិតមួយល្អយ៉ាងណាក៏ដោយក៏អ្នកស្រាវជ្រាវសូមលើកឡើងនូវសំណូមពរមួយចំនួន ដើម្បីចូលរួមចំណែកក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីនេះ និងកែលម្អចំណុចខ្វះខាតដែលភាគីពាក់ព័ន្ធនានា មានដូចជា ក្រសួងអប់រំយុវជននិងកីឡា ម្ចាស់ជំនួយ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ មន្ទីរអប់រំយុវជននិងកីឡាខេត្ត គណៈគ្រប់គ្រង សាលារៀន ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន

និងអាណាព្យាបាលសិស្ស ត្រូវរួមគ្នាដោះស្រាយជាប្រព័ន្ធទើបការងារនេះបានទទួលជោគជ័យ។

**៥.២.១-ក្រសួងអប់រំ យុវជន និងកីឡា**

- សូមបន្តសហការជាមួយម្ចាស់ជំនួយ បើកវគ្គបណ្តុះបណ្តាលនេះសម្រាប់ឆ្នាំសិក្សាក្រោយទៀត ដើម្បីបន្ថែមសាលាគោលដៅឱ្យបានច្រើនជាងនេះគឺ ទូទាំងប្រទេសបើសិនជាអាច។
- ចូលរួមពិនិត្យតាមដានលើការអនុវត្តកម្មវិធី ដើម្បីឈានទៅរកការកែលម្អចំណុចអវិជ្ជមាន ឱ្យមានលក្ខណៈកាន់តែប្រសើរឡើង។
- សូមធ្វើការស្នើសុំទៅម្ចាស់ជំនួយ ដើម្បីផ្តល់ជូននូវថវិកាសមរម្យសម្រាប់សិក្ខាកាមដែលមកសិក្សា ដោយថ្លឹងថ្លែងលើការចំណាយផ្សេងៗ ពិសេសលើចម្ងាយផ្លូវធ្វើដំណើរពីបណ្តាខេត្តផ្សេងៗផងដែរ។
- បើសិនជា ក្រសួងអប់រំអាចជំរុញឱ្យមានកន្លែងប្រមូលផ្តុំបណ្តុះបណ្តាលតាមខេត្តសម្រាប់លោកគ្រូអ្នកគ្រូដែលនៅជិតៗគ្នា គឺអាចកាត់បន្ថយការចំណាយបានច្រើន។

**៥.២.២-ម្ចាស់ជំនួយ**

- សូមបន្តសហការ និងអនុវត្តគម្រោងឱ្យបានទូលំទូលាយជាងនេះ ដើម្បីផ្តល់ឱកាសដល់លោកគ្រូអ្នកគ្រូផ្សេងៗទៀតបានមករៀនសូត្រផងដែរ។
- សូមជួយផ្តល់ជាកញ្ចប់ថវិកាសមរម្យមួយ ដើម្បីឱ្យមានតុល្យភាពលើការចំណាយផ្សេងៗសម្រាប់ទ្រទ្រង់ការសិក្សា។
- សូមមន្ត្រីគម្រោងទាំងអស់ជួយចូលរួមតាមដាន វាយតម្លៃ និងគាំទ្រតាមមធ្យោបាយផ្សេងៗដល់គណៈគ្រប់គ្រង និងលោកគ្រូអ្នកគ្រូនៃសាលាគោលដៅឱ្យបានជាប្រចាំ។

**៥.២.៣-សាកលវិទ្យាល័យភូមិន្ទ**

- បន្តសហការ និងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ឆ្នាំសិក្សាក្រោយឱ្យកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។
- ពិនិត្យតាមដាន និងវាយតម្លៃឱ្យបានសមស្របលើ ការរៀបចំពេលវេលានៃវគ្គ និងពេលវេលាសិក្សា កម្រិតកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន ដើម្បីឱ្យសិក្ខាកាមអាចទទួលយកបាន និងអនុវត្តបានយ៉ាងមានប្រសិទ្ធភាព។
- ជួយសម្រួលរាល់ការលំបាកមួយចំនួនរបស់សិក្ខាកាម ក៏ដូចជាដំណើរការរបស់វគ្គសិក្សាតាមលទ្ធភាពដែលអាចធ្វើបាន។

### ៥.២.៤-មន្ទីរអប់រំ យុវជន និងកីឡា

- ចូលរួមគាំទ្រ និងផ្សព្វផ្សាយពីការអនុវត្តគម្រោងដល់សាលារៀនដែលជាគោលដៅ និងលោកគ្រូអ្នកគ្រូឱ្យបានទូលំទូលាយ។
- ជួយឧបត្ថម្ភទាំងផ្នែកសម្ភារ និងបច្ចេកទេសដល់សាលាគម្រោងដើម្បីផ្តល់ភាពងាយស្រួលដល់សិក្ខាកាមនៃវគ្គTUP អនុវត្តនូវចំណេះដឹង និងវិធីសាស្ត្រផ្សេងៗ។

### ៥.២.៥-គណៈគ្រប់គ្រងសាលារៀន

- ផ្សព្វផ្សាយឱ្យបានច្បាស់លាស់អំពីកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនដល់គ្រូបង្រៀនឱ្យបានទូលំទូលាយបំផុត។
- ពង្រឹងការគ្រប់គ្រង និងដឹកនាំការបង្រៀនរបស់គ្រូ និងការរៀនសូត្ររបស់សិស្ស។
- ធ្វើផែនការនិងអនុវត្តអធិការកិច្ចផ្ទៃក្នុងជាប្រចាំ និងកែលម្អចំណុចខ្វះខាតរបស់គ្រូ។
- ចូលរួមគាំទ្រ និងដោះស្រាយរាល់បញ្ហាលំបាករបស់គ្រូក្នុងការបង្រៀនដូចជាការផ្តល់ជូន សម្ភារឧបទេស រៀបចំសម្ភារនិងបន្ទប់ពិសោធន៍ជាដើម។
- ទំនាក់ទំនង និងសហការជាមួយភាគីពាក់ព័ន្ធ ដូចជាមន្ត្រីគម្រោង គ្រូបង្រៀន សិស្ស និងអាណាព្យាបាលសិស្សជាប្រចាំដោយប្រើមធ្យោបាយគ្រប់រូបភាព ដើម្បីពង្រឹងការអនុវត្តគម្រោងឱ្យកាន់តែមានប្រសិទ្ធភាព។

### ៥.២.៦-គ្រូបង្រៀន ឬសិក្ខាកាម

- ខិតខំព្យាយាមទទួលយកនូវខ្លឹមសារមេរៀន បច្ចេកទេស បទពិសោធ ចំណេះដឹងថ្មីៗ និងវិធីសាស្ត្របង្រៀនល្អៗពីវគ្គ យកទៅអនុវត្តដោយយកចិត្តទុកដាក់ខ្ពស់។
- គោរពតាមការចាត់តាំងរបស់នាយកសាលា និងអនុវត្តប្រកបដោយមនសិកាវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់។
- មានការតាំងចិត្តខ្ពស់ ក្នុងការអនុវត្តចំណេះដឹងពីវគ្គប្រកបដោយប្រសិទ្ធភាពដោយឈរ លើគោលការណ៍ណែនាំ ការរៀបចំវិធីសាស្ត្របង្រៀនបានត្រឹមត្រូវ និងចូលរួមប្រជុំក្រុមបច្ចេកទេសជាប្រចាំដើម្បីផ្សព្វផ្សាយ ណែនាំដល់លោកគ្រូអ្នកគ្រូដែលមិនបានមករៀនឱ្យពួកគាត់ចូលរួមបានទូទាំងសាលា។
- ខិតខំអភិវឌ្ឍចំណេះដឹងរបស់ខ្លួនតាមការរីកចម្រើននៃសម័យកាលបច្ចេកវិទ្យា និងយកចំណេះ ដឹងលើជំនាញរបស់ខ្លួនទៅអនុវត្តឱ្យបានត្រឹមត្រូវ។
- ស្វ័យសិក្សាបន្ថែម និងប្រើប្រាស់វិធីសាស្ត្របង្រៀនសម្បូរបែបសមស្របតាមកាលៈទេសៈ និងស្ថានភាពសមត្ថភាពរបស់សិស្ស។

- ពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ព្រមទាំងផ្តល់ព័ត៌មានត្រឡប់ជូនដល់សិស្ស និងអាណាព្យាបាលសិស្សជាប្រចាំនូវលទ្ធផលសិក្សារបស់សិស្ស។

### ៥.២.៧-អាណាព្យាបាលសិស្ស

- ចូលរួមសហការជាមួយសាលារៀន និងគ្រូបង្រៀនរបស់គម្រោងក្នុងការជំរុញការសិក្សារបស់សិស្សបន្ថែម។
- ពិនិត្យតាមដានការសិក្សារបស់កូនជាប្រចាំ និងផ្តល់ព័ត៌មានត្រឡប់ ជូនសាលារៀនវិញឱ្យបានទាន់ពេលវេលា។
- យកចិត្តទុកដាក់ និងចូលរួមអភិវឌ្ឍសាលារៀន តាមរយៈការជួយជាថវិកា សម្ភារៈដើម្បីកែលម្អសាលារៀន និងការអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាពជាដើម។

## ៥.៣. អនុសាសន៍សម្រាប់ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាស្រាវជ្រាវនេះ ផ្តោតតែលើទស្សនៈសិក្ខាកាមដែលរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញតែប៉ុណ្ណោះ ហើយសម្រាប់អ្នកស្រាវជ្រាវបន្តទៀត អាចពិចារណាលើ ចំណុចមួយចំនួនដូចខាងក្រោម៖

- ស្រាវជ្រាវលើប្រធានបទដដែល តែជ្រើសរើសសំណាកធំជាងនេះ ដោយធ្វើការប្រមូលទិន្នន័យតាមបែបគុណវិស័យ តាមរយៈការសម្ភាសន៍ផ្ទាល់ឱ្យបានច្រើនជាងនេះ ជាមួយអ្នកឆ្លើយសំណួរតែម្តង។
- អាចធ្វើការសិក្សាស្រាវជ្រាវអំពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងវគ្គ មន្ត្រីគម្រោងគណៈគ្រប់គ្រងសាលា និងគ្រូបង្រៀននៃសាលាដែលទទួលគម្រោងផ្ទាល់តែម្តង។

# គន្ថនិទ្ទេស


១. ក្រសួងអប់រំ យុវជន និងកីឡា-គោលនយោបាយស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ (២០១២)
២. ក្រសួងអប់រំ យុវជន និងកីឡា-ស្តង់ដារវិជ្ជាជីវៈគ្រូបង្រៀន (២០១៦)
៣. ក្រសួងអប់រំ យុវជន និងកីឡា-សេចក្តីពង្រាងលើកទី១ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៨)
៤. ក្រសួងអប់រំ យុវជន និងកីឡា-យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ (២០១៨)
៥. ក្រសួងអប់រំ យុវជន និងកីឡា-ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (២០១៩)
៦. មជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា-ជំនួយស្មារតីស្តីពី បដិវត្តន៍ឧស្សាហកម្មទី៤ (២០១៩)
៧. រាជរដ្ឋាភិបាលកម្ពុជា-ច្បាប់ស្តីពីការអប់រំ (២០១៧)
៨. មជ្ឈមណ្ឌលអភិវឌ្ឍកម្ពុជា-គោលនយោបាយគ្រូបង្រៀន (២០១៣)
៩. Teacher Training Department -Teacher Policy Action Plan, 2015
១០. សិក្ខាសាលាពិគ្រោះយោបល់ លោកព្រឹង មរកត ស្តីពី-ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន (២០១៩)
១១. SEAMEO INNOTECH-Teaching Competency Standards in Southeast Asian Countries, Philippine (2010)
១២. ក្រសួងអប់រំ យុវជន និងកីឡា-បទបង្ហាញស្តីពីសញ្ញាណគោលនយោបាយកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា (២០១៩)
១៣. MoEYS-Operational Manual for Teacher Upgrading Program (2017)
១៤. ហង់ជួន ណារ៉ុន-សន្និបាទអប់រំស្តីពី ចក្ខុវិស័យកំណែទម្រង់វិស័យអប់រំ (២០១៥)
១៥. មហាវិទ្យាល័យអប់រំ-របាយការណ៍សិក្ខាកាមវគ្គ TUPនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ (២០១៩)
១៦. រាជរដ្ឋាភិបាលកម្ពុជា-អនុក្រិតស្តីពីក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន (២០០៨
១៧. ក្រសួងអប់រំ យុវជន និងកីឡា-គោលនយោបាយស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ (២០១៦)
១៨. រាជរដ្ឋាភិបាលកម្ពុជា-គោលនយោបាយចតុកោណដំណាក់កាលទី ៤ (២០១៨)
១៩. ក្រសួងអប់រំ យុវជន និងកីឡា-គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត (២០១៩)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

**កម្រងសំណួរស្រាវជ្រាវ**
**សម្រាប់សរសេរនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ**
**ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ**

ខ្ញុំបាទឈ្មោះ កែម សុកែវ ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិ នៃវិទ្យាស្ថានជាតិអប់រំនឹងធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **ទស្សនៈយល់ឃើញរបស់សិក្ខាកាមដែលបានរៀនវគ្គកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ** ដើម្បីបញ្ចប់ការសិក្សថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំឯកទេសវិជ្ជាជីវៈនាយកសាលាមធ្យមសិក្សាទុតិយភូមិនៅវិទ្យាស្ថានជាតិអប់រំ ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកគ្រូ អ្នកគ្រូទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការឆ្លើយនឹងកម្រងសំណួររបស់ខ្ញុំបាទ ។ ចម្លើយរបស់លោកគ្រូអ្នកគ្រូបានចូលរួមចំណែកក្នុងការបង្ហាញអំពីទស្សនៈយល់ឃើញចំពោះកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានតាមរយៈកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនទៅកម្រិតបរិញ្ញាបត្រអប់រំ ។ សូមលោកគ្រូ អ្នកគ្រូមេត្តាជួយគូសសញ្ញា ✓ និងឆ្លើយសំណួរដូចខាងក្រោម ៖

I. **ពត៌មានទូទៅ**

ខេត្ត:..............................

ស្រុក:.............................

អនុវិទ្យាល័យ/វិទ្យាល័យ:..........................

១. ភេទ: □១.ស្រី □២. ប្រុស

២. អាយុ:..................ឆ្នាំ

៣. ស្ថានភាពគ្រួសារ: □១.នៅលីវ □២. មានគ្រួសារ □៣.ពោះម៉ាយ/មេម៉ាយ

៤. កម្រិតវប្បធម៌:

□១. មធ្យមសិក្សាទុតិយភូមិ □២. បរិញ្ញាបត្រ □៣. បរិញ្ញាបត្រជាន់ខ្ពស់ □៤. បណ្ឌិត

៥. គ្រូបង្រៀនឯកទេស: ..........................................................

៦. បទពិសោធការងារ:

□១. ១-៥ឆ្នាំ □២. ៥-១០ឆ្នាំ □៣. ១០-២០ឆ្នាំ □៤. ២០ឆ្នាំឡើងទៅ

II. **អំពីទស្សនៈផ្ទាល់ខ្លួន**

៧. តើលោកគ្រូ/អ្នកគ្រូធ្លាប់បានដឹងពីកម្មវិធីបណ្តុះបណ្តាលនេះពីមុនមកដែរឬទេ?

□១.ធ្លាប់ដឹងច្បាស់ □២.ដឹងស្រពិចស្រពិល □៣. មិនដឹង (រំលងទៅសំណួរទី៩)

៨. តើលោកគ្រូ/អ្នកគ្រូទទួលបានព័ត៌មានវគ្គបណ្តុះបណ្តាលនេះ តាមរយៈអ្វី?

□១. នាយកសាលា □២. ការិ.អ.យ.កស្រុក □៣. មន្ទីរអ.យ.កខេត្ត □៤.ក្រសួងអ.យ.ក

□៣. ផ្សេងៗ.................................

៩.តើលោកគ្រូ/អ្នកគ្រូបានមករៀនវគ្គបណ្តុះបណ្តាលនេះតាមរយៈអ្វី? ...................................................

.......................................................................................................................................។

១០. តើមានមូលហេតុអ្វីខ្លះដែលជំរុញឱ្យលោកគ្រូ/អ្នកគ្រូសម្រេចចិត្តចូលរៀនវគ្គនេះ?

...............................................................................................................................................

.............................................................................................................................................។

១១. តើលោកគ្រូ/អ្នកគ្រូពេញចិត្តចំពោះវគ្គសិក្សានេះដែរឬទេ?

□១.ពេញចិត្តណាស់ □២.ពេញចិត្ត □១.មិនសូវពេញចិត្ត □១.មិនពេញចិត្តទេ

(បើមិនពេញចិត្ត) ហេតុអ្វី? ..........................................................................................................

១២. ជុំវិញការបណ្តុះបណ្តាល ចំពោះពេលវេលាក្នុងការសិក្សា តើលោកគ្រូ/អ្នកគ្រូយល់យ៉ាងណាដែរ?

□១.ឯកភាពទាំងស្រុង □២.មិនឯកភាព □១.ធម្មតា

ហេតុអ្វី?...................................................................................................................................

...........................................................................................................................................។

១៣. តើកម្មវិធីសិក្សាដែលវគ្គបានដាក់សមស្របនឹងសមត្ថភាពសិក្ខាកាមអាចទទួលយកបានដែរឬទេ?

□១.សមស្រប □២.មិនទាន់សមស្រប □១.មិនសមស្រប □១.មិនដឹងច្បាស់

(បើមិន) ត្រង់ចំណុចណាខ្លះ?..........................................................................................................

...........................................................................................................................................។

១៤.តើលោកគ្រូអ្នកគ្រូបានទទួលវិធីសាស្រ្តបង្រៀនថ្មីៗអ្វីខ្លះពីវគ្គបណ្តុះបណ្តាលនេះ?

...........................................................................................................................................

១៥.វិធីសាស្រ្តទាំងនោះ តើលោកគ្រូអ្នកគ្រូគិតថាអាចយកទៅអនុវត្តក្នុងកាបង្រៀនជាក់ស្តែងរបស់លោកគ្រូអ្នកគ្រូបានដែរឬទេ?

□១.បាន ហេតុអ្វី?..........................................................................................................................

□២.បានខ្លះ ហេតុអ្វី?......................................................................................................................

□៣.មិនបាន ហេតុអ្វី?......................................................................................................................

១៦. អំឡុងពេលសិក្សា តើអ្វីខ្លះដែលលោកគ្រូ/អ្នកគ្រូគិតថាជាបញ្ហាលំបាកសម្រាប់លោកគ្រូ/អ្នកគ្រូ?
(ចម្លើយអាចលើសពីមួយ)

□១.ខ្លឹមសារ □២.មុខវិជ្ជាឯកទេស □៣.ភាសាបរទេស □៤.វិធីសាស្រ្តបង្រៀន

□៥.ការធ្វើដំណើរ □៦.ការប្រើសម្ភារឧបទេស □៧.បញ្ហាថវិកា □៨.ផ្សេងៗ..................................

ហេតុអ្វី?...................................................................................................................................

...........................................................................................................................................

..........................................................................................................................................។

១៧. ចំពោះបញ្ហាទាំងនោះ ត្រូវបានដោះស្រាយដែរឬទេ?

□១.បានដោះស្រាយ □២.បានដោះស្រាយខ្លះ □៣. មិនទាន់ដោះស្រាយបាន □៤.មិនមានដំណោះស្រាយ

(បើដោះស្រាយ)តាមវិធីណា? ................................................................................................................

.........................................................................................................................................................

...................................................................................................................................................។

១៨. ជារួម តើលោកគ្រូ/អ្នកគ្រូយល់ដូចម្ដេចចំពោះកម្មវិធីសិក្សាក្នុងវគ្គបណ្ដុះបណ្ដាលនេះ?

□១.ល្អណាស់ □២.ល្អ □៣.មិនទាន់ល្អ □៤.មិនល្អទេ

មូលហេតុអ្វី? .........................................................................................................................................

..........................................................................................................................................................។

១៩. ក្រោយពីបញ្ចប់វគ្គបណ្ដុះបណ្ដាលនេះ តើលោកគ្រូ/អ្នកគ្រូទទួលបានចំណេះដឹង ឬបទពិសោធន៍អ្វីខ្លះ?.....................................................................................................................................................

............................................................................................................................................................

............................................................................................................................................................

.......................................................................................................................................................។

២០.តើលោកគ្រូ/អ្នកគ្រូគិតថាអ្វីដែលទទួលបានពីវគ្គនេះអាចយកទៅអនុវត្តនៅសាលារៀនរបស់លោកគ្រូ/អ្នកគ្រូបានកម្រិតណា?

□១.បាន៨០%-១០០% □២.បាន៦៥%-៨០% □៣.បាន៥០%-៦៥% □៤. បាន៥០%ឬ<៥០%

មូលហេតុអ្វី? ........................................................................................................................................

.......................................................................................................................................................

.................................................................................................................................................។

២១. ក្រោយពីបញ្ចប់វគ្គនេះ តើលោកគ្រូ/អ្នកគ្រូមានទស្សនៈបែបណាចំពោះកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញនេះ?.................................................................។..................

............................................................................................................................................................

............................................................................................................................................................

....................................................................................................................................។

២២. តាមទស្សនលោកគ្រូ/អ្នកគ្រូ តើគួរឱ្យមាននូវវគ្គបណ្ដុះបណ្ដាលនេះបន្តទៀតឬទេ? ហេតុអ្វី?

............................................................................................................................................................

............................................................................................................................................................

............................................................................................................................................................

..........................................................................................................................................................។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមឆ្លើយនូវកម្រងសំណួររបស់លោកគ្រូ/អ្នកគ្រូ។

**សូមអរគុណ**!

# ជំពូកទី១.សេចក្តីផ្តើម

# ជំពូកទី២. រំលឹកទ្រឹស្តី

# ជំពូកទី៣. វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៤.វិធីសាស្រ្តវិភាគទិន្នន័យ

# ជំពូកទី៥. សេចក្តីសន្និដ្ឋាន សំណូមពរ និង អនុសាសន៍